# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## របាយការណ៍កម្មសិក្សាបញ្ចប់ការ

## ប្រធានបទ៖ ការអភិវឌ្ឍជនបទ
## ឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល

កម្មសិក្សាថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៩ ដល់ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១៩

ឈ្មោះស្ថាប័ន៖ **សាលាឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល**


តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ

និស្សិតឈ្មោះ **ព្រំ បញ្ញា** | លោក **ខួន ហេង**

**ហួ លីហួង**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍ | ឆ្នាំចូលសិក្សា ២០១៥

ជំនាន់ទី ០៣ | ឆ្នាំសរសេររបាយការណ៍ ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រុម $D_4A_1$ រៀនជំនាញផ្នែក សេដ្ឋកិច្ចអភិវឌ្ឍន៍។ ពួកយើងបានធ្វើជារបាយការណ៍កម្មសិក្សា បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដែលមានប្រធានបទ "ការអភិវឌ្ឍជនបទនៅក្នុង ឃុំព្រែកវៃ ស្រុកល្វាឯម ខេត្តកណ្តាល" បានបញ្ចប់ដោយជោគជ័យជាស្ថាពរ។

យើងខ្ញុំទាំងពីរសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះអ្នកមានគុណទាំងពីរ ដែលបានបីបាច់ ថែរក្សា ការពារ ប្រៀនប្រដៅ ព្រមទាំងអប់រំ រហូតមកដល់ថ្ងៃមួយនេះ ដោយសារការខិតខំប្រឹងប្រែងរបស់លោកទាំងទ្វេ។

របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាមួយនេះអាចទទួលបានជោគជ័យ ចេញជាលទ្ធផលបែបនេះ ពីព្រោះតែដោយមានការចូលរួមពីគ្រប់ថ្នាក់នៃគ្រប់ផ្នែក ដូចច្នេះពួកយើងខ្ញុំសូមធ្វើការថ្លែងអំណរគុណដល់គ្រប់អ្នកមានភារកិច្ចទាំងនេះ ដែលមានការរៀបរាប់ដូចតទៅៈ

យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ ឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តមសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងមន្ត្រីរាជការទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងធំធេងបំផុតជូនចំពោះ លោកសាស្ត្រាចារ្យ លោក ងួន ហេង ដែលលោកគ្រូបានជួយជ្រោមជ្រែងអស់ពីកម្លាំងកាយចិត្ត ដោយមានការផ្តល់ជា អនុសាសន៍សម្រាប់របាយការណ៍ចុះកម្មសិក្សានេះ តាំពីចាប់ផ្តើមរហូតដល់ចុងបញ្ចប់។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ អាជ្ញាធរមូលដ្ឋាន មេឃុំ ប្រធានភូមិ និងអ្នកសហការជាមួយទាំងអស់នៅក្នុងភូមិ ដែលបានចំណាយជាពេលវេលាក្នុងកំឡុងពេលដែលជាប់ មានភារកិច្ចនៅនឹងខ្លួនក៏នៅតែឈ្លៀតពេលមកផ្តល់ ជាឯកសារក៏ដូចជាពត៌មាន ដែលជាប់ពាក់ព័ន្ធនានា ដែលធ្វើអោយការស្រាវជ្រាវមួយនេះមានដំណើរការយ៉ាងរលូន។ ជាទីបញ្ចប់ពួកយើងខ្ញុំទាំងពីរសូមប្រសិទ្ធពរជ័យ សិរីសួរស្តី ជ័យមង្គល វិបុលសុខ មហាប្រសើរ ចូរកើតមានដល់លោកមានគុណទាំងទ្វេ និងអ្នកដែលបានជួយជ្រោមជ្រែងដល់ការស្រាវជ្រាវនេះ អោយជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពុលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នាពេលបច្ចុប្បន្ននេះ នៅលើទូទាំងពិភពលោកយើងនេះកំពុងតែមានការយកចិត្តទុកដាក់លើបញ្ហាមានភាពរអាក់រអួលដល់ដំណើរការសេដ្ឋកិច្ចជាចម្បងក្នុងប្រទេសរៀងៗខ្លួន។ ការប្រកួតប្រជែងនៅសម័យសាកលភាវូបនីយកម្ម ដែលធ្វើអោយ ប្រទេសនីមួយៗខិតខំទាញយកផលចំណេញពីសេដ្ឋកិច្ច។ បើត្រឡប់មកមើលស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជាវិញ មានការជួបប្រទះបញ្ហាជាច្រើនដែលធ្វើ អោយប្រជាជនតាមជនបទមានការពិបាក ក្នុងការប្រកបមុខរបររកប្រាក់កម្រៃមកផ្គត់ផ្គង់ក្នុងជីវភាពរស់នៅរបស់ខ្លួនប្រចាំថ្ងៃ។ កង្វះហេដ្ឋារចនាសម្ព័ន្ធរូបវន្ត កង្វះចំណេះដឹងនៃធនធានមនុស្ស ដែលបណ្តាលអោយមានផលិតភាពទាប ពិបាកក្នុងការប្រកួតប្រជែង។ វាជាហេតុដែលរុញច្រាន អោយពួកយើងមានការសម្រេចចិត្តជ្រើសរើសយកប្រធានបទដែលបានលើកឡើង "ការអភិវឌ្ឍជនបទនៅក្នុង ឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល" មកធ្វើការស្រាវជ្រាវ។

ចំពោះកម្រងឯកសារស្រាវជ្រាវដែលមាននេះ ជាសមិទ្ធផលមួយដែលឆ្លងកាត់នៅការសិក្សាស្រាវជ្រាវ ពីសំណាក់កម្រងឯកសារជាច្រើន រួមទាំងមានពត៌មាន និងការតម្រង់ទិសពីលោក សាស្ត្រា ចារ្យដែលមានជំនាញច្បាស់លាស់ផងដែរ។ យើងខ្ញុំសង្ឃឹមថា កិច្ចការស្រាវជ្រាវមួយនេះ នឹងអាចមានការចូលរួមចំណែកជួយសម្រួលដល់ស្ថាប័នអភិវឌ្ឍន៍ ក៏ដូចជាបង្ហាញពីស្ថានកាលនៃការរីកចម្រើននៃសហគមន៍ ហើយផ្តល់ជាគំនិតដល់អ្នកសិក្សាស្រាវជ្រាវទាំងឡាយផងដែរ។

ពួកយើងខ្ញុំសូមអភ័យទោសទុកជាមុនរាល់កំហុសឆ្គងទាំងឡាយណា ដែលបានកើតឡើងដោយអចេតនា ព្រោះការធ្វើរបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាមួយឡើង នោះរមែងតែងមានកំហុសឆ្គងមួយចំនួនដោយជៀសមិនផុតឡើយ។ ការរិះគន់ដើម្បីស្ថាបនាពីសំណាក់លោកអ្នក ដែលបានអាន និងសិក្សាបន្តមកពីគ្រប់មជ្ឈដ្ឋានទាំងអស់ ពួកយើងគឺស្វាគមន៍រាល់កិច្ចទាំងអស់នេះ ដែល បណ្តាលអោយរបាយការណ៍សក្សាស្រាវជ្រាវមួយនេះកាន់តែមានភាពល្អប្រសើរមួយកម្រិតទៀត។

# មាតិកា


បញ្ជីតារាង ........ v

បញ្ជីក្រាហ្វិក ........ vi

បញ្ជីឧបសម្ព័ន្ធ ........ vii


## សេចក្តីផ្តើម


១ លំនាំបញ្ហា ........ ១

២ ចំណោទបញ្ហា ........ ១

៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

៤ ទំហំ និងដែនកំណត់ស្រាវជ្រាវ ........ ២

៥ វិធីសាស្ត្រស្រាវជ្រាវ ........ ២

៦ សារៈសម្ខាន់នៃការស្រាវជ្រាវ ........ ២

៧ រចនាសម្ព័ន្ធស្រាវជ្រាវ ........ ៣


## ជំពូកទី១

## ការរំលឹកទ្រឹស្តី


១.១ និយមន័យ ........ ៤

១.១.១ ការអភិវឌ្ឍ ........ ៤

១.១.១.១ ការអភិវឌ្ឍជនបទ ........ ៥

១.១.១.២ វត្ថុបំណងនៃការអភិវឌ្ឍន៍ ........ ៥

១.១.២ ទ្រឹស្តីសំខាន់ៗនៃសេដ្ឋកិច្ចអភិវឌ្ឍន៍ ........ ៦

១.១.២.១ ទ្រឹស្តីដំណាក់កាលលីនេអ៊ែរ ........ ៦

១.១.២.១.១ ទ្រឹស្តីរបស់លោក Walt Withman Rostow ........ ៦

១.១.២.១.២ គំរូកំណើនរបស់លោក Harrod-Domar ........ ៨

១.១.២.២ ទ្រឹស្តីបំលាស់ប្តូររចនាសម្ព័ន្ធ ........ ៨

១.១.២.២.១ ទ្រឹស្តីអភិវឌ្ឍន៍របស់លោក W.Arthu Lewis ........ ៨

១.១.២.២.២ ការផ្លាស់ប្តូររចនាសម្ព័ន្ធ និងគំរូនៃការអភិវឌ្ឍ ........ ៩

១.១.៣ កត្តាដែលជំរុញអោយមានការអភិវឌ្ឍ ........ ១០

១.១.៤ កត្តាដែលរាំងស្ទះដល់ការអភិវឌ្ឍ ........ ១៣

១.១.៥ ផែនការយុទ្ធសាស្ត្រអនុវត្តជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ............................. ១៥
១.១.៥.១ គោលបំណងនិងគោលដៅ ............................................................................ ១៦
១.១.៥.១.១ គោលបំណង ................................................................................... ១៦
១.១.៥.១.២ គោលដៅ....................................................................................... ១៦
១.១.៥.២ គោលនយោបាយអភិវឌ្ឍន៍ជនបទ ............................................................ ១៧
១.១.៦ ទិសដៅគោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ....................................... ១៨
សន្និដ្ឋានជំពូក...................................................................................................២១

## ជំពូកទី ២

## ស្ថានភាពទូទៅ ឃុំព្រៃកវៃ ស្រុកល្វាឯម ខេត្តកណ្តាល

២.១ ស្ថានភាពជាក់ស្តែងទីតាំងភូមិសាស្ត្ររចនាសម្ព័ន្ធគ្រប់គ្រងតួនាទីភារកិច្ចសមាជិកឃុំ.......២២
២.១.១ ស្ថានភាពជាក់ស្តែងផ្ទាល់នៃឃុំព្រៃកវៃ...................................................................២២
២.១.២ ទីតាំងភូមិសាស្ត្រ ..............................................................................................២២
២.១.៣ ស្ថានភាពប្រជាជនបច្ចុប្បន្ននៃឃុំព្រៃកវៃ................................................................ ២៣
២.១.៤ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទីភារកិច្ចសមាជិកឃុំព្រៃកវៃ ........................................... ២៣
២.១.៤.១ រចនាសម្ព័ន្ធគ្រប់គ្រង ................................................................................. ២៣
២.១.៤.២ តួនាទីភារកិច្ចសមាជិកឃុំព្រៃកវៃ.....................................................................២៥
២.២ ចក្ខុវិស័យ, គោលបំណង, គោលដៅ, យុទ្ធសាស្ត្រនៃការអភិវឌ្ឍ......................................២៨
២.២.១ ចក្ខុវិស័យអភិវឌ្ឍន៍..............................................................................................២៨
២.២.២ គោលបំណងអភិវឌ្ឍន៍ ..........................................................................................២៨
២.២.៣ គោលដៅអភិវឌ្ឍន៍...............................................................................................២៩
២.២.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍ ............................................................................................២៩
២.២.៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច.......................................................................... ៣០
២.២.៤.១.១ យុទ្ធសាស្ត្រវិស័យកសិកម្ម........................................................................ ៣០
២.២.៤.១.២ យុទ្ធសាស្ត្រវិស័យធនធានទឹក................................................................... ៣០
២.២.៤.១.៣ យុទ្ធសាស្ត្រវិស័យសាធារណៈការ ............................................................. ៣០
២.២.៤.១.៤ យុទ្ធសាស្ត្រវិស័យអភិវឌ្ឍន៍ជនបទ............................................................ ៣០
២.២.៤.១.៥ យុទ្ធសាស្ត្រវិស័យពន្ធដារ.......................................................................... ៣១

២.២.៤.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច ........ ៣១
២.២.៤.២.១ យុទ្ធសាស្ត្រវិស័យអប់រំ ........ ៣១
២.២.៤.២.២ យុទ្ធសាស្ត្រវិស័យសុខាភិបាល ........ ៣១
២.២.៤.២.៣ យុទ្ធសាស្ត្រវិស័យយេនឌ័រ ........ ៣១
២.២.៤.២.៤ យុទ្ធសាស្ត្រវិស័យសាសនា ........ ៣២
២.២.៤.២.៥ យុទ្ធសាស្ត្រវិស័យសង្គមកិច្ច ........ ៣២
២.២.៤.២.៦ យុទ្ធសាស្ត្រវិស័យវប្បធម៌ ........ ៣២
២.២.៤.៣ យុទ្ធសាស្ត្រគ្រប់គ្រង ........ ៣២
២.២.៤.៣.១ យុទ្ធសាស្ត្រវិស័យជលផល ........ ៣២
២.២.៤.៣.២ យុទ្ធសាស្ត្រវិស័យបរិស្ថាន និងប្រែប្រួលអាកាសធាតុ ........ ៣២
២.២.៤.៤ យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល ........ ៣៣
២.២.៤.៤.១ យុទ្ធសាស្ត្រវិស័យការគ្រប់គ្រងរដ្ឋបាល ........ ៣៣
២.២.៤.៤.២ យុទ្ធសាស្ត្រវិស័យសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ៣៣
២.៣ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ........ ៣៤
២.៣.១ ស្ថានភាពសេដ្ឋកិច្ច ........ ៣៤
២.៣.២ ស្ថានភាពសង្គមកិច្ច ........ ៣៥
២.៣.៣ ស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ បិស្ថាន និងការប្រែប្រួលអាកាសធាតុ .. ៣៥
២.៣.៤ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ៣៦
សន្និដ្ឋានជំពូក ........ ៣៧

## ជំពូកទី ៣

## ការពិភាក្សាលើសមិទ្ធផល, បញ្ហាប្រឈម និងដំណោះស្រាយ

៣.១ វិភាគលើការអភិវឌ្ឍ និងការពិភាក្សាលើសមិទ្ធផល ........ ៣៨
៣.១.១ វិភាគលើការអភិវឌ្ឍ ........ ៣៨
៣.១.២ សមិទ្ធផលដែលមានថវិការ និងកិច្ចសន្យាគាំទ្រ ........ ៤១
៣.១.៣ សញ្ញាណសម្ខាន់ៗគួរកត់សម្គាល់នៃសមិទ្ធផលដែលទទួលបានពីក្នុងភូមិឃុំ ........ ៤៣
៣.២ ពិភាក្សាលើបញ្ហាប្រឈម ........ ៤៤
៣.២.១ បញ្ហាប្រឈមទូទៅនៅក្នុងឃុំ ........ ៤៤

៣.២.២ ស្ថិតិរងគ្រោះ និងងាយរងគ្រោះជាក់ស្តែង ........ ៤៥
៣.៣ ដំណោះស្រាយ ........ ៤៦
៣.៣.១ អប់រំ ........ ៤៦
៣.៣.២ សុខាភិបាល ........ ៤៧
៣.៣.៣ ភាពងាយរងគ្រោះ ........ ៤៧
៣.៣.៤ ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ........ ៤៨
៣.៣.៥ រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ៤៨
សន្និដ្ឋានជំពូក ........ ៥០

**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

១ សេចក្តីសន្និដ្ឋាន ........ ៥១
២ ការផ្តល់អនុសាសន៍ ........ ៥១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

១. តារាង៣.១ តារាងទិន្នន័យវិស័យអប់រំ........................................................................ ៣៩

២. តារាង៣.២ តារាងទិន្នន័យវិស័យសុខាភិបាល ................................................................. ៤០

៣. តារាង៣.៣ តារាងទិន្នន័យវិស័យធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ .. ៤១

៤. តារាង៣.៤ តារាងទិន្នន័យវិស័យរដ្ឋបាល និងសន្តិសុខសាធារណៈ.................................... ៤១

៥. តារាង៣.៥ តារាងការសាងសង់........................................................................................ ៤៥

# បញ្ជីក្រាហ្វិក

១. ក្រាហ្វិក៣.១៖ វិស័យអប់រំ................................................................................... ៣៩

២. ក្រាហ្វិក៣.២៖ វិស័យសុខាភិបាល .......................................................................... ៤០

៣. ក្រាហ្វិក៣.៣៖ វិស័យធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ .................. ៤១

៤. ក្រាហ្វិក៣.៤៖ វិស័យរដ្ឋបាល និងសន្តិសុខសាធារណៈ.................................................... ៤២

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ផែនទីខេត្តកណ្តាល នៃព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធទី២៖ ផែនទីឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល

ឧបសម្ព័ន្ធទី៣៖ សង្ខេបទិន្នន័យចម្បងនៃឃុំព្រែករៃ

ឧបសម្ព័ន្ធទី៤៖ គម្រោង សកម្មភាពមានថវិកាគាំទ្រ

ឧបសម្ព័ន្ធទី៥៖ គម្រោង សម្មភាពអាទិភាពមិនទាន់មានថវិកាគាំទ្រ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១ លំនាំបញ្ហា

វិស័យដែល ត្រូវបានគេពឹងផ្អែកយ៉ាងសម្ខាន់បំផុតនៅក្នុងប្រទេសនីមួយៗគឺវិស័យកសិកម្ម វិស័យសេវាកម្ម និងវិស័យឧស្សាហាកម្ម វាត្រូវបានរិះរកគ្រប់មធ្យោបាយដើម្បីបំពេញអោយមានការរីក ចំរើនទាំងបីផ្នែកនេះ វានឹងបណ្តាលអោយមានកំណើនសេដ្ឋកិច្ចដោយពឹងផ្អែកវិស័យទាំងបីនេះបាន។ រីឯប្រទេសកម្ពុជាវិញបើនៅក្នុងកំឡុងឆ្នាំ ២០១៧ វិញគេបានប៉ាន់ស្មានថា វិស័យកសិកម្មមានកំណើនប្រមាណជា ២.០% វិស័យសេវាកម្មវិញមានអត្រាប្រមាណជា ៦.៥% ហើយបើមើលទៅលើវិស័យឧស្សាហាកម្មវិញ គឺមានអត្រាកំណើនគួរអោយកត់សម្គាល់គឺ១០.៧%នោះ។

ទោះបីមានការចូលរួមលក្ខណៈ ទ្រង់ទ្រាយធំក៏ដោយ ប្រសិនបើយើងត្រឡប់មកមើលការអភិវឌ្ឍត្រឹម ថ្នាក់ឃុំ តាមជនបទ វិស័យទាំងបីនេះក៏ត្រូវបានគេកត់សម្គាល់ឃើញថា មានការរុញច្រានកំណើនសេដ្ឋកិច្ចផងដែរ។ ផ្ទុយទៅវិញ ទីផ្សារសេរីបានធ្វើអោយមានការប្រកួតប្រជែងខ្ពស់ដែល បណ្តាលអោយមានការប្រែប្រួល នូវបញ្ហាជាច្រើនដែល ពិបាកដល់ការផលិត និងមានការបញ្ឈប់ការផលិតជាដើមរបស់ប្រជាពលរដ្ឋ ជាពិសេសតាមតំបន់ជនបទ នៃផ្ទៃប្រទេស ដែលធ្វើអោយការរកទទួលទានចិញ្ចឹមជីវិតមានភាពរអាក់រអួល និងពុំមានការងាយស្រួល ក្នុងការប្រកបរបរក្នុងស្រុកភូមិរបស់ខ្លួន។

វាជាចំណុចដែលត្រូវការដោះស្រាយជាបន្ទាន់ ព្រោះវាបាន ជះឥទ្ធិពលអវិជ្ជមាន ទៅដល់កំណើនសេដ្ឋកិច្ច វាជាហេតុដែលបណ្តាលអោយពួកយើងខ្ញុំជ្រើសយកប្រធានបទមួយនេះឡើងដើម្បីបង្ហាញអោយឃើញពីការអភិវឌ្ឍបន្ថែម ជាគម្រោង ឬផែនការ និងការអនុវត្តជាក់ស្តែងនៅក្នុងភូមិឃុំដែលបានយកមកជូន។

## ២ ចំណោទបញ្ហា

អ្វីដែលជាការចោទសួរចំពោះប្រធានបទរបស់ពួកយើងផ្ទាល់នោះគឺមានដូចតទៅៈ

⇒ តើគម្រោងឬ ផែនការ និង ការអនុវត្តក្នុងភូមិឃុំមានដំណើរការរបៀបមិច?

⇒ តើបញ្ហាអ្វីខ្លះដែលជាបញ្ហាចម្បងក្នុងការអភិវឌ្ឍភីនិឃុំ?

⇒ តើមានចំណុចអ្វីខ្លះ ដែលជាដំណោះស្រាយដ៏មានប្រសិទ្ធភាព និងស្របតាមលទ្ធភាពដែលភូមិឃុំនោះអាចធ្វើទៅរួចដោយពុំមានភាពរអាក់រអួល?

⇒ តើដំណោះស្រាយនោះពិតជាអាចដោះស្រាយបានឬ មិនបានដោយអាស្រ័យទៅលើអ្វីខ្លះក្នុងលក្ខណ្ឌសេដ្ឋកិច្ច?

## ៣ គោលបំណងនៃការស្រាវជ្រាវ

ពួកយើងធ្វើរបាយការណ៍ស្រាវជ្រាវឡើងក្នុងប្រធានបទនេះ គឺ ព្រោះដោយចង់រុករកនូវដំណោះស្រាយ និងរបកគំហើញថ្មីដែលអាចស្រោចស្រង់ដោយមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាជាក់ស្តែងដែលកើតមានក្នុងសហគមន៍ផ្ទាល់។ ដើម្បីសម្រេចបានគោលបំណងនៃការស្រាវជ្រាវនេះ វាត្រូវបានធ្វើឡើងដោយតាមទិសដៅខាងក្រោម៖

- ✓ ការសិក្សាលើទ្រឹស្តីពាក់ព័ន្ធ
- ✓ សិក្សាពីស្ថានភាពជាក់ស្តែង
- ✓ សិក្សាពីបញ្ហាប្រឈមនានា
- ✓ រកដំណោះស្រាយលើបញ្ហានានា និងអោយជាអនុសាសន៍ដើម្បីមានការលើកស្ទួយបន្ថែមជូនភូមិឃុំនោះ។

## ៤ ទំហំ និងដែនកំណត់ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ ពួកយើងបានធ្វើការជ្រើសយក ឃុំនៅទីជនបទ មានឈ្មោះថា ឃុំព្រែកវៃ ស្រុកល្វាឯម ខេត្តកណ្តាល ក្រោមប្រធានបទ "ការអភិវឌ្ឍជនបទនៅក្នុង ឃុំព្រែកវៃ ស្រុក ល្វាឯម ខេត្តកណ្តាល" ដោយផ្តោតទៅលើ វិស័យអប់រំ សុខាភិបាល ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ចាប់ពីឆ្នាំ ២០១៣ មកដល់បច្ចុប្បន្ន។

## ៥ វិធីសាស្ត្រស្រាវជ្រាវ

ពួកយើងបានពឹងផ្អែកលើទិន្នន័យដែលទទួលបានពី៖

- ទិន្នន័យចម្បង៖ មានការសួរសំនួរមួយចំនួនទាក់ទង និងការអភិវឌ្ឍក្នុងឃុំ ដែលមានការសម្ភាសន៍ដោយ ពួកយើងផ្ទាល់ ពីមេឃុំ និងស្មានឃុំ ជាបរិមានវិស័យ និងគុណវិស័យ។
- ទិន្នន័យបន្ទាប់គឺ ឯកសាររៀបរាងរួចជាស្រេចនៃ ផែនការ និងការវិនិយោគនានា ដែលបានចែងក្នុង កិច្ចការអភិវឌ្ឍន៍ក្នុងឃុំទាំងមូល ហើយពុំទាន់បាន ធ្វើការវិភាគនៅឡើយ។ ឯកសារមានការអនុម័តតែពុំទាន់មានការវិភាគ។

## ៦ សារៈសម្ខាន់នៃការស្រាវជ្រាវ

សារៈសម្ខាន់ក្នុងការស្រាវជ្រាវចំពោះប្រធានបទខាងលើនេះរួមមានដូចតទៅ៖

- ✓ ធ្វើអោយយល់កាន់តែច្បាស់នូវដំណាក់កាលនៃ ការអភិវឌ្ឍភូមិឃុំ ពីអស្ថេរភាពនៃសុខមាលភាព របស់ សេដ្ឋកិច្ច និងប្រជាជនក្នុងភូមិឃុំ។
- ✓ ធ្វើអោយដឹងពីទិដ្ឋភាព និងសកម្មភាពភូមិឃុំដែលបានសម្រេចយកមកសិក្សាស្រាវជ្រាវ
- ✓ ធ្វើអោយដឹងពីអត្ថប្រយោជន៍នៃការអភិវឌ្ឍភូមិឃុំ
- ✓ យល់ដឹងមួយកម្រិតទៀត អំពីការអភិវឌ្ឍក្នុងភូមិឃុំ
- ✓ ឯកសារស្រាវជ្រាវមួយនេះនឹងក្លាយទៅជាទិន្នន័យដ៏សម្ខាន់ដល់និស្សិតជំនាន់ក្រោយដែលចង់សិក្សាស្រាវជ្រាវ
- ✓ ដើម្បីបញ្ចប់ការសិក្សារបស់ខ្លួនដោយជោគជ័យ

## ៧ រចនាសម្ព័ន្ធស្រាវជ្រាវ

របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាមួនេះ បានចែកចេញជាបីជំពូក មានដូចការរៀបរាប់ដូចខាងក្រោម៖

- **ជំពូកទី ១** មានដូចជានិយមន័យនៃពាក្យគន្លិះដែលមានក្នុងប្រធានបទ, សញ្ញាណផ្សេងៗ, ទ្រឹស្តីអ្នកប្រាជ្ញ, គោលនយោបាយ, ផែនការយុទ្ធសាស្ត្រ, បង្ហាញពីបទពិសធន៍ និងសន្និដ្ឋានជំពូក។
- **ជំពូកទី ២** មានដូចជា ស្ថានភាពចុះឃើញផ្ទាល់ និងទីតាំងភូមិសាស្ត្រ, ស្ថានភាពទូទៅ, ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍, លទ្ធផល បញ្ហា និង ដំណោះស្រាយឃុំផ្ទាល់ និងសន្និដ្ឋានជំពូក។
- **ជំពូកទី ៣** ធ្វើការវិភាគតារាង ក្រាហ្វិក, ការពិភាក្សាលើ សមិទ្ធផល, បញ្ហាប្រឈម និងដំណោះស្រាយ, សន្និដ្ឋាន ព្រមទាំងមានការផ្តល់អនុសាសន៍។

# ជំពូកទី១

# ការរំលឹកទ្រឹស្តី

# ជំពូកទី១
# ការរំលឹកទ្រឹស្តី

## ១.១ និយមន័យ

### ១.១.១ ការអភិវឌ្ឍ

ពាក្យអភិវឌ្ឍន៍មានអត្ថន័យផ្សេងៗគ្នាទៅតាមន័យ និងទស្សនៈ របស់អ្នកប្រាជ្ញ ដែលបានរកឃើញ និងផ្លាស់ប្តូរអត្ថន័យទៅតាមការវិវត្តពីសម័យកាលទៅ សម័យកាលមួយទៀតដោយមានលក្ខណៈប្រហាក់ប្រហែលគ្នា ប៉ុន្តែរក្សានូវទិសដៅតែមួយ។ ដោយយោងតាមអក្សរសិល្ប៍ខ្មែរ ផ្អែកលើវចនានុក្រមដែលបានចងក្រងឡើងដោយសម្តេចសង្ឃ ជួន ណាត ពាក្យ "អភិវឌ្ឍន៍" មានន័យថាសេក្តី ចំរើនក្រៃលែង ការលូតលាស់ចំរើនឡើង។[1] ដូច្នេះយោងតាមអត្ថន័យនេះយើងអាចឆ្លុះបញ្ចាំងពីដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចគឺជាចលនាវិវត្ត ឬការកែប្រែសេដ្ឋកិច្ចសង្គមអោយមានភាពជឿនលឿន ពីស្ថានភាពមួយទៅ ស្ថានភាពមួយទៀតដែលល្អប្រសើរនិងរីកចំរើនជាងមុន។

ក្នុងន័យសេដ្ឋកិច្ច ការអភិវឌ្ឍគឺទាក់ទងទៅ នឹងការកែលំអរនៅក្នុងស្ថានភាពសេដ្ឋកិច្ចរបស់មនុស្ស គុណភាពរស់នៅល្អប្រសើរជាងមុន អត្រាកំណើននៃចំណូលក្នុងម្នាក់ៗ ឬ ផលិតផលជាតិក្នុងពលរដ្ឋម្នាក់ៗ ក៏ដូចជានៅក្នុងប្រទេសទាំងមូល។ ការអភិវឌ្ឍត្រូវបានលើកឡើងក្នុងទំរង់កាត់បន្ថយនិងលុបបំបាត់នូវភាពក្រីក្រ វិសមភាពនិងនិកម្មភាពជាដើម។

ការអភិវឌ្ឍអាចស្តែងចេញតាមមាត្រដ្ឋានចំនួន៥គឺ

១. មាត្រដ្ឋានសេដ្ឋកិច្ចៈ ការអភិវឌ្ឍគឺជាកំណើនសេដ្ឋកិច្ចដែលត្រូវផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចកែលំអនិងពង្រីកប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធថាមពល ប្រព័ន្ធផ្គត់ផ្គង់ទឹក ការពង្រីកវិស័យកសិកម្ម ឧស្សាហកម្ម ទេសចរណ៍និងសេវាកម្មផ្សេងៗទៀត។

២. មាត្រដ្ឋានសង្គមៈ ការអភិវឌ្ឍជាការផ្លាស់ប្តូរផ្នែកសង្គមកិច្ចដូចជាសមធម៌និងយុត្តិធម៌តាមរយៈការកាត់បន្ថយភាពក្រីក្រដោយធ្វើយ៉ាងណាអោយគំលាតរវាងអ្នកមាន និងអ្នកក្រសមល្មមអាចទទួលយកបាន លើកតំកើននារីភេទ ជាពិសេសនោះបានធានានូវសមភាពយេនឌ័រ រវាងបុរស និងស្ត្រីក្នុងសង្គម។

៣.មាត្រដ្ឋាននយោបាយៈ ការអភិវឌ្ឍត្រូវស្ថិតនៅក្នុង បរិដ្ឋាននយោបាយសមស្របសំរាប់ជំរុញវឌ្ឍនភាពសង្គមតាមរយៈច្បាប់ និងធានានូវការគោរពសិទ្ធិមនុស្ស។

[1] ជួនណាត វចនានុក្រមខ្មែរ ភាគទី១ ទី២ ភ្នំពេញ ពុទ្ធសាសនបណ្ឌិត១៩៦៧ ទំព័រ១៦៦៦

៤.មាត្រដ្ឋានបរិស្ថាន៖ ការអភិវឌ្ឍត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌនៃការយកចិត្តទុកដាក់ថែរក្សាគុណភាពបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិអោយបានបិតថេរ។

៥. មាត្រដ្ឋានធនធានមនុស្ស៖ ការអភិវឌ្ឍផ្សារភ្ជាប់ទៅនឹងការកើនឡើងនៃផលិតភាពពលកម្ម និងកំរិតចេះដឹងនៃប្រជាជន ការផ្លាស់ប្តូរបទពិសោធន៍ និងបច្ចេកទេសការផ្តល់សេវាសុខភាពសាធារណ:និងការអប់រំសំរាប់ប្រជាជនទូទៅ។[2]

### ១.១.១.១ ការអភិវឌ្ឍជនបទ

ជនបទគឺជាទីប្រជុំដែលនៅក្រៅក្រុង ឬជាតំបន់ដាច់ស្រយាលដែលឆ្ងាយពីទីក្រុង។ ការអភិវឌ្ឍជនបទគឺជាពាក្យទូលំទូលាយ ដែលផ្តោតសំខាន់លើសកម្មភាពសំរាប់អភិវឌ្ឍន៍តំបន់នៅក្រៅប្រព័ន្ធសេដ្ឋកិច្ចទីក្រុង។ ការអភិវឌ្ឍជនបទគឺជាដំណើរការនៃការលើកកំពស់គុណភាពនៃជីវិតនិងសុខុមាលភាពសេដ្ឋកិច្ចរបស់ប្រជាជនដែលរស់នៅតំបន់ដាច់ស្រយាលនិងមានប្រជាជនតិចតួច។ ការអភិវឌ្ឍជនបទគឺជាការធ្វើអោយប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាមនុស្ស មុខរបរទាំងឡាយនៅតំបន់ដាច់ដាច់ស្រយាល ដែលគេហៅថាតំបន់ជនបទ។[3] ការអភិវឌ្ឍជនបទគឺជាបញ្ហាអន្តរវិស័យមួយយ៉ាងសំខាន់ផងដែលរាប់បញ្ចូលតាំងពីបញ្ហា ប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ការធ្វើវិមជ្ឈការ និងរហូតដល់ការបង្កើននិងការកែលំអហេដ្ឋារចនាសម្ព័ន្ធជនបទ សេវាអប់រំនិងសេវាសុខាភិបាលដល់ប្រជាជននៅជនបទ។[4] ដូចនេះការអភិវឌ្ឍជនបទគឺជាសមាសភាគមួយយ៉ាងសំខាន់ សំរាប់ប្រជាពលរដ្ឋដែលរស់នៅជនបទផ្ទាល់ហើយក៏ជាធាតុសំខាន់មួយផងដែលសំរាប់លើក កម្ពស់វិស័យកសិកម្មនិងការកាត់បន្ថយភាពក្រីក្រ។

### ១.១.១.២ វត្ថុបំណងនៃការអភិវឌ្ឍន៍

យោបាតាមទ្រឹស្តីរបស់លោក Micheal P.Todaro ដើម្បីធ្វើអោយជីវិតមានភាពប្រសើរឡើងនៅក្នុងការអភិវឌ្ឍសង្គមទាំងមូលត្រូវមានសមាសភាពជាក់លាក់នៃគោលដៅ ៣យ៉ាងគឺ

ក. ដើម្បីបង្កើនភាពដែលអាចរកបាន និងពង្រីកការចែកចាយបែងចែកទំនិញ ដែលទ្រទ្រង់ជីវិតជាមូលដ្ឋានដូចជាអាហា,ជម្រក,ស្នាក់នៅ,និងសុខភាព។

ខ. ដើម្បីលើកស្ទួយកម្រិតនៃការរស់នៅ ធ្វើអោយកើនឡើងនៃប្រាក់ចំនូល ការអប់រំល្អ ការផ្តល់ការងារនិងយកចិត្តទុកដាក់ទៅលើវប្បធម៌និងមនុស្ស ។មិនត្រឹមតែធ្វើអោយមានភាពប្រសើរឡើង

[2] សារណាបញ្ចប់ការសិក្សា,កម្មវិធីអភិវឌ្ឍន៍របស់ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ, ២០០២-២០០៦

[3] Moseley,Malcomlm J.(2003).Rural development : principles and practie,pp 5

[4] ការអភិវឌ្ឍជនបទ ព្រំទេវី , សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច,២០០៥

សំរាប់បុគ្គលម្នាក់ៗដែលទាក់ទងនឹងសុខមាលភាពប៉ុណ្ណោះទេ ថែមទាំងធ្វើអោយមានការគោរព និងអោយតម្លៃជាតិខ្លួនឯងផងដែរ។

គ. ដើម្បីជំរុញតម្លៃសេដ្ឋកិច្ច និងការជ្រើសរើសរបស់សង្គម ដែលអាចទទួលយកបានជាលក្ខណៈបុគ្គលនិងជាលក្ខណៈជាតិដោយធ្វើ អោយពួកគេមិនត្រឹមតែរួចផុតពីភាពអវិជ្ជា និងទុគិតភាពក្នុងកាតទាក់ទងទៅកាន់មនុស្សដទៃនិងមនុស្សជាតិទូទៅប៉ុណ្ណោះទេ ថែមទាំងជំរុញ អោយពួកគេរួចផុតពីអនិស្សរភាព និងសេរវគតិភាពទៀតផង។

### ១.១.២ ទ្រឹស្តីសំខាន់ៗនៃសេដ្ឋកិច្ចអភិវឌ្ឍន៍

ទ្រឹស្តីជាច្រើនត្រូវបានបង្កើតឡើងអ្នកប្រាជ្ញសេដ្ឋកិច្ចដើម្បីពន្យល់បកស្រាយអំពី ការផ្លាស់ប្តូរ ដែលកើតឡើងនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍក្នុង គោលបំណងដើម្បីសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចនិងកំណើនទាំងមូល។ ដោយយើងខ្ញុំ សូមលើកទ្រឹស្តីជាដំណាក់កាលលីនេអ៊ែរ និងទ្រឹស្តី បំលាស់ប្តូររចនាសម្ព័ន្ធមកបង្ហាញដូចតទៅៈ

#### ១.១.២.១ ទ្រឹស្តីដំណាក់កាលលីនេអ៊ែរ

នៅក្នុងគំរូទ្រឹស្តីនេះ ភាពពេញនិយមបំផុតនៃទ្រឹស្តីនេះគឺ គំរូកំណើនដំណាក់កាលរបស់លោក Walt Withman Rostow និង គំរូកំណើនរបស់លោក Harrod Domar។

##### ១.១.២.១.១ ទ្រឹស្តីរបស់លោក Walt Withman Rostow

លោក Walt Withman Rostow បានវែកញែកដំណាក់កាលសំខាន់ក្នុងការអភិវឌ្ឍជាប្រាំដំណាក់កាល ដោយលោកបានអះអាងថាគ្រប់ប្រជាជាតិទាំងអស់អាចឈានដល់កំរិតអភិវឌ្ឍន៍ ប្រសិនគេដើរតាមគន្លងប្រទេសអភិវឌ្ឍន៍ ហើយរក្សាលក្ខណៈក្នុងការធានាអោយមានកំណើនសេដ្ឋកិច្ចបានយូរអង្វែង។ ទ្រឹស្តីនេះចែកជាប្រាំដំណាក់កាលនៃការអភិវឌ្ឍជាតិរួមមានៈ

ក. សង្គមប្រពៃណី គឺជាសង្គមដែលគ្មានកំណើនទាល់តែសោះ ហើយការផលិតធ្វើឡើងតែរៀងៗខ្លួន ដូច្នេះផលដែលទទួលបានមានកំរិតទាប។ ប្រជាជនយកមុខរបរកសិកម្មជាចម្បងក្នុងការ ផលិត ហើយពួកគេមិនមានគំនិតក្នុងការផ្លាស់ប្តូរអ្វីៗទាំងអស់ គឺបណ្តោយតាមយថាកម្ម។

ខ. លក្ខណៈដែលធ្វើអោយមានការអភិវឌ្ឍ

វានឹងទៅដល់កាលណាមួយបើមានការរួមបញ្ចូល ឥទ្ធិពលពិតប្រាកដ ដែលធ្វើអោយមានផងចំណេញដល់សង្គមដែលមានការផ្លាស់ប្តូរនេះត្រូវបានដាក់ចេញមានដូចជាៈ

- ពង្រីកហេដ្ឋារចនាសម្ព័ន្ធ

- ការធ្វើអោយ ប្រសើរឡើងផ្នែកបច្ចេកវិជ្ជា (ត្រូវតែបង្ខំអោយលឿនជាពិសេសវិស័យកសិកម្ម)
- ការធ្វើអោយប្រជាជនមានភាពជាម្ចាស់កម្មសិទ្ធលើអចលនវត្ថុ ព្រមទាំងធ្វើអោយកើនឡើងនៃសន្សំវិនិយោគជាប្រទេសដែលស្ថិតនៅចន្លោះអន្តរកាលនៃការអភិវឌ្ឍ។

គ. ដំណាក់កាលនៃការកើនឡើងនៃការអភិវឌ្ឍៈ

- វិស័យអាទិភាពនៃសេដ្ឋកិច្ចបានចាប់កំណើត និងរីកធំធាត់ជាលំដាប់
- កំណើនសេដ្ឋកិច្ចបានក្លាយទៅជាបញ្ហាសាមញ្ញ
- អាចរក្សាបានស្វ័យប្រវត្តិនូវស្ថេរភាពសេដ្ឋកិច្ច។

ប្រសិនបើប្រទេសទាំងឡាយដែលមានចំនុចដូចខាងលើ គេហៅថាប្រទេសឧស្សាហកម្មថ្មីដោយពឹងផ្អែកលើ ភាពខ្លាំងនៃអត្រាវិនិយោគ អាទិភាពនៃនយោបាយ ស្ថាប័នដែលនាំអោយមានការរំកិលនៃកំណើន និងការបង្កើតឧស្សាហកម្មសំខាន់ៗ ដើម្បីជាការផ្លាស់ប្តូរ។

ឃ. ដំណាក់កាលទុំ

ការអភិវឌ្ឍបានជ្រាបទៅគ្រប់ច្រកល្ហកនៅទូទាំងប្រទេស ជាពិសេសវិស័យថ្មីៗនៃផលិតកម្មដែលបានលេចឡើងជារចនាសម្ព័ន្ធនៃ ការផលិតបានចេញពីវិស័យកសិកម្មទៅវិស័យឧស្សាហកម្ម។ ការអភិវឌ្ឍចេះតែឈានទៅមុខ ឧស្សាហកម្មដែលមានវ័យចំណាស់ ត្រូវបានផ្លាស់ប្តូរចេញអោយមានភាពកាន់តែទំនើបថែមទៀត ឬវិស័យឧស្សាហកម្មថ្មី។

ង. ដំណាក់កាលនៃបម្រើបម្រាស់ក្នុងទ្រង់ទ្រាយធំ

ការផលិតទំនិញ និងសេវាកម្មក្នុងគោលបំណងប្រើប្រាស់ចុងក្រោយ ត្រូវបានធ្វើនៅក្នុងវិស័យឧស្សាហកម្មនៃផលិតកម្មទំនិញ។ ដោយសារតែចំណូលប្រជាជនកើនឡើងបានអនុញ្ញាតដល់ការប្រើប្រាស់ក្នុងទ្រុងទ្រាយធំនៃទំនិញដែលមិនមានភាពចាំបាច់ត្រង់ចំនុចនេះបញ្ជាក់ថាៈ

- ការអភិវឌ្ឍកំពុងតែចាប់ផ្តើមដំណើរការខ្លាំង ព្រោះនៅត្រង់ចំនុចកើនធ្វើអោយ
- សេចក្តីត្រូវការជាមូលដ្ឋានត្រូវបានដោះស្រាយជាស្ថាពរ
- មានការអភិវឌ្ឍវិស័យសុខុមាលភាពសង្គម -អំណាចសេដ្ឋកិច្ចត្រូវបានពង្រីក។

ដូច្នេះលោក បានយកចិត្តទុកដាក់ខ្លាំង នៃការរីកសាយភាយ នៃគ្រឿងយន្តដែលមានតម្លៃថោកដែលធ្វើអោយមានឥទ្ធិពលដល់ ជីវិតនៃសង្គម ការបែងចែកប្រាក់ចំណូលថ្មី និងបង្កើតប្រព័ន្ធគ្រោងទុកនៃសង្គម។

**១.១.២.១.២ គំរូកំណើនរបស់លោក** Harrod-Domar

គំរូកំណើនរបស់លោកHarrod-Domar បានយកចិត្តទុកដាក់ជាសំខាន់ទៅលើការសន្សំ ដោយគ្រប់សេដ្ឋកិច្ចត្រូវតែមានសមាមាត្រពិតប្រាកដ និងចំណូលជាតិ ក្នុងករណីដែលមានការប្តូរទំនិញ មូលធនដែលហួសសម័យ ឬការរំលស់ដូចជា អាគារ គ្រឿងបរិក្ខារ និងសំភារៈផ្សេងៗទៀត។

ដើម្បីអោយមានកំណើនសេដ្ឋកិច្ចគឺត្រូវមានការវិនិយោគថ្មីសុទ្ធតែបន្ថែមទៅលើស្តុបមូលធន។ គំរូរបស់លោកបានបង្ហាញពីកំណើនសេដ្ឋកិច្ចដែលមាន៖

-ទំនាក់ទំនងរវាងការសន្សំ និងចំនូលជាតិ

-ទំនាក់ទំនងរវាងការវិនិយោគ និងបំរែបំរួលស្តុបមូលធន

-សន្សំជាតិសរុបស្មើនឹងវិនិយោគសរុប

តាមមតិសេដ្ឋកិច្ចវិទូ គន្លឹះនៃការអភិវឌ្ឍគឺស្ថិតនៅលើការចេះកៀងគរធនធានក្នុងស្រុង និងក្រៅស្រុកសំរាប់យកមកវិនិយោគ។ តាមអត្ថន័យនេះដើម្បីទទួលបានការអភិវឌ្ឍ ប្រព័ន្ធសេដ្ឋកិច្ចត្រូវការនូវការសន្សំ និងការវិនិយោគ តាមសមាមាត្រមួយកំណត់ធៀបទៅនឹង GDP និងGNP។ តាមកំរិតនៃការសន្សំ និងការវិនិយោគកាន់តែខ្ពស់ នោះអត្រាកំណើនក៏កាន់តែខ្ពស់ដែរ ហើយអត្រាកំណើនកាន់តែខ្ពស់ មានន័យថាការអភិវឌ្ឍក៏កើនឡើងទៅតាមនឹងដែរ។

**១.១.២.២ ទ្រឹស្តីបំលាស់ប្តូររចនាសម្ព័ន្ធ**

ទ្រឹស្តីនេះបានពន្យល់អំពីយន្តការនៃការផ្លាស់ប្តូររចនាសម្ព័ន្ធ នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើវិស័យកសិកម្មប្រពៃណីទៅវិស័យឧស្សាហកម្មនិងសេវាកម្មទំនើប។ ក្នុងទ្រឹស្តីនេះមានសេដ្ឋកិច្ចវិទូពីររូបបានបង្ហាញគឺ៖

**១.១.២.២.១ ទ្រឹស្តីអភិវឌ្ឍន៍របស់លោក** W.Arthu Lewis

នៅក្នុងគំរូរបស់លោក Lewis ទ្រឹស្តីនៃការអភិវឌ្ឍសេដ្ឋកិច្ចគឺជាទ្រឹស្តីនៃការផ្លាស់ប្តូររចនាសម្ព័ន្ធ។ គំរូនេះបានក្លាយជាទ្រឹស្តីទូទៅនៃដំណើរការអភិវឌ្ឍន៍សម្រាប់ប្រទេសតតីយលោកនៃភាពលើសកម្លាំងពលកម្មនៅក្នុងអំឡុងទសវត្ស1960 និងដើមទសវត្ស 1970។ ដែលគំរូ Lewis សេដ្ឋកិច្ចអភិវឌ្ឍន៍មានពីរវិស័យគឺ៖

១.វិស័យប្រពៃណី: វិស័យនេះគឺជាវិស័យគ្រាន់តែចិញ្ចឹមជីវិតនៅជនបទដោយប្រើប្រាស់ពលកម្មលើសដែលផលិតភាពពលកម្មសូន្យ (Zero Marginal Labor Productivity)។ ដោយសារតែគ្មានផលិតភាពទាបនៃកម្លាំង ពលកម្មវាអាចទៅរួចដើម្បីដក កម្លាំងពលកម្មពីវិស័យនេះដោយមិន

ប៉ះពាល់ដល់កម្រិតនៃទិន្នផល។ នេះគឺជា មូលហេតុដែលអនុញ្ញាតអោយលោក Lewis ចាត់ចំណាត់ថ្នាក់ដូចជាភាពលើសនៃកម្លាំងពលកម្ម ក្នុងអត្ថន័យថាកម្លាំងពលកម្មលើស ទាំងនោះអាចត្រូវបានដកចេញពី វិស័យកសិកម្មទៅវិស័យឧស្សាហកម្ម ដោយគ្មានការបាត់បង់នូវកសិផលឡើយ។

២. វិស័យទំនើប គឺជាវិស័យឧស្សាហកម្មទំនើបនៅក្នុងទីក្រុងដែលប្រើប្រាស់ផលិតភាពខ្ពស់ ដែលត្រូវបានគេបញ្ចូលនូវពលកម្មលើសពីវិស័យកសិកម្ម។ កត្តាចម្បងនៃគំរូនេះគឺជាដំណើរការនៃការផ្ទេរពលកម្មពីវិស័យប្រពៃណីទៅវិស័យទំនើប ត្រូវបានធ្វើជាបុព្វហេតុដោយការកើនឡើងនៃផលិតផល និងបង្កើនពលកម្មក្នុងវិស័យទំនើប។ ជាមួយនឹងល្បឿននៃការពង្រីកនេះបាននាំមកនូវអត្រាវិនិយោគឧស្សាហកម្ម និងការកើនឡើងនូវមូលធននៅក្នុងវិស័យទំនើប។វិនិយោគបែបនេះត្រូវបានបង្កើតឡើងតាមលទ្ធភាពដែលអាចធ្វើទៅរួចដោយភាពលើសនៃប្រាក់ចំណេញ ក្នុងវិស័យទំនើបលើប្រាក់ឈ្នួលពលកម្ម តាមរយៈម្ចាស់ដើមទុនទាំងនោះបានពង្រីកការវិនិយោគជាមួយនឹងប្រាក់ចំណេញរបស់ពួកគេ។ លទ្ធផលកំរិតនៃប្រាក់ចំណូលនៅក្នុងវិស័យឧស្សាហកម្មទីក្រុងត្រូវបានសន្មតថាថេរ នឹងត្រូវបានកំណត់បន្ថែមទៅលើកំរិតរស់នៅជាមធ្យមថេរ នៅក្នុងវិស័យកសិកម្ម។

### ១.១.២.២.២ ការផ្លាស់ប្តូររចនាសម្ព័ន្ធ និងគំរូនៃការអភិវឌ្ឍ

គំរូនេះបាននិពន្ធឡើងដោយលោក Hollis B.Cheneryដែលការវិភាគគំរូអភិវឌ្ឍន៍នៃការផ្លាស់ប្តូររចនាសម្ព័ន្ធផ្តោតទៅលើដំណើរការជាបន្តបន្ទាប់តាមរយៈរចនាសម្ព័ន្ធស្ថាប័នឧស្សាហកម្មនិងសេដ្ឋកិច្ចរបស់សេដ្ឋកិច្ចឱនភាវឌ្ឍន៍ទៅបានផ្លាស់ប្តូរឆ្លងកាត់ពេលវេលា ដើម្បីអនុញ្ញាតអោយឧស្សាហកម្មថ្មីចូលមកជំនួសកសិកម្មប្រពៃណីដូចក្បាលម៉ាសននៃកំណើន។ ទោះបីយ៉ាងណាក៏ដោយគំរូនេះ ខុសពីគំរូរបស់លោក Lewis ត្រង់ថាការកើនឡើងនៃការសន្សំ និងវិនិយោគពុំអាចបង្កើតជាលក្ខខណ្ឌគ្រប់គ្រាន់អោយមានកំណើនសេដ្ឋកិច្ចនោះឡើយ។ លោក Hollis B.Chenery បានបង្គ្រប់បន្ថែមទៅលើលក្ខខណ្ឌទាំងនោះគឺ ការប្រមូលមូលធន (ទាំងមូលធនរូប និងមូលធនបញ្ញា ) និង សេរីភាពនៃការផ្លាស់ប្តូរ អន្តរទំនាក់ទំនងនៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច។ ការបង្កើតនៃផ្លាស់ប្តូរអន្តរជាតិនៃការទំនាក់ទំនងនៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចនៃប្រទេស ដែលតម្រូវអោយមានការផ្លាស់ប្តូរពីប្រព័ន្ធសេដ្ឋកិច្ចប្រពៃណីអោយទៅជាប្រព័ន្ធសេដ្ឋកិច្ចទំនើបមួយ។ ការផ្លាស់ប្តូររចនាសម្ព័ន្ធទាំងនេះជាក់ស្តែងទាក់ទងជាមួយនឹងតួនាទីសេដ្ឋកិច្ចទាំងអស់ដែលរួមបញ្ចូលទាងការផ្លាស់ប្តូរនៃផលិតកម្ម និងការប្រែប្រួលក្នុងសមាសភាពនៃតម្រូវការអ្នកប្រើប្រាស់ពាណិជ្ជកម្មអន្តរជាតិ

និងការប្រើប្រាស់ធនធានរួមទាំងការផ្លាស់ប្តូរនៅក្នុងសង្គមកិច្ចដូចជា ការធ្វើទីក្រុងរូបនីយកម្ម ការធ្វើអោយមានកំណើន និងការបែងចែកទៅអោយប្រជាជននៅតាមជនបទ ដោយអោយពួកគេគិតថា ការអភិវឌ្ឍសេដ្ឋកិច្ចគឺសំរាប់ប្រទេសយើងទាំងអស់គ្នា។ ការវិភាគនៃការផ្លាស់ប្តូរចនាសម្ព័ន្ធនេះ បានសង្កត់ធ្ងន់ទៅលើកំហិតក្នុងស្រុក និងកំហិតអន្តរជាតិទៅលើការអភិវឌ្ឍ៖

-កំហិតក្នុងស្រុក: រួមបញ្ចូលកំហិតសេដ្ឋកិច្ចដូចជា ប្រភពធនធាន ទំហំប្រជាជន និងលក្ខខណ្ឌធម្មជាតិ រួមទាំងកំហិតស្ថាប័នដូចជាគោលដៅនិងនយោបាយរបស់រដ្ឋា ភិបាលក្នុងការធ្វើអោយមានការអភិវឌ្ឍ។

-កំហិតអន្តរជាតិ: រួមមានការទទួលយកធនធាន បច្ចេកទេសពីខាងក្រៅ និងពាណិជ្ជកម្មអន្តរជាតិ។

ភាពខុសគ្នា នៃកំហិតអភិវឌ្ឍន៍ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានគេសំអាងទៅលើកំហិតក្នុងស្រុក និងអន្តរជាតិទាំងនោះដែរ។ យ៉ាងណាមិញកំហិតអន្តរជាតិបង្កើតការផ្លាស់ប្តូរប្រទេសកំពុងអភិវឌ្ឍបានទទួលយកនូវការបង្ហាញឱកាសពីប្រទេសរីកចំរើន ដូចជាប្រភពមូលធន បច្ចេកទេស និងការនាំចូលផលិតផលព្រមទាំងទីផ្សារសំរាប់ការនាំចេញផងដែរ។

ជារួមទ្រឹស្តីនេះគឺទទួលស្គាល់ភាពពិតផងដែរនូវតួនាទី ដ៏សំខាន់នៃកត្តាអន្តរជាតិនៅក្នុងការជួយជំរុញដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ១.១.៣ កត្តាដែលជំរុញអោយមានការអភិវឌ្ឍ

យោងតាម អ្នកសេដ្ឋវិទូបានកំណត់ថា ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចអោយរីកចំរើនមិនថាប្រទេស អ្នកមានឬអ្នកក្រ គឺត្រូវមានកត្តា ៤យ៉ាងសំខាន់គឺ

ក.កត្តាធនធានធម្មជាតិ

ធនធានធម្មជាតិគឺជាធនធានដែលកើតឡើងដោយឯកឯង ដែលមានប្រភពមកពីលើអាកាស លើដី ក្រោមដី និងក្នុងទឹកជាដើម។

ធនធានធម្មជាតិជាធាតុផ្សំសំខាន់ៗ នៃប្រព័ន្ធអេកូឡូស៊ី ដែលផ្តល់ជាទ្រព្យសម្បត្តិនិងសេវាកម្មក្នុងការប្រើប្រាស់ដើម្បីបំពេញសេចក្តីត្រូវការដល់គ្រប់សភាវៈដែលមានជីវិតទាំងអស់ រួមទាំងការចិញ្ចឹមជីវិតរស់នៅរបស់មនុស្សជាតិផងដែរ។

ធនធានធម្មជាតិជាធនធានដែលមាន សារៈសំខាន់បំផុតក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងឧស្សាហកម្មដែលត្រូវបានគេទាញយកមកកែច្នៃ ដើម្បីផលិតនូវផលិតផលសម្រេចនានាដែលជះឥទ្ធិពលដល់ការផ្លាស់ប្តូររបស់មនុស្ស និង សំភារៈ។ល។

នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍គេប្រើធនធាន ទាំងនេះ ដើម្បីទ្រទ្រង់ជីវភាពក៏ដូចជាធ្វើអោយប្រសើរឡើងនូវគុណភាពរស់នៅ ហើយធនធានដែលមានតំលៃជាងគេគឺ ដីដែលអាចដាំដុះបាន ព្រោះភាគច្រើននៃប្រជាជនដែលរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍប្រកបរបរស្រែ ចំការដែលអាស្រ័យដោយផ្ទាល់ទៅលើដី។

ខ. ធនធានមនុស្ស

អ្នកសេដ្ឋកិច្ចបានយល់ឃើញ ថាធនធានមនុស្សគឺជាអ្នកកំណត់នូវអត្តចរិកលក្ខណៈសេដ្ឋកិច្ចសង្គមវប្បធម៌របស់ប្រទេសមួយ ដើម្បីឈានទៅរកការអភិវឌ្ឍផងដែរ។ ធនធានមនុស្សជាមនុស្សដែលពេញលេញបរិបូណ៌ដោយចំណេះដឹង និងការបណ្តុះបណ្តាលជាប្រភពសំរាប់កសាងប្រទេសជាតិ។ យ៉ាងណាមិញលោកសាស្ត្រាចារ្យ Fredirick Harbison ដែលបង្រៀននៅសាកលវិទ្យាល័យPrincetion បានអះអាងថាធនធានមនុស្សគឺជាមូលដ្ឋានកំណត់ យ៉ាងខ្ពស់បំផុតនូវ ទ្រព្យសម្បត្តិរបស់ជាតិមួយ មនុស្សរស់នៅត្រូវតែសកម្មក្នុងការអភិវឌ្ឍ ដូចជាការបង្កទុន ការទាញយកផលប្រយោជន៍ពីធនធានធម្មជាតិ ការថែរក្សាធនធានធម្មជាតិ កសាងសង្គម សេដ្ឋកិច្ច និងនយោបាយ។ ជាការពិតណាស់ថាប្រទេសមួយដែលមិនអាចបង្កើតជំនាញ និងចំនេះដឹងដល់ប្រជាពលរដ្ឋរបស់ខ្លួន និងមិនអាចប្រើប្រាស់ពន្ធគយអោយមានប្រសិទ្ធភាពក្នុងសេដ្ឋកិច្ចជាតិ នោះវាមិនអាចអភិវឌ្ឍន៍បានឡើយ។ ធនធានមនុស្សមានតួនាទីសំខាន់ណាស់ក្នុងការអភិវឌ្ឍដែលស្ថិតក្នុងគោលបំណងដើម្បីមនុស្សនិងសង្គមមនុស្ស។ ការអភិវឌ្ឍបានបង្ហាញអោយឃើញ យ៉ាងច្បាស់ថាប្រទេសជាតិនីមួយៗអាចរីកចំរើនទៅមុខបានគឺ អាស្រ័យដោយធនធានមនុស្សដើរតួយ៉ាងសំខាន់ក្នុងការបំពេញរាល់សកម្មភាពទាំងនោះ ដែលមានសមត្ថភាពឬមនុស្សដែលមានគុណភាពពោលគឺប្រជាពលរដ្ឋសកម្មព្រោះថាមនុស្សជាកត្តាផលិតកម្មដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចតាមរយៈវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងសេវាកម្មផ្សេងៗក្នុងការអភិវឌ្ឍប្រទេសជាតិទាំងមូល។

គ. កត្តាមូលធន

អ្នកសេដ្ឋវិទូបាននិយាយថា ដំណើរការដំបូងនៅក្នុងការអភិវឌ្ឍន៍ គឺបង្កើតអោយមានមូនធនតាមរយៈការសន្សំនិងការវិនិយោគ។ មូលធនគឺជាកត្តាដ៏សំខាន់បំផុតនៅក្នុងដំណើរការអភិវឌ្ឍក៏ដូចជាកំណើនសេដ្ឋកិច្ចដោយសារមូលធនជាប្រភព ដែលនាំអោយមានកត្តាផលិតកម្មឧបករណ៍សំរាប់ ដោះដូរទំនិញនិងជាប្រភព នៃតម្រូវការចាំបាច់មួយសំរាប់មនុស្ស ដែលធ្វើអោយមានភាពប្រសើរឡើងនៃប្រាក់ចំនូលនិងគុណភាពរស់នៅរបស់មនុស្សដើម្បីអភិវឌ្ឍន៍។ ការកើនឡើងនៃមូលធនចេញជាលទ្ធផលនៅពេលដែលសមាមាត្រ នៃចំណូលបច្ចុប្បន្នត្រូវបានសន្សំ និង

វិនិយោគធ្វើអោយកើនឡើងនូវទិន្នផល និងប្រាប់ចំណូលនៅពេលអនាគត។ នៅពេលដែលការវិនិយោគលើមូលធនកើនឡើង នោះផលិតកម្មការងារក៏កើនឡើងផងដែល។ ការវិនិ យោគផ្ទាល់ទាំងនេះគឺត្រូវបានបន្ថែមដោយការវិនិយោគទៅលើអ្វីដែល ត្រូវបានគេស្គាល់នៅក្នុងហេដ្ឋានរចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមដូចជា ផ្លូវថ្នល់ អគ្គីសនី ទឹកស្អាត ការទាក់ទងសម្របសម្រួលគ្នាក្នុងសកម្មភាព សមាហរណកម្មសេដ្ឋកិច្ច។

ឃ. កត្តាបច្ចេកវិទ្យា

បច្ចេកវិទ្យាអាចចាត់ទុកថាជា ប្រភពចម្បងនៅក្នុង ការធ្វើអោយមានកំណើនសេដ្ឋកិច្ច ហើយការផ្លាស់ប្តូរបច្ចេកវិទ្យារួមចំណែកយ៉ាងខ្លាំងក្នុងការអភិវឌ្ឍប្រទេសកំពុងអភិវឌ្ឍ។ បច្ចេកវិទ្យានាំអោយមានការបម្រែបម្រួលក្នុង ដំណើរការផលិតកម្មដែល គេអាចផលិតផលិតផលបានច្រើន គុណភាពល្អជាងមុននិងសន្សំពលកម្ម ព្រមទាំងសន្សំមូលធនគឺជាអ្វីដែលគេត្រូវការបំផុត។ ការបំរែបំរួលបច្ចេកវិទ្យាគឺជា ការរកដំណើរការនៃ ការកែលំអរគុណភាពក្នុងទ្រង់ទ្រាយតូចទៅទ្រង់ទ្រាយធំជាបន្តបន្ទាប់ដែលទាមទារអោយមានការជំរុញនិងការអភិវឌ្ឍសេដ្ឋកិច្ច។

ប្រភពនៃបច្ចេកវិទ្យាកំពុងអភិវឌ្ឍន៍គឺ ការទិញបច្ចេកវិទ្យាពីប្រទេសរីកចម្រើនដោយប្តូរជាមួយទំនិញនាំចេញរបស់ខ្លួន។ ដូច្នេះបច្ចេកវិទ្យាសំខាន់ណាស់សំរាប់ធានានូវកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង ដែលមានការចាត់ថ្នាក់ជាមូលដ្ឋាន បី គឺ៖

- កំណើនបច្ចេកវិទ្យាអព្យាក្រឹត្យ៖ កើតឡើងនៅពេលផលិតផលខ្ពស់ត្រូវបានសម្រេចនៅបរិមាណដូចគ្នាពីការផ្សំនៃកត្តាផលិតកម្ម ។
- កំណើនបច្ចេកវិទ្យាតាមរយៈការសន្សំពលកម្ម កើនឡើងនៅពេលកម្រិតនៃផលិតផលកើនឡើងជាមួយនឹងបរិមាណនៃកត្តាពលកម្មដដែលនោះ ។តួយ៉ាងកុំព្យូទ័រ អគ្គិសនី កីត្បាញស្វ័យប្រវត្ត ត្រាក់ទ័រ ម៉ាស៊ីនច្រូតស្រូវ និងឧបករណ៍ទំនើបផ្សេងៗទៀត បានចាត់ទុកជាការសន្សំពលកម្ម ។
- កំណើនបច្ចេកវិទ្យាតាមរយៈការសន្សំមូលធន៖ គឺជាការកើនឡើងនៅកម្រិតបរិមាណផលិតផលជាមួយបរិមានកត្តាមូលធនដដែល។ ការរីកចម្រើនបច្ចេកវិទ្យានេះកើតមានតាមរយៈការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រ របបគំហើញនូវឧបករណ៍ថ្មីៗសម្រាប់ប្រើប្រាស់ក្នុងដំណើរការផលិតកម្មគឺការសន្សំមូលធន។

ង. កត្តារចនាសម្ព័ន្ធ

ក្រៅពីកត្តាធនធានធម្មជាតិ មនុស្ស មូលធន ដែលបានបរិយាយខាងលើ កត្តារចនាសម្ព័ន្ធក៏ជាកត្តាសំខាន់មួយក្នុងការកំណត់ទិសដៅ និងខ្សែបន្ទាត់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។ នៅក្នុងការអភិវឌ្ឍគឺត្រូវមាននូវរចនាសម្ព័ន្ធពិតប្រាកដមួយដូចជា រចនាសម្ព័ន្ធនយោបាយ រចនាសម្ព័ន្ធច្បាប់ រចនាសម្ព័ន្ធសង្គម និងរចនាសម្ព័ន្ធសេដ្ឋកិច្ច។ល។ ស្តែងចេញពីរចនាសម្ព័ន្ធទាំងនេះ គឺជាស្នូលនៃមូលដ្ឋានគ្រឹះដ៏ សំខាន់មួយក្នុងការអភិវឌ្ឍប្រទេសជាតិពោរពេញដោយស្ថេរភាពសង្គម និងសន្តិភាព នយោបាយ។

* ដោយការរួមបញ្ចូលនូវកត្តាទាំងនេះគឺមានទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងល្អ នោះទើបធ្វើអោយសេដ្ឋកិច្ចមានការអភិវឌ្ឍប្រកបដោយនិរន្តភាព។

### **១.១.៤ កត្តាដែលរាំងស្ទះដល់ការអភិវឌ្ឍ**

ការអភិវឌ្ឍជាទូទៅពុំអាចធ្វើអោយស្មើគ្នាគ្រប់តំបន់ឡើយ ជាពិសេសក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ដែលងាយរងគ្រោះ និងជួបឧបសគ្គមួយចំនួនដូចជា៖

ក. កំណើនប្រជាជន

កំណើនប្រជាជននៅតែជាបញ្ហាចម្បងសំរាប់ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ដែលអត្រាកំណើនប្រជាជនបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាហេតុធ្វើអោយរាំងស្ទះដល់ការអភិឌ្ឍ។ ចំពោះការកើនឡើងចំនួនប្រជាជនធ្វើ អោយមានការកើនឡើងនូវតម្រូវការប្រើប្រាស់ សំភារៈទាញយកធនធានជាច្រើនដែលជាហេតុធ្វើអោយជះឥទ្ធិពលដល់ការសន្សំ ចំណូល និងការផ្គត់ផ្គង់មិនទាន់តម្រូវការប្រើប្រាស់គ្រប់គ្រាន់សំរាប់ជីវភាពរបស់ពួកគេឡើយ។ ទំហំគ្រួសារកាន់តែធំ ការចំណាយកាន់តែច្រើន កាត់បន្ថយនូវសមត្ថភាពរបស់សមាជិកក្នុងការសន្សំ ដោយដាក់កំហិតលើសេដ្ឋកិច្ចគ្រួសារ បង្កើតអោយមានភាពខ្វះខាតនិងក្រីក្រ។

ជាមួយគ្នានោះធ្វើអោយមានចលនាចាកចេញ ពីស្រុកកំណើតទៅកាន់ទីក្រុងឬទីប្រជុំជនកើនឡើង ដែលជាជះឥទ្ធិពលដល់បរិស្ថានទីក្រុងដូចជា មនុស្សណែនតាន់នៅទីក្រុង ការរស់នៅគ្មាន ផាសុខភាព បរិស្ថានកខ្វក់ សេវាសាធារណៈទន់ខ្សោយ កើននូវបទឧក្រិដ្ឋ អំពើឆក់ប្លន់ -ល- ដែលសុទ្ធតែជាបញ្ហាអាក្រក់បង្កើតចេញពីកំណើនប្រជាជន។ នៅពេលដែលកំណើនប្រជាជនកើន គេចាំបាច់បង្កើនអោយមានការវិនិយោគផងដែរ ដើម្បីរក្សានូវមូលធនពិតសំរាប់មនុស្សម្នាក់។ បើការវិនិ យោគពុំមានល្បឿនលឿន នោះកម្មករ និងសំភារៈបរិក្ខា ឧបករណ៍ប្រើប្រាស់

កាន់តែតិច នាំអោយផលិតភាពអ្នកធ្វើការកាន់តែថយចុះជាចំនូលរបស់មនុស្សម្នាក់ក៏កាន់តែថយចុះដែរ។

ខ. ការអប់រំមានកំរិតទាប

ជាការពិតណាស់នៅក្នុងសង្គម ការអប់រំក៏ត្រូវបានផ្សារភ្ជាប់ទៅនឹង សេដ្ឋកិច្ច គឺ សេដ្ឋកិច្ចសង្គម និងសេដ្ឋកិច្ចគ្រួសារ។ សេដ្ឋកិច្ច គឺជាកត្តាមួយដែលសំខាន់នៅក្នុងការជំរុញដំណើរការនៃការអប់រំ ប្រព្រឹត្តទៅបានយ៉ាងរលូន និងជោគជ័យ។ ដោយសារតែប្រទេសដែលកំពុងអភិវឌ្ឍន៍គឺជាប្រទេសដែលទើបតែងើបចេញពីភាពក្រីក្រ ដូច្នេះសក្តានុពលសេដ្ឋកិច្ច នៅមានកំរិតនៅឡើយ ជាហេតុជះ ឥទ្ធិពលដល់ប្រជាជនដែលមានបញ្ហាសេដ្ឋកិច្ចគ្រួសារ ពុំមានលទ្ធភាពដើម្បីផ្គត់ផ្គង់ដល់ការរៀនសូត្រ របស់កុមារ។

ទោះបីជារដ្ឋាភិបាលបានខិតខំយកចិត្តទុកដាក់ ជំរុញ និង លើកទឹកចិត្តឲប្រជាពលរដ្ឋបញ្ជូលកូនទៅសាលាដោយពុំចាំបាច់បង់ប្រាក់ក៏ដោយ ប៉ុន្តែសំរាប់គ្រួសារដែលមានសេដ្ឋកិច្ចទន់ខ្សោយ ពួកគាត់ពិតជាគ្មានលទ្ធផលភាពគ្រប់គ្រាន់សំរាប់ជួយដល់ការសិក្សារបស់កូនឡើយ ព្រោះពួកគាត់ត្រូវការចំណាយទៅសំភារៈមួយចំនួនដូចជា មធ្យោបាយធ្វើដំណើរ សំលៀកបំពាក់សំភារៈសិក្សា និងឯកសារសំរាប់រៀនសូត្រជាច្រើនទៀត។ម្យ៉ាងទៀតក្នុងករណី កុមារវ័យក្មេងជាច្រើនត្រូវបង្ខំចិត្តឈប់រៀនពាក់ កណ្តាលទីដើម្បីជួយសម្រួលសេដ្ឋកិច្ចគ្រួសាររបស់ខ្លួន ដូច្នេះប្រជាពលរដ្ឋភាគច្រើនមិនមានជំនាញមូលដ្ឋានដែលចាំបាច់សំរាប់ឡើងដល់កំរិតអប់រំខ្ពស់នៅពេលផ្តល់អោយឡើយ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនប្រឈម នឹងបញ្ហាអត្រាអនក្ខរជនច្រើនជាពិសេសនៅតាមជនបទ ចំណែកឯទីក្រុងមានអនក្ខរជនតិចតួច ដែលជាវិបត្តិមួយក្នុងការអភិវឌ្ឍ។ដោយសារតែការអប់រំជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការបង្កើនធនធានមនុស្ស អោយឆ្ពោះទៅការអភិវឌ្ឍប្រទេសជាតិទាំងមូល។

ឃ. និកម្មភាព

បញ្ហានិកម្មភាពគឺជាបញ្ហាមួយដែល គួរអោយព្រួយបារម្ភខ្លាំងសំរាប់សកលលោក ជាពិសេសប្រទេសកំពុងកំពុងអភិវឌ្ឍន៍ តាមការអង្កេតជាក់ស្តែងចំនួននៃនិកម្មភាពមានចំនួនខ្ពស់ដែលមនុស្សជាច្រើនមិនអាចរកការងាបាន ដោយទីផ្សារការងារមិនទាន់មានភាពសំបូរបែប ធ្វើអោយប្រជាជនធ្វើការផ្លាស់ទីលំនៅជាច្រើនពីជនបទមកទីក្រុង ដោយពួកគេរំពឹងថានឹងរកការងារដែលមានប្រាក់បៀវត្សខ្ពស់ជាងប្រាក់ដែលបានធ្វើរបរកសិកម្ម។ ការផ្លាស់ប្តូទីលំនៅ បានកើនឡើងយ៉ាងសម្បើមលើសពីកំណើននៃឱកាស ការងារនៅទីក្រុងនេះបណ្តាលមកពីនិកម្មភាពខ្ពស់

និងការបែងចែកពុំស្មើគ្នាក្នុងការ ផ្តល់ឱកាសការងាររវាងទីក្រុងនិងជនបទ។ បើយោងតាមការវិភាគមួយក្នុងវេបសាយ Wikipedia ដើម្បីទទួលបានផលចំណេញពី សេដ្ឋកិច្ចត្រឹមតែ២/៣ប៉ុណ្ណោះ នៅពេលដែលសេដ្ឋកិច្ចធ្លាក់ចុះរាល់ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ បើធ្វើការប្រមូលផ្តុំគ្នាច្រើនទៅគឺក្លាយជាចលកររារាំងការរីកចម្រើនរបស់សង្គម។ ការខ្វះទីជំរកនឹងកើតមានឡើងនៅពេលដែលមាននិកម្មភាព ភាពក្រក្រក៏កើតឡើងជាបន្តបន្ទាប់ ដែលអាចបង្កជងលំបាកដល់រដ្ឋាភិបាលក៏ដូចជាប្រទេសជាតិទាំងមូល។ ក្នុងនោះដែលពេល និកម្មភាព កើតឡើងអំពើចលាចលផ្សេងៗដូចជា ពេស្យាចារ ល្បែងសីសង ការលួចឆក់ ប្លន់ និងបញ្ហាផ្សេងៗជាច្រើននឹងចោទមានដែរ។ រាល់បញ្ហានេះសុទ្ធតែកើតឡើងដោយសារនិកម្មភាព ហើយបញ្ហាផងដែរនឹងបណ្តោយអោយមានភាពរាំងស្ទះដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច រួមទាំងបង្កអោយមានភាពអសន្តិសុខ ដល់សង្គម និងប្រទេសទៀតផង។

ង. កត្តានយោបាយ

ជាការពិតណាស់ប្រទេសមួយអាចអភិវឌ្ឍន៍ឬអត់ គឺអាស្រ័យលើស្ថានភាពនយោបាយរបស់ប្រទេសនោះមានស្ថានភាពដូចម្តេច? ប្រសិនបើប្រទេសនោះ ស្ថិតនៅក្នុងអសន្តិភាពនយោបាយ អសន្តិសុខ ប្រឈមមុខនិងភាពអនាធិបតេយ្យចលាចល ឬមួយច្បាប់ប្រទេសស្ថិតក្នុងសភាពទន់ជ្រាយ ដែលមិនអាចធានាសន្តិសុខ និងយុត្តិធម៌ជូនប្រជាពលរដ្ឋបាន នេះជាបញ្ហាដ៏ធំមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងប្រទេសជាតិទាំងមូល។ ឬក៏ស្ថិតក្នុងស្ថានភាពមួយទៀតគឺសង្គ្រាម នោះនឹងទទួលបាននូវការខាតបង់យ៉ាងធំធេង។ ផលប៉ះពាល់ទាំងនេះគឺការបាត់បង់នូវទំនុបចិត្តពីបណ្តាប្រទេសនានាក្នុងការចូលមកវិនិយោគ ឬផ្តល់ជាជំនួយជាដើម។ ហេតុតែគ្មានទំនុបចិត្តមិនថាតែត្រៀមវិនិយោគប៉ុណ្ណោះទេ សូម្បីតែវិនិយោគរួចហើយក៏អាចបាត់បង់ទៅវិញដែរ។ នោះនិងធ្វើអោយប្រជាជនក៏ដូចជាប្រជាជាតិទាំងមូលបាត់បង់នូវចំណូល និងបញ្ហាផ្សេងៗទៀត ដែលរាំងស្ទះដល់ការអភិវឌ្ឍន៍ប្រទេសជាតិ។

### **១.១.១.៥ ផែនការយុទ្ធសាស្ត្រអនុវត្តជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ**[5]

យុទ្ធសាស្ត្រនៃការអភិវឌ្ឍជា យុទ្ធសាស្ត្រដល់ត្រូវបានគេយកទៅអនុវត្តន៍នៅទសវត្សកន្លងមកដោយទទួលបានការរីកចំរើនផ្នែកសេដ្ឋកិច្ច ព្រោះលទ្ធផលនៃការអភិវឌ្ឍន៍បង្កើតអោយមានវិសមភាពរវាងអ្នកក្រ និងអ្នកមាន រវាងទីក្រុងនិងជនបទ ឧស្សាហកម្មនិងជនបទជាដើម។ ដោយសារតែប្រជាពលរដ្ឋ កម្ពុជាចំនួន ៨០.៥%កំពុងតែរស់នៅជនបទ និងប្រជាជនក្រីក្រភាគ

[5] ក្រសួងអភិវឌ្ឍន៍ជនបទ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ,២០១៤ -២០១៨

ច្រើនរស់នៅជនបទផល ដែរ។ ដូចនេះការអភិវឌ្ឍជនបទត្រូវបានរាជរដ្ឋាភិបាលកំណត់ថា ជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតក្នុងការលុបបំបាត់ភាពក្រីក្រថ្នាក់ជាតិ លើកស្ទួយកំរិតជីវភាពប្រជាពលរដ្ឋនៅជនបទ និងជំនះនូវភាពខុសគ្នារវាងតំបន់ជនបទនិងទីក្រុង ដើម្បីអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ជាមួយគ្នានោះរដ្ឋាភិបាលក៏បានបង្កើតនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ ដើម្បីធានាកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពក្នុងទិសដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជាជាង១%ក្នុងមួយឆ្នាំ និងកំណើនសេដ្ឋកិច្ចប្រមាណជាង៧%ក្នុងមួយឆ្នាំ។ តាមរយៈនៃការអភិវឌ្ឍនេះក្រសួងអភិវឌ្ឍន៍ជនបទដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តន៍ និង រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងគោលដៅចូលរួម ចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតាមជនបទ។ ការអភិវឌ្ឍជនបទតាមរូបភាពចម្រុះរួមមាន ផ្នែកទន់ (Software) និងផ្នែករឹង (Hardware) ។

ការអភិវឌ្ឍន៍ផ្នែករឹងសំដៅលើពង្រឹងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈបណ្តុះបណ្តាលទាំងផ្នែកមន្រ្តីថ្នាក់កណ្តាលនិងថ្នាក់សហគមន៍ ជនបទដើម្បីបង្កើនចំណេះដឹងវិជ្ជាជីវៈ ក្រមសីលធម៌មន្ត្រីរាជការ និងការអប់រំប្រជាពលរដ្ឋអំពីទឹកស្អាត អនាម័យដើម្បីធានាប្រសិទ្ធភាពការងារ ភាពជាម្ចាស់ និងបង្កើនប្រាក់ចំនូលប្រចាំគ្រួសាររបស់ប្រជាជនតាមជនបទផងដែរ។

ចំពោះការអភិវឌ្ឍផ្នែករឹងសំដៅដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា៖

ផ្លូវជនបទ សំណង់សិល្បការ ការសាងសង់បង្គន់អនាម័យ ការសាងសង់អណ្តូងទឹក ស្រះទឹក ទំនប់ទឹក ប្រព័ន្ធធារាសាស្ត្រ សាលារៀន មណ្ឌលសុខភាព។ល។

**១.១.៥.១. គោលបំណងនិងគោលដៅ**

**១.១.៥.១.១. គោលបំណង**

គោលបំណងរបស់ក្រសួងអភិវឌ្ឍន៍គឺ ធ្វើអោយតំបន់ជនបទនៃកម្ពុជាក្លាចជាតំបន់អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងបរិស្ថានល្អដែលមានប្រជាជនរស់នៅប្រកបដោយសុខសន្តិភាព និងជីវភាពសមរម្យ។

**១.១.៥.១.២ គោលដៅ**

គោលដៅចម្បងរបស់ក្រសួងអភិវឌ្ឍន៍គឺ ជំរុញប្រសិទ្ធភាព និងគណនេយ្យភាពនៃការផ្តល់សាវាសាធារណៈអោយដល់ថ្នាក់មូលដ្ឋានតាមរយៈការជុសជុល និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ការផ្គត់ផ្គង់ទឹកនិងអនាម័យជនបទ ការអភិវឌ្ឍន៍សហគមន៍ជនបទ ការផ្តល់ឥណទាន

ជនបទ រួមនឹង វិស័យដទៃទៀតដើម្បីធ្វើអោយសម្រេចគោលបំណងខាងលើ គោលនយោបាយអភិវឌ្ឍន៍ជនបទ។

**១.១.៥.២ គោលនយោបាយអភិវឌ្ឍន៍ជនបទ**

ដើម្បីសម្រេចគោលបំណង និងគោលដៅខាងលើអោយទទួលបានជោគជ័យ ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើតគោលនយោបាយចំនួនពីរ សម្រាប់ជាចក្ខុវិស័យរយៈពេលវែង៖

គោលនយោបាយទី១៖ ការជានាលើកកម្ពស់កម្រិត ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទអោយខិតជិតទិប្រជុំជននៅឆ្នាំ២០២៥។

គោលនយោបាយទី២៖ ជំរុញកំណើនសេដ្ឋកិច្ច ជនបទតាមរយៈការអភិវឌ្ឍជនបទចម្រុះដោយមានការចូលរួមពីសហគមន៍ជាតិ និងអន្តរជាតិ ។

គោលនយោបាយខាងលើ ត្រូវបានរៀបចំឡើង ក្នុងបរិបទដែលប្រជាពលរដ្ឋទូទាំងប្រទេសកំពុងចូលរួមយ៉ាងសកម្មក្នុងកិច្ចអភិវឌ្ឍន៍ប្រទេស ដែលបានធ្វើអោយសេដ្ឋកិច្ចកម្ពុជាមានការប្រែប្រួលវិជ្ជមានជាបន្តបន្ទាប់ ពិសេសមានការគាំទ្រពីបណ្តាប្រទេសជាមិត្តលើសកលលោក និងដៃគូរអភិវឌ្ឍន៍នានាជាច្រើនក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ដោយយើងសង្កេតឃើញថា បច្ចុប្បន្នស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទមាន ការប្រែប្រួលយ៉ាងច្រើនក្នុងអំឡុងប៉ុន្មានឆ្នាំនេះ ដោយយើងសង្កេតឃើញថា ជីវភាពរបស់ប្រជាពលរដ្ឋបានមានភាពល្អប្រសើរបន្តិចម្តងៗ ពីកម្រិតក្រីក្រ មកមានកម្រិតជីវភាពមធ្យម និងអ្នកមានកម្រិតជីវភាពមធ្យមកាន់តែធូរធារជាងមុន តាមរយៈការផ្តល់សេវាសាធារណៈជាច្រើនរួមមាន៖ ផ្លូវជនបទ ទឹកស្អាត អនាម័យ ជំនាញវិជ្ជាជីវៈផ្សេងៗ ការផ្តល់ឥណទានជនបទ ការអប់រំសហគមន៍ជនបទ អគ្គិសនី សាលារៀន ប៉ុស្តិ៍ មណ្ឌលសុខភាព វត្តអារាម និងប្រព័ន្ធធារាសាស្ត្រ ។ល។ ក្នុងគោលដៅបង្ហិតជិតគ្នារវាងអ្នកក្រនិងអ្នកមាន រវាងទីជនបទ និងទីប្រជុំជន ក្រសួងអភិវឌ្ឍន៍ជនបទនឹងខិតខំធ្វើអោយបានាម្រេចនៅឆ្នាំ២០២៥ ខាងមុខនេះ។

គោលបំណងគោលនយោបាយទី១៖ ធ្វើអោយប្រជាពលរដ្ឋក្នុងសហគមន៍ជនបទមានលទ្ធភាពរស់នៅសោយខ្លួនឯងប្រកបដោយចំណេះដឹងជំនាញវិជ្ជាជីវៈ មូលដ្ឋានសមស្របដែលអាចបង្កើនប្រាក់ចំណូលប្រចាំគ្រួសារបាន។ ជំរុញអោយការវិនិយោគលើវិស័យកសិកម្ម និងមិនមែនកសិកម្ម សហគ្រាសខ្នាតតូច និងសហគ្រាសគ្រួសារដើម្បីបង្កើតការងារថ្មីៗបន្ថែមទៀតនៅតាមសហគមន៍ជនបទដែលមានសក្តានុពលហើយ ដូចជាផ្លូវគមនាគមន៍ បណ្តាញអគ្គិសនី និងប្រភពធនធានដទៃទៀតដើម្បីកាត់បន្ថយចំណាកស្រុក និងបង្កើនប្រាក់ចំណូលបន្ថែមទៀត។

គោលបំណងគោលនយោបាយទី២៖ តភ្ជាប់ចរន្តសេដ្ឋកិច្ចពីជនបទដាច់ស្រយាល ដែលជាតំបន់ផលិតកម្ម សេវាកម្ម ទេសចរណ៍មកកាន់ទីប្រជុំជន និងទីក្រុង ដើម្បីធ្វើពាណិជ្ជកម្ម និងទំនាក់ទំនងផ្សេងៗតាមរយៈ ធ្វើអោយប្រសើរឡើងនូវបណ្តាញផ្លូវជនបទទាំងអស់នៅទូទាំងប្រទេស។ បន្តធ្វើអោយប្រសើរឡើងថែមទៀតនូវសេវាទឹកស្អាត និង អនាម័យជនបទដល់គ្រប់សហគជនបទអោយបាន ១០០% នៅឆ្នាំ២០៥០ និងជំរុញការអភិវឌ្ឍនិងអភិរក្សជនជាតិដើមភាគតិច ដើម្បីរក្សាភាសាប្រពៃណីល្អ វប្បធម៌ទំនៀមទម្លាប់របស់ជនជាតិដើម។

### ១.១.៦ ទិសដៅគោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

ទិសដៅគោលនយោបាយអភិវឌ្ឍន៍ជនបទ គឺធ្វើអោយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទកាន់តែប្រសើរឡើង ដើម្បីធានាកាត់បន្ថយគម្លាតសេដ្ឋកិច្ចរវាងតំបន់ជនបទ ទីប្រជុំជន និង ទីក្រុង ទាំងហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ និង ផ្នែករឹង។ ដើម្បីសម្រេចទិសដៅគោលនយោបាយនេះ ក្រសួងបានកំណត់ទិសដៅអាទិភាពដូចខាងក្រោម៖

ទិសដៅទី១៖ ការកសាង និងលើកម្ពស់សមត្ថភាព

- បន្តចូលរួមអភិវឌ្ឍន៍កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជំហានទី២ និងទី៣ ដោយជំរុញនិងបង្កើតអង្គភាពអង្គការថវិការ និងអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដោយពេញលេញ។
- ចាប់ផ្តើមអនុវត្តកម្មវិធីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធពត៌មានវិទ្យា បន្តធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិការ ផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល និងផែនការប្រចាំឆ្នាំសម្រាប់ដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ដាក់អោយប្រើប្រាស់ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃគំរោងកម្មវិធីនានារបស់ក្រសួង។ បន្តបណ្តុះបណ្តាលបំពាក់បំប៉នមន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក និងខិតខំកៀរគររកជំនួយជួសជុល និងសាងសង់មន្ទីរការិយាយល័យអភិវឌ្ឍន៍ជនបទស្រុកទាង២៤រាជធានីខេត្ត។
- បន្តអនុវត្តគម្រោងផែនការមូលដ្ឋានចម្រុះ បន្តសហប្រត្តិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរួមចនែកអភិវឌ្ឍន៍ជនបទ រៀបចំនិងដាក់អោយប្រើប្រាស់ពីវិធីសាស្ត្ររៀបចំបញ្ជីគណនេយ្យហិរញ្ញវត្ថុសម្រាប់អនុវត្តអង្គភាពថវិការ។
- បន្តអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ។
- បន្តរៀបចំនិងអនុវត្តកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការដល់ថ្នាក់ក្រោមជាតិ។

- គាំទ្រដំណើរការអនុវត្តវេទិការសាធារណៈនៅតាមមូលដ្ឋាន។
- អនុវត្តគោលនយោបាយស្តីអំពីការអភិវឌ្ឍន៍ធនធានមនុស្សរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។
- កសាងសមត្ថភាព និងបណ្តុះបណ្តាលគ្រប់មន្ត្រីរាជការរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងប្រជាពលរដ្ឋដែលបានឆ្លងកាត់វគ្គបណ្តុះបណ្តាលក្នុងក្របខណ្ឌក្រសួង និងមជ្ឈមណ្ឌល។
- ផ្សព្វផ្សាយការងារក្រសួងតាមរយៈទស្សនាវដ្តី និងព្រឹត្តប័ត្រពត៌មាន។
- ជំរុញបង្កើតអោយមានមជ្ឈមណ្ឌល ឬវិទ្យាស្ថានជាតិអភិវឌ្ឍន៍ជនបទ។
- អនុវត្តសវនកម្មផ្ទៃក្នុង និងអធិការកិច្ច អនុវត្តកម្មវិធីយេនឌ័រ។

ទិសដៅទី២ ៖ ការស្តា ថែទាំ និងកែលំអរហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ

- បន្តថែទាំ និងជួសជុលផ្លូវជនបទ និងសំណង់សិល្បការ។
- បន្តកែលំអផ្លូវជនបទពីកម្រាលក្រួសក្រហមទៅជាកម្រាលកៅស៊ូពីរជាន់ ឬបេតុង។
- បន្តរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវជនបទអោយបានចប់សព្វគ្រប់ទូទាំង ២៥ខេត្ត រាជធានីបដោយកំណត់អត្តសញ្ញាណផ្លូវជនបទ ធ្វើផែនទីផ្លូវជនបទ និងដាក់ស្លាកសញ្ញាចរាចរ។
- ចាប់ផ្តើមសិក្សា និងសាកល្បងផ្លូវជនបទ និងសំណង់សិល្បការមួយចំនួនបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ទិសដៅទី៣ ៖ លើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជនបទអោយកាន់តែប្រសើរឡើង

- ការអភិវឌ្ឍភូមិចម្រុះ។
- បញ្ជ្រាបការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងសហគមន៍ជនបទ។
- បន្តបណ្តុះបណ្តាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ស្តីពីផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ។
- ការអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ចជនបទតាមរយៈវិធីសាស្ត្រចលានាភូមិ។
- បន្តអភិវឌ្ឍន៍ភូមិតាមបណ្តោយទិសខាងលិចនិងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា និងតំបន់ត្រីកោណ វៀតណាម និងឡាវ ដែលជាតំបន់ប៉ូលសេដ្ឋកិច្ចទី៥។
- បន្តពង្រឹងសមត្ថភាពរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍។
- ជំរុញទីផ្សារផលិតផល សម្រាប់ប្រជាពលរដ្ឋក្រីក្រជនបទ។

- បន្តពង្រឹងប្រតិបត្តិការសេវាឥណទានជូនប្រជាពលរដ្ឋក្រីក្រនៅជនបទ។
- អភិវឌ្ឍអាជីវកម្មនិងសហគ្រាសខ្នាតតូច។
- ជំរុញការសាងសង់មជ្ឈមណ្ឌលអភិវឌ្ឍន៍។
- បន្តរៀបចំសហគមន៍ជនជាតិដើមភាគតិច។
- បន្តផ្គត់ផ្គង់ទឹកស្អាតដល់តំបន់ជនបទតាមរយៈការជួសជុល ថែទាំ និងសាងសង់អណ្តូងទឹកគ្រប់ប្រភេទ ស្រះទឹក ពាងយក្ស ពិសេសជំរុញកាងប្រព័ន្ធចែកចាយទឹកតាមទុយោនៅតំបន់ដែលមានប្រភពទឹកស្រាប់។
- បង្កើតកម្មវិធីជាតិនៃវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងរៀបចំកម្មវិធីជាតិ ស្តីពីការផ្លាស់ប្តូរទម្លាប់។
- រៀបចំយុទ្ធសាស្ត្រថវិការសម្រាប់ផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យដែលផ្តោត លើការជួយគាំទ្រគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ។
- រៀបចំតួនាទីថ្នាក់ក្រោមជាតិ ជាពិសេសឃុំ សង្កាត់ ស្រុក ក្រុង ក្នុងការផ្តល់សេវាកម្មការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅជនបទស្របគ្នាជាមួយនឹងការអនុវត្តតាមគោលការណ៍ណែនាំ និងកម្មវិធីកសាងសមត្ថភាព។
- បង្កើតកម្មវិធីជាតិផ្លាស់ប្តូរឥរិយាបថតាមរយៈកាតប្រាស្រ័យទាក់ទង។
- លើកម្ពស់ការយល់ដឹងអំពីការការពារជំងឺអេដស៍។
- បង្កើតគោលការណ៍ណែនាំស្តីពីការឧបត្ថម្ភធន សម្រាប់ទឹកស្អាត និងអនាម័យដោយផ្តោតជាពិសេសលើគ្រួសារក្រីក្រ និងងាយរងគ្រោះ។
- បែងចែកតួនាទីដល់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ (ឃុំ និងស្រុក) ផ្នែកខាងការផ្តល់សេវាពាក់ព័ន្ធជាមួយនឹងទឹក និងអនាម័យដោយផ្តល់អោយពួកគេនូវគោលការណែនាំស្តីពីការអនុវត្តនិងកម្មវិធីកសាងសមត្ថភាព។
- បង្កើតកម្មវិធីសម្រាប់គាំទ្រដល់ប្រតិបត្តិការ និងការគ្រប់គ្រងទឹកនៅថ្នាក់ភូមិ
- បន្តជួសជុលសាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូចដើម្បីផ្តល់ទឹកសម្រាប់កសិកម្មខ្នាតតូចនិងមធ្យម។
- បន្តអប់រំអំពីសុខភាព និងអនាម័យព្រមទាំងកសាងបង្គន់អនាម័យដល់ប្រជាពលរដ្ឋក្នុងសហគមន៍ជនបទ។

## សន្និដ្ឋានជំពូក

មុននឹងចូលដល់ការបកស្រាយនៅកត្តា និងផ្នែកដែលបានចូលរួមជាមួយក្នុងប្រធានបទយើងនេះ។ គួរតែមានការបកស្រាយអោយបានក្បោះក្បាយទៅលើ លក្ខណៈនៃប្រធានបទ ក៏ដូចជាពាក្យ គន្លឹះនៅក្នុងប្រធានបទមួយនេះ ដែលជាហេតុនាំអោយមានភាពងាយស្រួលក្នុងការអង្កេតមើលទៅលើ កិច្ចការងារដែលបាន ស្រាវជ្រាវនៅ ក្នុងជំពូកផ្សេងៗទៀត។ ទ្រឹស្តីនៃអ្នកប្រាជ្ញក៏ជាជំនួយនៃកិច្ចការស្រាចជ្រាវ ដែលបានផ្តល់នៅគំនិត និងស្ថានការយល់ដឹងរបស់ យើងបន្ថែមទៀត។ គោលនយោបាយ និងផែនការយុទ្ធសាស្រ្តនានា បានរួមបញ្ចូលក្នុងនេះផងដែរ ដែលនាំអោយលក្ខណៈនៃកិច្ចស្រាវជ្រាវនេះ មានសភាពយ៉ាងរលូនដល់ការសិក្សាលើប្រធានបទ។ បង្រួមមកវិញវាជាការលម្អិតនៃភាគន័យ តូចៗ ដែលបង្កើតបានជាកិច្ចសិក្សាស្រាវជ្រាវអោយបានល្អឥតខ្ចោះ។

# ជំពូកទី ២
# ស្ថានភាពទូទៅ ឃុំព្រែករៃ
# ស្រុកល្វាឯម ខេត្តកណ្តាល

# ជំពូកទី ២

# ស្ថានភាពទូទៅ ឃុំព្រៃករ ស្រុកល្វាឯម ខេត្តកណ្ដាល

## ២.១ ស្ថានភាពជាក់ស្ដែង ទីតាំងភូមិសាស្ត្រ និងរចនាសម្ព័ន្ធគ្រប់គ្រង តួនាទីភារកិច្ច សមាជិកឃុំព្រៃករ

### ២.១.១ ស្ថានភាពជាក់ស្ដែងផ្ទាល់នៃឃុំព្រៃករ[6]

* ក្នុងភូមិឃុំមានសភាពស្ងប់ស្ងាត់ នៅតាមតំបន់មួយចំនួន មានការអភិវឌ្ឍមានដូចជា សាលារៀន, ទីវត្តអារាម, មន្ទីពេទ្យ, មានការចាក់ធ្វើផ្លូវ, មានសំណង់ផ្ទះប្រជាជនធ្វើបន្ត, ហេដ្ឋារចនាសម្ព័ន្ធស្របតាមលក្ខណរដ្ឋ។
* ប្រជាជន មានភាពរួសរាយរាក់ទាក់ មានប្រាស្រ័យទាក់ទងគ្នាល្អ មានការជួយយកចិត្តទុកដាក់ ទៅកាន់អ្នកជិតខាង ពុំឃើញមានការឈ្លោះប្រកែកហិង្សាណាមួយគួរអោយកត់សំគាល់។
* មានឃើញការឃោមកាមពីសំណាក់នគរបាលភូមិឃុំ ដើម្បីធ្វើអោយមានសុវត្ថិភាពក្នុងភូមិឃុំ កុំអោយមានភាពមិនប្រក្រតីណាមួយកើតឡើងដោយចៃដន្យ នោះនឹងអាចដោះស្រាយបានទាន់ពេលវេលា។
* ឃើញមានដំណាំជាច្រើនបានជាផ្កា ជាផល ដែលសម្លឹងមើលឃើញតែពណ៌បៃតង មានសភាពស្រស់ស្រាយ ដោយពុំមានអ្វីគួរអោយខ្លាចរអារក្នុងឃុំព្រៃករនេះឡើយ។

### ២.១.២ ទីតាំងភូមិសាស្ត្រ[7]

ឃុំព្រៃករ ជាឃុំមួយក្នុងចំណោមឃុំទាំង ១៥ នៃស្រុកល្វាឯម មានព្រំប្រទល់៖

- ខាងកើតជាប់ឃុំភូមិធំ
- ខាងលិចជាប់ឃុំព្រែកក្មេង
- ខាងលិចជាប់ឃុំទឹកឃ្លាំង និងឃុំថ្មគរ
- ខាងជើងជាប់ស្រុកពោធិ៍រាងខេត្តព្រៃវែង

ឃុំនេះមានផ្ទៃដី ១,៦៤៦ ហិកតា មានភូមិចំនួន ៣ គឺ ភូមិព្រែករ ភូមិព្រែកឈ្មោះ និងភូមិព្រែកគង់រាជ។ ឃុំនេះមានទីតាំងស្ថិតនៅតាមបណ្ដោយដងទន្លេតូច និងតំបន់បឹងវាល

[6] ចុះទៅឃើញផ្ទាល់នៅស្ថានភាពឃុំព្រៃករ

[7] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០១៨-២០២២) ឃុំព្រៃករ ស្រុកល្វាឯម ខេត្តកណ្ដាល,ទំព័រទី១
https://km.wikipedia.org/wiki/%E1%9E%83%E1%9E%BB%E1%9F%86%E1%9E%96%E1%9F%92%E1%9E%9A%E1%9F%82%E1%9E%80%E1%9E%9A%E1%9F%83

ទំនាបជារៀងរាល់ឆ្នាំនៅរដូវវស្សាទឹកជនលិច បឹង ព្រែក ស្រែចំការ និងក្នុងភូមិមួយចំនួនគេនិយមធ្វើស្រូវប្រាំង ដែលមានផ្ទៃដីធ្វើស្រូវប្រាំងសរុប ៦២៤ ហិកតា។

### ២.១.៣ ស្ថានភាពប្រជាជនបច្ចុប្បន្ននៃឃុំព្រែកវៃ[8]

មានប្រជាជនសរុបចំនួន ៤,៩៥២ នាក់ក្នុងនោះមានចំនួនស្ត្រីសរុប ២,២៦២ នាក់ហើយមានចំនួនគ្រួសារសរុប ១,១៩៥ គ្រួសារ។ អ្នកមានអាយុពី ០១ ដល់ ១៧ឆ្នាំ មានប្រមាណជា ៣០ ភាគរយ, ពី១៨ ដល់ ៦០ឆ្នាំមានប្រមាណជា ៤៥ ភាគរយ, អ្នកមានអាយុពី ៦១ឆ្នាំឡើងទៅមានប្រមាណជា ២០ ភាគរយ។ កំណើនប្រជាជនប្រចាំឆ្នាំគឺ ២.៨ ភាគរយ, អត្រានៃភាពក្រីក្រមាន ១.៨ ភាគរយ និងប្រជាជនដែលទៅរកការងារនៅក្រៅប្រទេសមាន ០.៥ ភាគរយ។ កុមារមានអាយុ ៣ ដល់ ៥ឆ្នាំបានចូលរៀន ៥០ ភាគរយ, ៦ឆ្នាំ ៩៥ ភាគរយ, ៦ ដល់ ១១ឆ្នាំ ៩៥ ភាគរយ, ១២ ដល់ ១៤ឆ្នាំ ៩០ ភាគរយ, អ្នកចេះអក្សរអាយុ ១៥ ដល់ ១៧ឆ្នាំ ៩៨ ភាគរយ, អ្នកចេះអក្សរអាយុ ១៨ ដល់ ៤៥ឆ្នាំ ៩៨ ភាគរយ។ ជនពិការមានចំនួន ៥ នាក់ប៉ុណ្ណោះ។ ចាស់ជរាគ្មានទីពឹងចាប់ពីអាយុ ៦១ឆ្នាំឡើងមានចំនួន ៨ នាក់។

### ២.១.៤ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទីភារកិច្ចសមាជិកឃុំព្រែកវៃ

#### ២.១.៤.១ រចនាសម្ព័ន្ធគ្រប់គ្រង

ខាងក្រោមនេះជារចនាសម្ព័ន្ធនៃក្រុមប្រឹក្សាឃុំព្រែកវៃដែលមានជាប្រព័ន្ធ ងាយស្រួលដល់កិច្ចការគ្រប់គ្រងរបស់ថ្នាក់ឃុំ ភូមិ ដែលមាននៅក្នុងនោះ។ វាបង្កអោយមានភាពងាយស្រួល ក្នុងកិច្ចការងារជាសចង្វាក់ មិនបង្កអោយមានភាពរអាក់រអួល នៅពេលមានប្រតិបត្តិការណ៍ណាមួយចេញដោយរាជរដ្ឋាភិបាល។ កាលបើមានការគ្រប់គ្រង និងបែងចែកតួនាទីច្បាស់លាស់ នោះវាបង្កអោយមានភាពរលូនក្នុងភារកិច្ចធំៗ បានជាផលឬលទ្ធផលគួរជាទីគាប់ចិត្តជាក់ជាពុំខាន។

រចនាសម្ព័ន្ធគ្រប់គ្រង៖[9]

[8] ផែការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០១៨-២០២២) ឃុំព្រែកវៃ ស្រុកល្វាឯម ខេត្តកណ្តាល ទំព័រទី១

[9] ធ្វើបទសម្ភាសន៍ជាមួយស្មៀនឃុំនៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ៧.៣០ នាទីព្រឹក

ខេត្តកណ្តាល
ស្រុកល្វាឯម
ឃុំព្រែករៃ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា, ព្រះមហាក្សត្រ**

**លោក នង នាង មេឃុំ**

**លោក ចាន់ ចេង ជំទប់ទី១**

**លោកស្រី អ៊ុក សៀះ ជំទប់ទី២**

**លោកស្រី សួន សារេន**
**សមាជិកក្រុមប្រឹក្សាឃុំ**

**លោក ហេង ផល្លី**
**សមាជិកក្រុមប្រឹក្សាឃុំ**

**លោក ទេព ថែម មេភូមិ ព្រែករៃ**

**លោក ខៀវ សារឿន អនុភូមិ**

**លោកស្រី រឿង លាប**
**សមាជិកភូមិ**

**លោក ខួន ឡេង មេភូមិ ព្រែកឈ្លោះ**

**លោក ប្រាក់ វង្ស អនុភូមិ**

**លោកស្រី សិន អឿន**
**សមាជិកភូមិ**

**លោក អ៊ូ ខុន មេភូមិ ព្រែកគង់រាជ**

**លោក ហ៊ុយ លៀង អនុភូមិ**

**កញ្ញា សិន វាសនា**
**សមាជិកភូមិ**

### ២.១.៤.២ តួនាទីភារកិច្ចសមាជិកឃុំព្រែករៃ

តួនាទី និងភារកិច្ចរបស់សមាជិក ឃុំព្រែករៃ

ក. ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងធ្វើការអធិបតីនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់, ធានាថា ក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ, ធានាថា កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានធ្វើឡើងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំសង្កាត់ និងរក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

ខ. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានតួនាទីដូចជាធានាថាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាចតួនាទី និងមុខងារដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ, ចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់និង ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

គ. មេឃុំ ចៅសង្កាត់

ចំពោះមេឃុំ ចៅសង្កាត់ គឺធានាថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្ត, រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមព្រឹក្សាឃុំ សង្កាត់, ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការងារថវិកាហិរញ្ញវត្ថុ និងការអនុវត្តអំណាចតួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់, បំពេញភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឲ្យ និងផ្ទេរសិទ្ធដល់ជំទប់ ចៅសង្កាត់រងតាមឋានុក្រមពេលខ្លួនអវត្តមាន។

ឃ. ជំទប់ទី១ ចៅសង្កាត់រងទី១

ជំទប់ទី១ ចៅសង្កាត់រងទី១ គឺទទួលជួយមេឃុំចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន និងបំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

ង. ជំទប់ទី២ ចៅសង្កាត់រងទី២

ជំទប់ទី២ ចៅសង្កាត់រងទី២ មានតួនាទីជួយមេឃុំ ចៅសង្កាត់លើការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ, បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់ និងជំទប់ទី១ ចៅសង្កាត់រងទី១ អវត្តមាន និងបំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

ច. គណៈកម្មធិការនានា

គណៈកម្មធិការនានា គឺជាអ្នកដែលផ្តល់យោបល់ និងជួយការងារជាក់លាក់មួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដូចជាការកសាងផែនការ និងថវិកា, រាយការណ៍អំពីការអភិវឌ្ឍការងារប្រចាំខែរបស់ខ្លួន និងផ្តល់យោបល់ពីវិធានការត្រូវអនុវត្តដែលពាក់ព័ន្ធទៅនឹងការងារជាសមត្ថកិច្ចរបស់ខ្លួន។

ឆ. ស្មៀនឃុំ សង្កាត់

ថ្វីត្បិតតែស្មៀនឃុំ សង្កាត់ជាបុគ្គលិកស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋបាលស៊ីវិលរបស់ក្រសួងមហាផ្ទៃក៏ពិតមែន ប៉ុន្តែក្នុងការអនុវត្តការងារស្មៀនឃុំ និងសង្កាត់ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់ជាអ្នកជួយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ជំទប់ ចៅសង្កាត់រង និងគណៈកម្មាធិការនានា បំពេញតួនាទី និងមុខងារស្របទៅតាមតម្រូវការផ្នែកច្បាប់, បំពេញការងាររដ្ឋបាល, ធានាថាសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្របទៅនឹងល័ក្ខខ័ណ្ឌច្បាប់, ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងការអនុវត្តកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ឃុំ សង្កាត់, ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការលើកលែងតែការទទួលការអនុញ្ញាតឲ្យអវត្តមានជាមុនពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំឲ្យមានក្តារខៀនព័ត៌មានមួយ ឬច្រើនកន្លែង ដើម្បីបិទផ្សាយសេចក្តីជូនដំណឹង សេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ សម្រាប់ឲ្យសាធារណៈជនទូទៅបានដឹងព័ត៌មាន។

ជ. បុគ្គលិកឃុំ សង្កាត់

មាត្រា២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ចែងថា " ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋ ដើម្បីជួយកិច្ចការរបស់ខ្លួនតាមសេចក្តីត្រូវការ និងការចាំបាច់នៃការងារ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្ថយការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់"។

បែបបទនៃការជ្រើសរើសបុគ្គលិកឃុំ សង្កាត់មានបរិយាយនៅក្នុងសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់។

ឈ. មេភូមិ និងជំនួយការមេភូមិ

ឈ.១ មេភូមិ

ចំពោះមេភូមិទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន, តំណាងឲ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់, បង្កើនការពិគ្រោះយោបល់ ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់, នឹងត្រូវធានាផ្តល់ព័ត៌មានជាឯកសារសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន។ ហើយឯកសារព័ត៌មានទាំងនោះអាចរួមមានព័ត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់, ត្រូវទទួលត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឲ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។និងចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវ ដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួនមានជាអាទ៍៖

- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីរបៀបបង្កើន និងកសាងសមត្ថភាព និងធនធានរបស់ភូមិ
- ផ្តល់យោបល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់អំពី៖
  - តម្រូវការ និងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
  - ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន
  - ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន។

បញ្ជាក់៖

- មេភូមិមិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ។
- មេភូមិពុំមានសិទ្ធិអំណាចសម្រេចបញ្ហាណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ ឬសង្កាត់ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃបានឡើយ។ ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬគណៈកម្មាធិការ ឬអង្គការ ណាមួយនៅក្នុងភូមិបានឡើយលើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុង ប្រកាសរបស់ក្រសួងមហាផ្ទៃ។

ឈ.២.ជំនួយការមេភូមិ

- អនុប្រធានភូមិ ទទួលការងារជំនួសមេភូមិក្នុងពេលដែលមេភូមិអវត្តមាន ដោយមានមូលហេតុច្បាស់លាស់ ដូចជាមានជំងឺ ឬមានបេសកម្មចេញក្រៅឃុំ សង្កាត់របស់ខ្លួនលើសពី១ថ្ងៃ។ ក្រៅពីនេះអនុប្រធានភូមិត្រូវទទួលជួយមេភូមិលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានាក្នុងភូមិតាមគម្រោងផែនការរបស់ឃុំ សង្កាត់។
- សមាជិកភូមិ ទទួលជួយធ្វើជាលេខាធិការឲ្យភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិ ការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ។

បញ្ជាក់៖ ក្រៅពីការងារខាងលើនេះមេភូមិអាចធ្វើការបែងចែក ឬប្រគល់ភារកិច្ចដល់ អនុប្រធាមភូមិ និងសមាជិកភូមិតាមការចាំបាច់ និងធ្វើសេចក្ដីរាយការណ៍ជូនមេឃុំ ចៅសង្កាត់សាមី។

## ២.២ ចក្ខុវិស័យ, គោលបំណង, គោលដៅ, យុទ្ធសាស្ត្រនៃការអភិវឌ្ឍ[10]

### ២.២.១ ចក្ខុវិស័យអភិវឌ្ឍន៍

ប្រជាពលរដ្ឋក្នុងឃុំ ត្រូវបានលើកកម្ពស់ជីវភាពរស់នៅសម្បូរ ធូរធារ មានសុខមាលភាព សេចក្ដីថ្លៃថ្នូរ និង សុវត្ថិភាពព្រមទាំងធានានូវ បរិស្ថានល្អ និរន្តរភាពធនធានធម្មជាតិ និងសមធម៌យេនឌ័រប្រកបដោយប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងមានការចូលរួមដោយមានប្រសិទ្ធិភាពក្នុងការដឹកនាំ និង ការគ្រប់គ្រង អោយមានការអភិវឌ្ឍន៍ឈានឡើងជាបន្ត។

### ២.២.២ គោលបំណងអភិវឌ្ឍន៍

នៅឆ្នាំ ២០១៨ ប្រជាពលរដ្ឋមានជីវភាពធូរធារ ដោយមានស្បៀងហូបចុកគ្រប់គ្រាន់សម្បូរធូរធារ អត្រាភាពក្រីក្រមកនៅត្រឹមកម្រិតអប្បបរមា ហើយត្រូវបានលើកកម្ពស់នូវ សុខភាព រីឯអត្រាបរណៈភាពត្រូវបានកាត់បន្ថយ វិស័យអប់រំមានគុណភាពស្របតាមស្តង់ដាបច្ចេកទេស។ មានសមភាពយេនឌ័រ បង្កើនមុខរបរដល់យុវជន យុវនារី ជនពិការ អ្នកគ្មានទីពឹង ជនក្រីក្រ ជាពិសេសជន ងាយនឹងរងគ្រោះ ប្រជាពលរដ្ឋទទួលបានកម្មសិទ្ធដីធ្លី កាត់បន្ថយទំនាស់ ទប់ស្កាត់ការបំផ្លាញធនធានធម្មជាតិ បរិស្ថាន ថៃរក្សាអោយបានល្អ លើកកម្ពស់ការយល់ដឹង និងត្រៀមលក្ខណៈអន្តរាគមន៍បន្ទាន់ នៅពេលមានគ្រោះមហន្តរាយកើតនៅក្នុងមូលដ្ឋាន ធានាបង្កើនសមត្ថភាពមន្ត្រីឃុំ ភូមិអោយស្របតាម គោលការណ៍ផ្តល់សេវាសាធារណៈ បានឆាប់រហ័ស គ្រប់គ្រងឯកសារលិខិតស្នាម មានកម្រិតខ្ពស់ ទប់ស្កាត់ និងកាត់បន្ថយរាល់បទល្មើស មិនអោយកើតមានក្នុងសហាគមន៍ ប្រជាពលរដ្ឋរស់នៅមានសុវត្ថិភាពល្អ និងសុខដុមរម្យនាក្នុងគ្រួសារ។

[10] ផែការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០១៨-២០២២) ឃុំព្រែកវៃ ស្រុកល្វាឯម ខេត្តកណ្ដាល ទំព័រទី៦

### ២.២.៣ គោលដៅអភិវឌ្ឍន៍

ប្រជាពល់រដ្ឋមានសុវត្ថភាពស្បៀង រកចំណូលកើនពី $១,០៥៣ ដល់ $១,៨០០ មួយនាក់ក្នុង ១ឆ្នាំ។ សុខភាពប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ កាត់បន្ថយភាពមរណៈភាពមកត្រឹម ០.១ ក្នុងមួយឆ្នាំ បង្កើនសមភាពយេនឌ័រ និងប្រព័ន្ធអប់រំតាមគុណភាពគោលការណ៍កំណែទម្រង់ លក្ខណៈស្តង់ដាតាម បច្ចេកទេសលទ្ធផលប្រលង ទុតិយភូមិបានពី ៦៥ ភាគរយ ដល់ ៩៥ ភាគរយនៅឆ្នាំ ២០២២។ ប្រជាពលរដ្ឋបានប្រើប្រាស់ទទួលផលពីដីធ្លីកម្មសិទ្ធ ៨០ ភាគរយតាមកាតចុះបញ្ជីលក្ខណៈដាច់ដោយ ដុំ ការពារធនធានធម្មជាតិ បរិស្ថាន ត្រៀមលក្ខណៈ សម្ភារៈឧបករណ៍គ្រប់គ្រាន់ សម្រាប់បង្ការគ្រោះមហន្តរាយ ដោយធម្មជាតិ ឬមនុស្ស ទប់ស្កាត់ និងកាត់បន្ថយរាល់បទល្មើស មិនអោយកើតមាននៅក្នុង សហគមន៍ ដោយមានការផ្សព្វផ្សាយអោយយល់ពីច្បាប់នានា ជាបន្តបន្ទាប់។

### ២.២.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍

ស្តារ និងកែលម្អរប្រព័ន្ធធារាសាស្ត្រ បណ្តុះបណ្តាលបច្ចេកទេសកមសិកម្ម ចាក់ថ្នាំការពារកម្លាំងអូសទាញមិនអោយមានជម្ងឺ បង្កើនគុណភាពផលិតកម្មដំណាំស្រូវបង្កើនទិន្នផល និង ផ្សព្វផ្សាយ ការប្រើប្រាស់ជីគីមី និងថ្នាំផលិតពីធម្មជាតិ។ ផ្សព្វផ្សាយអំពីសុខភាពអនាម័យ ផ្សព្វផ្សាយពីការទប់ស្កាត់ នៃជម្ងឺឆ្លង ការចាក់ថ្នាំបង្ការការការពារជម្ងឺ១២មុខដល់កុមារ ផ្សព្វផ្សាយការប្រើប្រាស់តាមលក្ខណៈ អនាម័យ សាងសង់អាគារសិក្សាថ្នាក់មត្តេយ្យសមគម និងថ្នាក់បឋមសិក្សា លើកកម្ពស់គុណភាព អប់រំ និង ក្រុមសីលធមិដល់ យុវជន នារី កុមារសហការរវាងអាណាព្យាបាលសិស្ស សមត្ថកិច្ចជំរុញយុវជន និងកុមារបានចូលរៀនគ្រប់ៗគ្នា ផ្សព្វផ្សាយច្បាប់ពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ពង្រឹង និងពង្រីក សុខមាលភាពដល់ ជនពិការ ជនងាយរងគ្រោះ ជនក្រីក្រ ស្តារលទ្ធភាពពលកម្ម និងពង្រឹងសមាគមន៍ មនុស្សចាស ផ្សព្វផ្សាយច្បាប់ភូមិបាល និងសំណង់តាមអនុក្រិត្យ បន្តចុះបញ្ជីដីធ្លីតាមលក្ខណៈដាច់ដោយដុំ និងការចុះបញ្ជីដីធ្លីតាមលក្ខណៈប្រព័ន្ធ។ ផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារសម្បត្តិធម្មជាតិ មានវិធានការការពារ ព្រៃលិចទឹក និងត្រីពងកូន ជម្រកសត្វ និងទប់ស្កាត់ការប្រើប្រាស់ឧបករណ៍ខុសច្បាប់, ផ្សព្វផ្សាយអនុក្រិត្យស្តីពីការបំពុល និងការគ្រប់គ្រងកាកសំណល់រាវ រឹង, រក្សាសោភ័ណ្ឌភាពបរិស្ថាន អោយបានកម្រិតខ្ពស់, អប់រំផ្សាយអំពី ផែនការទប់ស្កាត់គ្រោះមហន្តរាយ ត្រៀមបង្កើនលក្ខណៈ និងដោះស្រាយជាបន្ទាន់នៅពេលមានគ្រោះមហន្តរាយកើតឡើង។ បណ្តុះបណ្តាលជំនាញបច្ចេកទេសតាមនីតិវិធីថ្មី បណ្តុះបណ្តាល និងពង្រឹងកិច្ចរដ្ឋបាល ជម្រុញការចុះបញ្ជីអត្រានុកូលដ្ឋានស្របច្បាប់

ធានាការគ្រប់គ្រង និងការអនុវត្តលិខិតស្នាមតាមនីតិវិធី បន្ថែមឧបករណ៍សម្ភារៈ គ្រឿងសង្ហារឹមដល់ រដ្ឋបាលឃុំ ផ្សព្វផ្សាយអំពីគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងបង្កើនចាត់វិធានការបង្ក្រាប រាល់បទល្មើសអោយទាន់ពេលវេលា។

**២.២.៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច**

ដើម្បីការអនុវត្តទទួលបានលទ្ធផលល្អប្រសើរ ឈានទៅសម្រេចគោលបំណង និងគោលដៅផ្នែកសេដ្ឋកិច្ច បណ្តាជំនាញពាក់ព័ន្ធ ត្រូវបង្កើនសមត្ថភាព ចំនេះដឹង ជំនាញ ជំរុញសេវាផលិតកម្ម មុខរបរកសិកម្ម និងក្រៅពីកសិកម្មជាពិសេសពង្រីកពង្រឹងបណ្តាញ ហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ ជូនប្រជាពលរដ្ឋ ដែលជាយុទ្ធសាស្ត្រក្នុងការកាត់បន្ថយ ភាពក្រីក្រ និងធ្វើអោយជីវភាពរស់នៅ ត្រូវបាន កែលម្អបន្ថែមទៀត។

**២.២.៤.១.១ យុទ្ធសាស្ត្រវិស័យកសិកម្ម**

_ រៀបចំចងក្រងក្រុមកសិករ ៣ក្រុម មានចំនួន ៣០ គ្រួសារ
_ បើកវគ្គបណ្តុះបណ្តាលបច្ចេកទេស និងមុខរបរក្រៅកសិកម្ម
_ ផ្តល់ទុនកម្ចីសម្រាប់ធ្វើមុខរបរ មានការប្រាក់ទាប។

**២.២.៤.១.២ យុទ្ធសាស្ត្រវិស័យធនធានទឹក**

_ ស្តារព្រែក បឹង និងស្តារប្រឡាយមេ
_ ជួសជុលទំនប់អាងតំកល់ទឹក និងសាងសង់សំណង់លូទឹក និងទ្វារទឹក
_ ទប់ទំនប់តាមព្រែក ដើម្បីការពារផលដំណាំ។

**២.២.៤.១.៣ យុទ្ធសាស្ត្រវិស័យសាធារណៈការ**

_ គោរពច្បាប់ចរាចរណ៍
_ បើកបរត្រូវពាក់មួកសុវត្ថិភាព
_ មិនត្រូវស្រវឹងពេលបើកបរយានជំនិះ
_ ម៉ូតូត្រូវមានកញ្ចក់ ភ្លើងបំភ្លឺគ្រប់គ្រាន់
_ ល្បឿនមិនហួសហេតុ និងមិននិយាយទូរស័ព្ទពេលបើកបរ...។ល។

**២.២.៤.១.៤ យុទ្ធសាស្ត្រវិស័យអភិវឌ្ឍន៍ជនបទ**

_ អោយប្រជាពលរដ្ឋ យល់ដឹងពីការប្រើប្រាស់ទឹកស្អាត និងរស់នៅស្អាត

_ អោយប្រជាពលរដ្ឋយល់ដឹងអំពីផលប៉ះពាល់ពីជាតិអាសេនិច ដែលមាននៅក្នុងទឹកអណ្តូងស្នប់

_ ជួសជុល និងសាងផ្លូវគ្រប់ច្រកចូលក្នុងស្រុកល្វាឯម។

**២.២.៤.១.៥ យុទ្ធសាស្ត្រវិស័យពន្ធដារ**

_ ផ្សព្វផ្សាយទូលំទូលាយគ្រប់រូបភាព និងមានវិធានការអនុវត្តច្បាប់សារពើពន្ធ។

**២.២.៤.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច**

ដើម្បីសម្រេចគោលបំណង និងគោលដៅផ្នែកសង្គមកិច្ច ការិយាល័យចំណុះសាលាស្រុកខិតខំប្រឹងប្រែងចុះមូលដ្ឋានឃុំ ភូមិ អោយដល់ប្រជាពលរដ្ឋ សម្រួលផ្តល់សេវាសាធារណះគ្រប់ប្រភេទ ផ្តល់ជំនាញចំនេះដឹងវិជ្ជាជីវៈជូនប្រជាពលរដ្ឋ ជាចម្បងដល់ស្ត្រី ចូលរួមថែរក្សាវប្បធម៌ប្រពៃណីអោយ ច្រុំច្រើន។

**២.២.៤.២.១ យុទ្ធសាស្ត្រវិស័យអប់រំ**

_ ពង្រឹងគុណភាពការរៀន និងបង្រៀនតាមប្រព័ន្ធបច្ចេកទេស ស្របទៅនឹងកម្មវិធី

_ ជំរុញអោយមាកម្រិតក្រមសីលធម៌ដល់យុវជន និងកុមារ

_ បង្កើនអាហាររូបករណ៍

_ សហការរវាងឪពុកម្តាយ សមត្ថកិច្ចជំរុញអោយយុវជន និងកុមារចូល រៀនគ្រប់ៗគ្នា

**២.២.៤.២.២ យុទ្ធសាស្ត្រវិស័យសុខាភិបាល**

_ ផ្សព្វផ្សាយអំពីសុខភាពអនាម័យ

_ ចាក់ថ្នាំការពារជម្ងឺ ១២មុខដល់កុមារ

_ ផ្សព្វផ្សាយទប់ស្កាត់ការរីករាលដាលនៃជម្ងឺឆ្លង

_ ផ្សព្វផ្សាយគោលការ និងចុះអនុវត្តជាក់ស្តែង

**២.២.៤.២.៣ យុទ្ធសាស្ត្រវិស័យយេនឌ័រ**

_ ផ្សព្វផ្សាយលុបបំបាត់ការរើសអើង

_ ផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ

_ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ

_ លើកកម្ពស់អភិវឌ្ឍន៍សមត្ថភាពយេនឌ័រ

- លើកកម្ពស់សមភាពយេនឌ័រក្នុងកម្រិតខ្ពស់។

**២.២.៤.២.៤ យុទ្ធសាស្ត្រវិស័យសាសនា**

- វត្តបណ្តុះបណ្តាលគណៈកម្មការវត្ត និងអាចារ្យ
- ជំរុញព្រះសង្ឃចូលសាលាពុទ្ធិកបឋមសិក្សា
- សាងសង់ព្រះវិហារបន្ទាយម្លូរ។

**២.២.៤.២.៥ យុទ្ធសាស្ត្រវិស័យសង្គមកិច្ច**

- ពង្រឹង និងពង្រីកសុខមាលភាពដល់ជនពិការ និងស្តារលទ្ធភាពពលកម្ម
- ផ្សព្វផ្សាយលុបបំបាត់ការរើសអើង
- បង្កើតសមាគមបន្ថែម និងស្វែងរកជំនួយឧបត្ថម

**២.២.៤.២.៦ យុទ្ធសាស្ត្រវិស័យវប្បធម៌**

- ផ្សព្វផ្សាយពីច្បាប់ការការពារបិតិកភ័ណ្ឌជាតិ
- បង្កើត និងបណ្តុះបណ្តាលជំនាញ រង់ភ្លេងប្រពៃណីជាតិរបស់ខ្មែរ
- ធ្វើផែនទីបង្ហាញទីទួលបុរាណ
- ផ្សព្វផ្សាយ និងមានវិធានការទប់ស្កាត់ការចាក់ផ្សាយវីដេអូមិនស្របច្បាប់

**២.២.៤.៣ យុទ្ធសាស្ត្រគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំ និងការប្រែ ប្រួលអាកាសធាតុ**

**២.២.៤.៣.១ យុទ្ធសាស្ត្រវិស័យជលផល**

ផ្នែកជំនាញជលផល រួមនិងសហគមន៍ត្រូវបានបង្កើនការផ្សព្វផ្សាយអោយយល់ដឹងពីជលផល និងមានផែនការចុះបង្ក្រាបបទល្មើសនានាក្នុងមូលដ្ឋានតាមភាពជាក់ស្តែង។

**២.២.៤.៣.២ យុទ្ធសាស្ត្រវិស័យបរិស្ថាន និងប្រែប្រួលអាកាសធាតុ**

ផ្នែកបរិស្ថាន គ្រោះមហន្តរាយ ការកើនឡើងនូវទឹកជំនន់ និងលិខិតបទដ្ឋាននានាផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយបញ្ហាប្រឈមហានីភ័យផ្សេងៗ ដូចជាការគ្រប់គ្រងការពារ ជលផល គ្រប់គ្រងកាកសំណល់គ្រប់ប្រភេទ មានសម្ភារៈលក្ខណៈការពារជាមុនមុននឹងកើតឡើង ដោយគ្រោះធម្មជាតិ ដែលជាអាទិត៍។

- ផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការបំពុល ការប្រើប្រាស់ថាមពល និងការគ្រប់គ្រងកាកសំណល់រឹង និងរាវ។

- ធានារក្សាសោភ័ណ្ឌភាព និងមានវិធានការទប់ស្កាត់។
- អប់រំផ្សព្វផ្សាយពី ការប្រើប្រាស់បច្ចេកទេសប៉ះពាល់ បរិយាកាស បរិស្ថាន។

### ២.២.៤.៤ យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល

#### ២.២.៤.៤.១ យុទ្ធសាស្ត្រវិស័យការគ្រប់គ្រងរដ្ឋបាន

សាលាឃុំមានមន្ត្រី បុគ្គលិកឃុំ និងមន្ត្រីភូមិ ដែលត្រូវបានពង្រឹងសមត្ថភាពរបស់ខ្លួន តាមរយ:ការបណ្តុះបណ្តាល ជំនាញបច្ចេកទេសថ្មីៗ ប្រកបដោយប្រសិទ្ធភាព សហការជាមួយរដ្ឋបាលគ្រប់គ្រង ថ្នាក់ពង្រឹងយន្តការ និងការអនុវត្តច្បាប់ផ្សព្វផ្សាយយកចិត្តទុកដាក់ ផ្តល់សេវាសាធារណ:បានទាន់ ពេលវេលា អោយមូលដ្ឋានទូទាំងឃុំមានសុវត្ថិភាព ស្ថេរភាព កាត់បន្ថយអំពើហិង្សាកើតឡើង ក្នុងមូលដ្ឋានដែលអាចកើតឡើងដោយចៃដន្យ និង យថាហេតុណាមួយ វាត្រូវបានផ្តល់អោយមានភាពងាយស្រួលដោយ មានកិច្ចការងារសហការរវាងប្រជាជន និង សមត្ថកិច្ចដូចជា៖

- ផ្តល់ឯកសារ ឬក្រដាសអត្រានុកូលដ្ឋានបានទាន់ពេលវេលា
- បង្កើនការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មីផ្តល់ជូនប្រជាពលរដ្ឋប្រើប្រាស់
- ទិញឧបករណ៍សម្ភារ: គ្រឿងសង្ហារឹមដល់រដ្ឋបាលស្រុក

#### ២.២.៤.៤.២ យុទ្ធសាស្ត្រវិស័យសន្តិសុខសណ្តាប់ធ្នាប់សាធារណ:

រដ្ឋបាលឃុំមានគណ:បញ្ជាការឯកភាព និងមានកិច្ចសហការជាមួយ គណ:បញ្ជាការឯកភាព ស្រុក និងខេត្ត បានធ្វើអោយស្ថានភាពក្នុងមូលដ្ឋានមានភាពសុខសាន្ត ប្រជាពលរដ្ឋរស់នៅប្រកប ដោយភាពកក់ក្តៅ សុវត្ថិភាព មានសក្តានុពលសន្តិសុខក្នុងភូមិឃុំ មានកិច្ចសហការរវាងប្រជាជនជាមួយនឹងនគរបាលឬ សមត្ថកិច្ចក្នុង តំបន់នោះ ជឿជាក់មកលើអជ្ញាធរ និងរាជរដ្ឋាភិបាលដាក់ស្តែងរដ្ឋបាលបានបង្កើតអោយមាន៖

- បង្កើនការផ្សព្វផ្សាយអំពីគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព
- ចាត់វិធានការបង្ក្រាប រាល់បទល្មើស អោយទាន់ពេលវេលា
- អប់រំផ្សព្វផ្សាយ ដល់មុខសញ្ញាល្បែងស៊ីសង និងក្មេងទំនើង...ជាដើម។

## ២.៣ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម[11]

### ២.៣.១ ស្ថានភាពសេដ្ឋកិច្ច

- សក្តានុពលៈ ឃុំព្រែកវៃ ហ៊ុំព័ទ្ធទៅដោយ ទន្លេ បឹង និងព្រែក មានគម្រោងស្តារ ប្រឡាយ ព្រែក អោយបានដំណើរការឡើងវិញ ដែលជាប្រភពសម្បូរបែប សម្រាប់ ប្រើប្រាស់ និងស្រោចស្រពផលដំណាំកសិកម្ម ព្រមទាំងបានស្ថាបនាទ្វាទឹក មួយ ចំនួនបន្ថែមទៀតផងដែរ។ ហើយមានសណ្ឋានដីនៅតាមសណ្តូរបឹង វាលសំណាប និងបឹង ព្រែកជាដីដែលសម្បូរជីជាតិ អំណោយផលដល់ការធ្វើស្រូវ និងដំណាំអនុ ផលគ្រប់ប្រភេទព្រមទាំងមាន ប្រជាកសិករយើងបាន ប្រកបមុខរបរបន្ថែមទៀតគឺ នេសាទ និងចិញ្ចឹមសត្វទៀតផង ដែលជាចំណូលសម្រាប់ទ្រទ្រង់ជីវភសពគ្រួសារ ផងដែរ។ ចំពោះផ្លូវគមនាគមន៍ មានចំនួនបីខ្សែ ដោយមួយខ្សែជាប្រភេទផ្លូវក្រួស ក្រហម និងកម្ចិចថ្មមិចឆ្លងកាត់ឃុំ ទាំងមូល និងពីរខ្សែទៀតជាផ្លូវប្រភេទដីស និង ក្រួសក្រហមដែលចូលក្នុងភូមិ ធ្វើអោយ ប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការ ធ្វើដំណើរ។
- បញ្ហាប្រឈមៈ ឃុំព្រែកវៃ ដោយស្ថានភាពទន្លេមេគ្គង្គ មិនទៀងទាត់អាកាសធាតុ ប្រែប្រួល ធ្វើអោយផលដំណាំខូចខាតដោយគ្រោះធម្មជាតិ និងបច្ចេកទេសប្រកប របរកសិកម្ម (ធ្វើស្រែ ចំការ នឹងចិញ្ចឹមសត្វ) នៅមានកម្រិត ព្រមទាំងមានការខូច ខាតផល ដំណាំដោយសារទឹកជំនន់ជន់លិចអស់។

➢ ដំណោះស្រាយៈ ផ្អែកតាមបញ្ហាខាងលើ ឃុំបានយកចិត្តទុកដាក់បញ្ហាសំខាន់ លើការ បណ្តុះបណ្តាល បច្ចេកទេសកសិកម្ម កែប្រែទម្លាប់ចាស់ប្រើប្រាស់បច្ចេកទេសថ្មី បែប ប្រ ពលវប្បកម្ម និងខិតខំស្វែងរកជំនួយឧបត្ថម្ភបន្ថែមនូវ ស្រូវពូជដល់ប្រជាកសិករដែលរង គ្រោះ។ ចំពោះស្ថានភូមិសាស្ត្រជាប្រភេទដីទំនាប ងាយរងគ្រោះដោយជំនន់ទន្លេមេគ្គង បណ្តាលអោយផ្លូវគមនាគមន៍ខូចខាត និងទ្រុឌទ្រោមជាច្រើនកន្លែង។ ប៉ុន្តែថ្មីៗនេះដោយ មានការចាត់តាំងពី សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រគល់ភារកិច្ចជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរត្ន ជាប្រធានក្រុម ការងារថ្នាក់ជាតិ ចុះជួយខេត្តកណ្តាល និងទទួលចុះជួយមូលដ្ឋានស្រុកល្វាឯមនិងលោក ទី សុខុន ជាប្រធានក្រុមការងារចុះជួយឃុំ ព្រែកវៃ ធ្វើអោយគម្រោងហេដ្ឋារចនាសម្ព័ន្ធជា

[11] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០១៨-២០២២) ឃុំព្រែកវៃ ស្រុកល្វាឯម ខេត្តកណ្តាល ទំព័រទី៣

ច្រើន ត្រូវបានឯកឧត្តម និងក្រុមការងារ លើកផែនការសាងសង់ និងជួសជុល ដូចជាផ្លូវប្រឡាយ សាលារៀន វត្តអារ៉ាម សាលាឃុំ ប៉ុស្តិ៍រដ្ឋ បាលនគរបាលជាដើម។

**២.៣.២ ស្ថានភាពសង្គមកិច្ច**

- សក្តានុពលៈ ឃុំព្រៃករ៉ៃ មានសាលាបឋមសិក្សាចំនួនពីរកន្លែង មានទទួលសុវត្ថិភាពចំនួនមួយកន្លែង មានវត្តអារ៉ាមចំនួនពីរកន្លែង មានស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំដែល ទទួលការងារសេវាសង្គមជាពិសេសការងារនារី និងកុមារ។
- បញ្ហាប្រឈមៈ នៅមានខ្វះគ្រូ ខ្វះអាគារសិក្សា សិស្សមួយចំនួនបោះបង់ចោលការសិក្សាដើម្បីស្វែងរកចំណូលទ្រទ្រង់គ្រួសារ។

➢ ដំណោះស្រាយៈ ទន្ទឹមនឹងបញ្ហាប្រឈមខាងលើឃុំបានយកចិត្តទុកដាក់សម្ទាន់លើការផ្តល់ សេវាអប់រំតាមរយៈការលើកកម្ពស់ និងកែលម្អគុណភាពអប់រំដោយបានគៀងគរប្រាក់ពីសប្បុរសជនព្រមទាំងប្រជាជនក្នុងឃុំដើម្បី ការកសាង អាគារសិក្សា និងមណ្ឌលសុខភាពនៅក្នុងឃុំ។

**២.៣.៣ ស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ**

- សក្តានុពលៈ ស្ថានភាពភូមិសាស្ត្រឃុំ យើងបានបែងចែកដីធ្លីជាប្រភេទ ដូចជាដីលំនៅដ្ឋាន ដីស្រែ ដីចំការ ដីព្រៃលិចទឹក ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងប្រើប្រាស់ ជាងនេះទៅទៀតក្នុងឃុំសម្បូរទៅដោយបឹង ព្រៃក និងអូរ ដែលជាប្រភពផ្តល់ទឹក ក្នុងការប្រើប្រាស់ ស្រោចស្រព និងផ្តល់ធនធានមច្ឆាជាតិ សម្រាប់ទ្រទ្រង់ជីវភាពរបស់ប្រាជាពលរដ្ឋ។ ព្រមទាំងបានបង្ក្រាបបទល្មើសនេសាទខុសច្បាប់ដោយដុតកម្ទេចចោល នៅនឹងកន្លែងនូវសម្ភារៈបទល្មើស ជាមួយគ្នានេះដែរឃុំមានបណ្តាញសហការជាមួយ និង មានភ្នាក់ងារសម្រាប់តាមដានការកើនឡើងនូវកម្ពស់ទឹកជំនន់ និងអាកាសធាតុ ព្រមទាំងមានវិទ្យុទាក់ទងគ្នាក្នុងឃុំ ងាយស្រួលផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ។
- បញ្ហាប្រឈមៈ ប្រជាជននៅមានទំនាស់ដីធ្លី ដោយដីភាគច្រើនពុំទាន់បានចុះបញ្ជីច្បាស់លាស់ ព្រមទាំងបឹង ព្រៃក និងអូរ ត្រូវគោករាំង បទល្មើសនេសាទនៅតែកើតមាន បណ្តាលអោយធនធានមច្ឆាជាតិត្រូវថយចុះ។

- ដំណោះស្រាយ៖ ដើម្បីកាត់បន្ថយនូវទំនាស់ដីធ្លី ឃុំបានយកចិត្តទុកដាក់លើការផ្សព្វផ្សាយច្បាប់ភូមិបាល និងជម្រុញការចុះបញ្ជីដីធ្លី ព្រមទាំងបង្ក្រាបបទល្មើសនេសាទគ្រប់ប្រភេទ និងធ្វើការផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការអភិរក្សធនធានធម្មជាតិ។

**២.៣.៤ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**:

- សក្តានុពល៖ យើងបានបែងចែកដែនដីរដ្ឋបាល ភូមិ ឃុំ និងរចនាសម្ព័ន្ធដឹកនាំត្រឹមត្រូវ ងាយស្រួលក្នុងការធ្វើការ និងគ្រប់គ្រង។ ចំពោះការងារសន្តិសុខក្រោមការដឹកនាំរបស់ ប្រមុខរាជរដ្ឋាភិបាល ពិសេសការដឹកនាំរបស់ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានស្រុក និងលោក ទី សុខុន ប្រធានក្រុមការងារ ចុះជួយឃុំព្រែកវៃ និងសហាការីគណៈបញ្ជាការឯកភាពរដ្ឋបាលឃុំ បានខិតខំរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងមូលដ្ឋានបានល្អប្រសើរ និងបានពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ច្បាប់ចរាចរណ៍ផ្លូវគោក ផ្សព្វផ្សាយផលលំបាកនៃការប្រើប្រាស់ គ្រឿងញៀន ច្បាប់ស្តីពីការទប់ស្កាត់ក្មេងទំនើងដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្ស ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មិនតែប៉ុណ្ណោះ យើងបានពង្រឹងក្រុមប្រជាការពារជាប្រចាំ ដោយមានការឧបត្ថម្ភសម្ភារៈពីឯកឧត្តមក្រុមការងារចុះជួយឃុំ ដោយមានសម្លៀក បំពាក់ និងអាយកូម ដោយបានធ្វើសកម្មភាពយាមកាម ដើរល្បាតក្នុងភូមិឃុំ ធ្វើអោយស្ថានភាពសន្តិសុខសណ្តាប់ធ្នាប់សង្គម មានសុវត្ថិភាពល្អប្រសើរ។ កម្លាំងប្រជាការពារ តាមបណ្តាឃុំ បានសហការជាមួយកងកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលរក្សាបានសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ជូនប្រជាពលរដ្ឋក្នុងការជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី ៤ ពិធីអាពាហ៍ពិពាហ៍ និងពិធីបុណ្យផ្សេងៗបានល្អប្រសើរ។

- បញ្ហាប្រឈម៖ ភូមិសាស្ត្រឃុំជាតំបន់ទំនាប ងាយនឹងរងគ្រោះដោយទឹកជំនន់ កម្លាំងសមត្ថកិច្ចមានចំនួនតិច ខ្វះប៉ុស្តិ៍យាមកាមនៅតាមភូមិ។

- ដំណោះស្រាយ៖ ឃុំបានយកចិត្តទុកដាក់ ធ្វើការផ្សព្វភ្សាយពីភាពការពារ និងភាពបន្សាំជាមួយ ទឹកជំនន់ និងបានរឹតបន្តឹងការយាមល្បាតនៅពេលយប់។

# សន្និដ្ឋានជំពូក

សរុបមកសេចក្តីមក ឃុំព្រែកវែគឺជា ឃុំដែលស្ថិតនៅក្រោមការគ្រប់គ្រងយ៉ាងយកចិត្តទុកដាក់ បំផុតពី សំណាក់រាជរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ មិនខុសពីឃុំដទៃទៀតដែរ។ ឃុំព្រែកវែបានបង្កើត អោយមាន ចក្ខុវិស័យ, គោលបំណង, គោលដៅ, យុទ្ធសាស្ត្រនៃការអភិវឌ្ឍ ដែលបង្ហាញពីការកើនឡើងនូវការអភិវឌ្ឍន៍ វិធិសាស្ត្រមួយចំនួនធំបានជោគជ័យទៅលើវិស័យអប់រំ សុខាភិបាល ការគ្រប់គ្រងធនធានធម្មជាតិ បិស្ថាន និងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមានការរាំងស្ទះមួយចំនួន ដែលបានកើតឡើងដោយសារតែ គ្រោះធម្មជាតិ, មនុស្ស និង បញ្ហាមួយចំនួនតូចទៀតដែលត្រូវប្រឈម។ ប៉ុន្តែអ្វីដែលជាភាពអវិជ្ជមានទាំងនោះ គឺ ត្រូវបានដោះស្រាយដោយយកចិត្តទុកដាក់បំផុតពីសំណាក់ នគរបាលឃុំ ដោយមានភាព សក្តិសិទ្ធបំផុត ជូនប្រជាជនក៏ដូចជាប្រជាពលរដ្ឋដើម្បីកាត់បន្ថយភាពក្រីក្រ និងបង្កើនកម្រិតជីវភាពជូនប្រជាជននៅក្នុងឃុំព្រែកវែនេះ។

# ជំពូកទី ៣
# ការពិភាក្សាលើសមិទ្ធផល, បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី ៣

# ការពិភាក្សាលើសមិទ្ធផល, បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១ វិភាគលើការអនុវត្ត និងការពិភាក្សាលើសមិទ្ធផល

### ៣.១.១ វិភាគលើការអនុវត្ត

ពួកយើងបានលើកយកវិស័យបួនធំៗ នៅក្នុងកិច្ចការងារស្រាវជ្រាវមួយនេះ ដែលមានដូចជា វិស័យអប់រំ, សុខាភិបាល, ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ, រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។

– **តារាងទិន្នន័យវិស័យអប់រំពីឆ្នាំ ២០១៥ ដល់ ២០១៨ (៣.១)**

នេះជាតារាងទិន្នន័យដែលមានស្រាប់ក្នុង កិច្ចស្រាវជ្រាវរបស់ភូមិឃុំ

| ឆ្នាំ | %កុមារចូលរៀនពី ៦ឆ្នាំ ដល់ ១៤ឆ្នាំ |
|---|---|
| ២០១៥ | ៩៨.២៤% |
| ២០១៦ | ៩៨.២៤% |
| ២០១៧ | ៩៨.២៤% |
| ២០១៨ | ៩៣.៣៣% |

(ឧបសម្ព័ន្ធទី ៣)

– **ក្រាហ្វិកវិស័យអប់រំ(៣.១)**



តាមការកត់សម្គាល់យើងឃើញថា ក្រាហ្វិកនៃ %កុមារចូលរៀនពី ៦ឆ្នាំ ដល់ ១៤ឆ្នាំ មកដល់ឆ្នាំ ២០១៨ នេះមានការថយចុះ ៤.៩១% បើធៀបនិងឆ្នាំមុនៗ ដោយមូលហេតុជាច្រើនបណ្តាលមកពី៖

- ការចំណាយពេលជួយដល់ការងារគ្រួសារ
- ការរកចំណូលជួយដល់គ្រួសារ
- គ្រួសារពុំមានថវិកាគ្រប់គ្រាន់បញ្ជូនកូនមកទទួលការអប់រំពីសាលា
- បញ្ហាអាកាសធាតុ
- និងកត្តាផ្សេងៗទៀត។

– **តារាងទិន្នន័យវិស័យសុខាភិបាលពីឆ្នាំ ២០១៧ ដល់ ២០១៨ (៣.២)**

| ឆ្នាំ | សម្រាលកូនដោយពេទ្យឆ្មបសរុប |
|---|---|
| ២០១៧ | ៩៦ នាក់ |
| ២០១៨ | ០០ នាក់ |

(ឧបសម្ព័ន្ធទី ៣)

– **ក្រាហ្វិកវិស័យសុខាភិបាល(៣.២)**




តាមក្រាហ្វិកខាងលើឃើញ ថាវាមានការប្រើនូវសេវាកម្មសម្រាលកូន ពីមណ្ឌលសុខភាពប្រចាំឃុំព្រៃកវៃ ដែលបានកើនឡើងខ្ពស់រហូតទៅដល់ ៩៦នាក់ក្នុងឆ្នាំ ២០១៧ ប៉ុន្តែក្នុងឆ្នាំ ២០១៨ ពុំទាន់មានជាតួលេខណាមួយឡើយ។ វាប្រសើរជាងការប្រើប្រាសរបៀបឬ វិធីបុរាណក្នុងកិច្ចការងារសម្រាលកូនដែលជួបប្រទះនៅគ្រោះថ្នាក់ច្រើនភាគរយជាងការសម្រាលដោយពេទ្យឆ្មប។

– **តារាទិន្នន័យវិស័យធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ (៣.៣)**

| ឆ្នាំ | %គ្រួសាររងគ្រោះដោយមហន្តរាយ |
|---|---|
| ២០១៥ | ៧.១៩% |
| ២០១៦ | ៧.១៩% |
| ២០១៧ | ៧.១៩% |
| ២០១៨ | ២.៤៣% |

(ឧបសម្ព័ន្ធទី ៣)

- **ក្រាហ្វិកវិស័យធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ(៣.៣)**




តាមក្រាហ្វិកនេះបានបង្ហាញថា គ្រួសារដែលរងគ្រោះដោយសារមហន្តរាយកធម្មជាតិនានាបានថយចុះអស់ ៤.៧៦% នាពេលបច្ចុប្បន្ន នេះបង្ហាញពីភាពរីកចម្រើន នៃការទប់ស្កាត់របស់ប្រជាជន និងកិច្ចយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល និងឃុំទាំងមូលផងដែរ។

- **តារាងទិន្នន័យវិស័យរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ (៣.៤)**

| ឆ្នាំ | %ករណីបទល្មើសក្នុងឃុំ |
|---|---|
| ២០១៥ | ២.៦៣% |
| ២០១៦ | ២.៦៣% |
| ២០១៧ | ២.៦៣% |
| ២០១៨ | ០.៩% |

(ឧបសម្ព័ន្ធទី ៣)

- **ក្រាហ្វិកវិស័យរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ (៣.៤)**




តាមក្រាហ្វិកខាងលើបានបង្ហាញបានយ៉ាងច្បាស់ថា ករណីនៃបទល្មើសនានាក្នុងឃុំបានថយចុះអស់ ១.៧៣% និងមានសុវត្ថិភាពភូមិឃុំប្រសើរជាងមុន ផ្តល់ទំនុកចិត្តដល់ប្រជាជនរស់នៅក្នុងឃុំកាន់តែមានប្រសិទ្ធភាពខ្ពស់។

- សរុបមកវិញ រាល់ភាពថយចុះ និងកើនឡើងទាំងអស់នេះសុទ្ធតែជា ការឆ្លុះបញ្ចាំងអំពីដំណើរការនៃការអភិវឌ្ឍក្នុងឃុំដែលបាន ផ្តល់ដោយរាជរដ្ឋាភិបាលជាយុទ្ធសាស្ត្រ និងការងារជាក់ ស្តែងដែលបាន អនុវត្តន៍ផ្ទាល់។ យ៉ាងណាមិញក៏វាមិនមែនជាសញ្ញាណនៃការអភិវឌ្ឍឈានដល់កម្រិតកំពូលដែលល្អៀតតខ្វោះនោះទេ ប៉ុន្តែអាចទទួលយកបានតាមលក្ខណ្ឌសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ក៏ដូចជាស្ថានភាពទាំងមូលក្នុងប្រទេសកម្ពុជាយើងផងដែរ។

### ៣.១.២ សមិទ្ធផលដែលមានថវិការ និងកិច្ចសន្យាគាំទ្រ[12]

- ✓ មានការជួសជុលផ្លូវដែលបានចាក់ដីសរនៅក្នុងភូមិព្រៃកឈ្មោះ ដែលមានរយៈប្រវែង ១,៥០០ ម៉ែត្រ ដែលមានរយៈពេលអនុវត្តគឺមួយឆ្នាំ ដែលមានថវិកាគាំទ្រគម្រោងមានទៅដល់រហូត ១០០ លានរៀលក្នុងកំឡុងឆ្នាំ ២០១៨ ដែលទទួលបាន ពីមូលនិធិឃុំ និងកម្រិតវិនិយោគទុនដែលបានបែងចែកក្នុងសកម្មភាព វិនិយោគនីមួយៗ អង្គភាពអនុវត្តគឺ ឃុំ។
- ✓ អាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាបឋមភូមិ ក្នុងអនុវិទ្យាល័យព្រៃកគង់រាជចំនួន ៩០ នាក់ រយៈពេលអនុវត្តមានចំនួន ១ឆ្នាំ ដែលមានថវិកាគាំទ្រគម្រោង ២១.៦ លានរៀលក្នុង

[12] កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៨-២០២០) ឃុំព្រៃកវៃ ស្រុកល្វាឯម ខេត្តកណ្តាល

ឆ្នាំ ២០១៨ ដែលទទួលមូលនិធិបានពីសំណាក់រាជរដ្ឋាភិបាល ហើយអង្គភាពដែលអនុវត្តគឺមន្ទីរអប់រំក្នុងឃុំ។

- ✓ ការអប់រំក្រៅប្រព័ន្ធ (ពង្រឹងមជ្ឈមណ្ឌលសិក្សាសហគមន៍) នៅក្នុងភូមិព្រៃកគង់រាជ ចំនួន ៣៥នាក់ មានរយៈពេលមួយឆ្នាំគឺឆ្នាំ ២០១៨ មានថវិកាគាំទ្រចំនួន ២០ លានរៀលពីសំណាក់រាជរដ្ឋាភិបាល អង្គភាពអនុវត្តមន្ទីរអប់រំក្នុងឃុំ។
- ✓ ផ្តល់វ៉ាក់សាំងការពារជម្ងឺ ១១មុខដល់កុមារអាយុក្រោម ១ឆ្នាំ និងថ្នាំបង្ការជម្ងឺតេតាណូសដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រី ក្នុងឃុំរហូតទៅដល់ ៩០% ក្នុងរយៈពេលមួយឆ្នាំគឺឆ្នាំ ២០១៨ មានថវិកាគាំទ្រចំនួន ៣.៣ លានរៀលពីសំណាក់រាជរដ្ឋាភិបាល ដែលមានមន្ទីសុខាភិបាលជាអ្នកអនុវត្ត។
- ✓ ការផ្តល់សេវាសម្រាលកូនដោយបុគ្គលិក សុខាភិបាល ដែលបានបណ្តុះបណ្តាលនៅមូលដ្ឋាន (RH, HC) ក្នុងឃុំទាំងមូលរហូតទៅដល់ ៩០% ក្នុងរយះពេលមួយឆ្នាំគឺឆ្នាំ ២០១៨ ដែលមានថវិការគាំទ្រ ៨.១១ លានរៀលពីសំណាក់រាជរដ្ឋាភិបាល មន្ទីរសុខាភិបាលជាអ្នកអនុវត្ត។
- ✓ កម្មវិធីពន្យារកំណើត ក្នុងឃុំទាំងមូល មានរហូតទៅដល់ ៩០% ក្នុងមួយឆ្នាំគឺឆ្នាំ ២០១៨ ដែលមានថវិកាគាំទ្រចំនួន ១.១ លានរៀលពីសំណាក់រាជរដ្ឋាភិបាល ហើយមន្ទីរសុខាភិបាលជាអ្នកអនុវត្ត។
- ✓ សេវាសុខាភាពស្ត្រីមានផ្ទៃពោះ ក្នុងឃុំទាំងមូល រហូតទៅដល់ ៩០% ដែលមានរយះពេលមួយឆ្នាំគឺឆ្នាំ ២០១៨ ដែលមានថវិកាគាំទ្រ ១.១ លានរៀលពីរាជរដ្ឋាភិបាល ហើយមន្ទីរសុខាភិបាលជាអ្នកអនុវត្ត។
- ✓ សកម្មភាពបង្ការថែទាំ និងព្យាបាលជម្ងឺអេដស៍ ក្នុងឃុំទាំងមូល មានរហូតទៅដល់ ៩០% មានរយះពេលមួយឆ្នាំគឺក្នុងឆ្នាំ ២០១៨ ដែលមានថវិកាគាំទ្រចំនួន ១ លានរៀលពីសំណាក់រាជរដ្ឋា ភិបាល មានការចូលរួមអនុវត្តពីមន្ទីរសុខាភិបាល។
- ✓ សកម្មភាពស្រាវជ្រាវ និងទប់ស្កាត់ការឆ្លងរាដាលជម្ងឺរបេង ចំពោះឃុំទាំងមូល មានរហូតទៅដល់ ៩៥% មានរយះពេលមួយឆ្នាំគឺឆ្នាំ ២០១៨ មានថវិកាគាំទ្រចំនួន ៥ លានរៀលពីសំណាក់រាជរដ្ឋាភិបាល ដែលការអនុវត្តគឺមន្ទីរសុខាភិបាល។

✓ យុទ្ធការដាក់ថ្នាំបាណកឃាដអាបេត/ ប៊ីធីអាយ ក្នុងឃុំទាំងមូល មានរហូតទៅដល់ ៩០% ដែលមានរយៈពេលមួយឆ្នាំគឺឆ្នាំ ២០១៨ ដែលមានថវិកាគាំទ្រចំនួន ១.៥ លានរៀលពីសំណាក់រាជ រដ្ឋាភិបាល ហើយមន្ទីរសុខាភិបាលជាអ្នកអនុវត្ត។

✓ អប់រំផ្សព្វផ្សាយបន្ទុកជម្ងឺឆ្លង (លើសឈាម ទឹកនោមផ្អែម សុខភាពភ្នែក សុខភាពមាត់ធ្មេញ...) ក្នុងឃុំទាំងមូល មានរហូតទៅដល់ ៩០% ដែលមានរយះពេលមួយឆ្នាំគឺឆ្នាំ ២០១៨ ដែលមានថវិកាគាំទ្រចំនួន ០.៩៦ លានរៀលពីសំណាក់រាជរដ្ឋាភិបាល ហើយមន្ទីរសុខាភិបាលជាអ្នក អនុវត្ត។

✓ ផ្តល់សេវាព្យាបាលដោយមិនយកកម្រៃដល់ប្រជាពលរដ្ឋក្រីក្រដល់មូលនិធិសមធម៌ ក្នុងឃុំទាំមូល មានរហូតទៅដល់ ១០០% មានរយៈពេលមួយឆ្នាំគឺឆ្នាំ ២០១៨ ដែលមានថវិកាគាំទ្រចំនួន ៨ លានរៀលពីសំណាក់រាជរដ្ឋាភិបាល ហើយមន្ទីរសុខាភិបាលអនុវត្ត។

✓ ប្រតិបត្តការពង្រឹងគុណភាព និងលើកកម្ពស់ សមធម៌សេវាសុខាភិបាល ក្នុងឃុំទាំងមូល រហូតទៅដល់ ១០០% មានរយៈពេលមួយឆ្នាំគឺឆ្នាំ ២០១៨ ដែលមានថវិកាគាំទ្ររហូតទៅដល់ ៣០.៦ លានរៀនពីសំណាក់រាជរដ្ឋាភិបាល ហើយមន្ទីរសុខាភិបាលជាអ្នកអនុវត្ត។

អ្វីដែលពុំមានការអនុវត្តក៏ដូចជាមានការគាំទ្រណា មួយគួរអោយកត់សម្គាល់ គឺទៅលើផ្នែកដូចជា៖

* ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
* ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

### ៣.១.៣ សញ្ញាណសម្ខាន់ៗគួរអោយកត់សម្គាល់ នៃសមិទ្ធផលដែលទទួលបានពីក្នុងភូមិឃុំ

⇒ បើយើងសង្កេតមើលទៅលើសមិទ្ធផលទាំងនោះដែលមានការចូលរួមគាំទ្រ ពីសំណាក់អ្នកមូលនិធិទុន និងពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាផ្ទាល់គឺ ពិតជាបានផ្តល់នៅឱកាសជាច្រើន ទៅលើផ្នែកធនធានមនុស្សជាមូលដ្ឋាន ដើម្បីបង្កើតនៅការអនុវត្តខ្ពស់នៃសង្គមជាតិ នាពេលអនាគត ដែលបាមើលឃើញពីភាពខ្វះខាតនៃ ប្រជាជនក្នុងឃុំព្រៃកវៃនេះតែម្តង។

⇒ មួយវិញទៀត បើយើងអង្កេតអោយកាន់តែច្បាស់លាស់បន្ថែមនោះ គឺ ហេដ្ឋារចនាសម្ព័ន្ធមិនបានបោះបង់ចោលគឺ នៅតែបន្តអភិវឌ្ឍន៍ ដែលមានការចូលរួមខ្ពស់ពីសំណាក់ ប្រជា

ជន មូល និធិទុន និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នេះបង្ហាញថា ពិតជាឆ្ពោះទៅរកការអភិវឌ្ឍន៍នាពេលអនាគតមិនខាន។

⇒ វិស័យអប់រំក៏នៅតែបន្តអោយមានការរីកដុះដាល ទាំងមានការស្រាវជ្រាវនានា ដើម្បីបណ្តុះបណ្តាល យុវជន យុវនារីជំនាន់ក្រោយ ដែលបណ្តាលអោយមាន ធនធានមនុស្សក្នុងភូមិវានឹងមានភាពរីកចំរើន ប្រសិនបើសម្បូរទៅដោយធនធានមនុស្សបែបនេះ។

⇒ វិស័យសុខាភិបាល ដោយមានការអនុវត្តនៅកិច្ចការដែលបានបញ្ជូនពីសំណាក់រាជរដ្ឋាភិបាល មកជូនអោយមន្ទីរសុខាភិបាល គឺ៖

- មានការស្រាវជ្រាវកិច្ចការនានាដែលបានផ្តល់អោយ
- មានការចាក់ថ្នាំបង្ការនានា
- មានការចាក់ថ្នាំមិនយកកម្រៃ

* អ្វីទាំងអស់នេះជាសញ្ញាណមួយដែល គួរអោយយកចិត្តទុកដាក់ទាំងស្រុងទៅលើចំណុចប៉ុន្មានទាំងនេះនៅក្នុងតំបន់ជនបទ ទាំងហេដ្ឋារចនាសម្ព័ន្ធ, ធនធានមនុស្ស និងស្ថានភាពសុខភាពមនុស្សក្នុងឃុំទាំងមូល វាជាគោលចំបងដែលត្រូវតែជាជំហារទីមួយនៃការអភិវឌ្ឍតាមទីជនបទបែបនេះ។

* ចំណុចខ្វះខាតមួយចំនួនទៀតដែលពុំទាន់មានការចូលរួមគាំទ្រជាថវិកា ក៏ដូចជាពុំមានការធ្វើកិច្ចសន្យាស្តារធ្វើរឡើងវិញក៏ដោយ ប៉ុន្តែវានឹង មានដំណោះស្រាយនាពេលខាងមុខ ដែលអ្វីទាំងអស់នេះជាកិច្ចការរបស់ មិនត្រឹមតែរាជរដ្ឋាភិបាលទេ គឺមានការចូលរួមពីរាល់ខេត្ត ស្រុក ឃុំ ភូមិ និង ប្រជាជនក្នុងតំបន់ខ្លួនផ្ទាល់ ទើបមានភាពងាយស្រួលក្នុងការអភិវឌ្ឍអោយរលូនដូចជា កិច្ចការដែលបានធ្វើរួចពីមុន ឬអាចបានល្អជាងពីកាលពីពេលមុនក៏អាចបាន បើមានការសហការល្អក្នុង ភូមិ ឃុំ ស្រុក ខេត្ត។

## ៣.២ ពិភាក្សាលើបញ្ហាប្រឈម

### ៣.២.១ បញ្ហាប្រឈមទូទៅនៅក្នុងឃុំ

❖ បញ្ហាប្រឈមស្ថានភាពសេដ្ឋកិច្ច៖ ឃុំព្រែកវៃ ដោយស្ថានភាពទន្លេមេគង្គ មិនទៀងទាត់ អាកាសធាតុ ប្រែប្រួល ធ្វើអោយផលដំណាំខូចខាតដោយគ្រោះធម្មជាតិ និងបច្ចេកទេសប្រកបរបរកសិកម្ម (ធ្វើស្រែ ចំការ នឹងចិញ្ចឹមសត្វ) នៅមានកម្រិត ព្រមទាំងមានការខូចខាតផល ដំណាំដោយសារទឹកជំនន់ជន់លិចអស់។

- ❖ បញ្ហាប្រឈមស្ថានភាពសង្គមកិច្ចៈ នៅមានខ្វះគ្រូ ខ្វះអាគារសិក្សា សិស្សមួយចំនួនបោះបង់ចោលការសិក្សាដើម្បីស្វែងរកចំណូលទ្រទ្រង់គ្រួសារ។
- ❖ បញ្ហាប្រឈមស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ បិស្ថាន និងការប្រែប្រួលអាកាសធាតុៈ ប្រជាជននៅមានទំនាស់ដីធ្លី ដោយដីភាគច្រើនពុំទាន់បានចុះបញ្ជី ច្បាស់លាស់ ព្រមទាំងបឹង ព្រៃក និងអូរ ត្រូវគោករាំង បទល្មើសនេសាទនៅតែកើតមាន បណ្តាលអោយធនធានមច្ឆាជាតិត្រូវថយចុះ។
- ❖ បញ្ហាប្រឈមស្ថានភាពនៃ ការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ភូមិសាស្ត្រឃុំជាតំបន់ទំនាប ងាយនឹងរងគ្រោះដោយទឹកជំនន់ កម្លាំងសមត្ថកិច្ចមានចំនួនតិច ខ្វះប៉ុស្តិ៍យាមកាមនៅតាមភូមិ។

### ៣.២.២ ស្ថិតិរងគ្រោះ និងងាយរងគ្រោះជាក់ស្តែង[13]

**<u>អប់រំ</u>**

- កុមារដែលមានអាយុពី ៣ ទៅ ៥ ឆ្នាំបានចូលរៀនតែ ៥០%

**<u>សុខាភិបាល</u>**

- ស្ត្រីដែលបានសម្រាលកូនដោយឆ្មបពេទ្យ ០០%
- ចំនួនគ្រួសារមានសមាជិកកើតអេដស៍ មាន ០.៣%

**<u>ភាពងាយរងគ្រោះ</u>**

- ជនពិការដែលមានអាយុ ១៨ឆ្នាំមិនអាចរកចំណូលបាន ២%
- ចំនួនចាស់ជរាគ្មានទីពឹង (៦១ឆ្នាំឡើង) ៨ នាក់

**<u>ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ</u>**

- ចំនួនគ្រួសាររងគ្រោះដោយខ្យល់ព្យុះកន្ត្រាក់ ៤ គ្រួសារ
- ចំនួនគ្រួសាររងគ្រោះដោយរាំងស្ងួត ៣ គ្រួសារ

**<u>រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ:</u>**

- ចំនួនគ្រួសារមានអំពើហិង្សាក្នុងគ្រួសារ ៦ គ្រួសារ
- ចំនួនគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន ៤ គ្រួសារ

[13] ផែការអភិវឌ្ឍន៍រយះពេលប្រាំឆ្នាំ (២០១៨-២០២២) ឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល ទំព័រទី១

## ៣.៣ ដំណោះស្រាយ

### ៣.៣.១ អប់រំ

វិស័យអប់រំត្រូវបានគេចាត់ទុកថាជា វិស័យស្នូល ដែលបំពេញអោយការអភិវឌ្ឍក្នុងតំបន់ ដំណោះស្រាយត្រូវបានផ្តល់ដោយមានការចូលរួមពីគ្រប់ផ្នែកមានដូចជារាជរដ្ឋាភិបាល ខេត្ត ស្រុក ឃុំ ភូមិ៖

- ✓ កាត់បន្ថយការចំណាយខ្ជះខ្ជាយក្នុងការងារដែលមិនចំណេញដល់កិច្ចការសង្គម
- ✓ ប្រើប្រាស់ថវិកាជំនួយដោយមានប្រសិទ្ធភាពខ្ពស់ និងអស់ពីលទ្ធភាព
- ✓ ស្រាវជ្រាវរកមូលហេតុនៃការបោះបង់ចោលនៃការសិក្សា និងទទួលយល់ដឹង និងគ្រប់គ្រងពត៌មាននៃសិស្សដែលបានបោះបង់ចោលការសិក្សាដើម្បី រកវិធីសាស្ត្រសមស្របមកដោះស្រាយជាបន្ទាន់
- ✓ ធ្វើការផ្សព្វផ្សាយពី វិធីសាស្ត្រអប់រំទៅកាន់សាលាដែលមាន
- ✓ មានជំនួយជាប្រចាំដល់សាលាខ្វះខាត
- ✓ គ្រូមានក្របខ័ណ្ឌរដ្ឋស្របតាមច្បាប់ការងារដែលមានចែង
- ✓ ពង្រឹងសណ្តាប់ធ្នាប់ក្នុងសាលា
- ✓ ចុះជួប ឬអង្កេតមើលតាមមូលដ្ឋានអប់រំផ្ទាល់ដើម្បីអោយប្រសិទ្ធភាព
- ✓ បែងចែកគ្រប់គ្រង រចនាសម្ព័ន្ធការងារអប់រំដែលត្រូវការជាចាំបាច់
- ✓ បញ្ហាទាក់ទងនិងការអបរំត្រូវមានការកត់ត្រាទុក និងដោះស្រាយជាប្រញាប់
- ✓ ផ្តល់ពត៌មានដល់មាតាបីតាដែលជាអាណាព្យាបាល អោយដឹងពី អត្ថប្រយោជន៍នៃការសិក្សា
- ✓ មានការផ្លាស់ប្តូរជាចំនេះដឹង ពីសាលាមួយទៅសាលាមួយដោយមានទំនាក់ទំនងជាប្រព័ន្ធ
- ✓ អនុវត្តការងារអប់រំអោយស្របតាមគោលការណ៍ពី មន្ទីរអប់រំអោយបានខ្ជាប់ខ្ជួន
- ✓ ពង្រឹងសមត្ថភាព ក៏ដូចជាសុវត្ថភាពនៅពេលសិក្សា
- ✓ បែងចែកអាយុ នៃការចូលសិក្សាអោយបានត្រឹមត្រូវ
- ✓ បរិស្ថាប និងអនាម័យត្រូវតែមានសភាពល្អ និងស្អាត
- ✓ បង្កើតជាពាក្យ ស្លោកអប់រំផ្លូវចិត្ត និងផ្លូវកាយនានា ដែលជាប្រយោជន៍ដល់ការអប់រំបណ្តុះបណ្តាល
- ✓ អំពើពុករលួយមិនត្រូវអោយកើតមានក្នុងសាលាទាំងមូល

- ✓ ការយកប្រាក់កម្រៃបន្ថែមពីសិស្សានុសិស្សត្រូវចាត់ចូលជាអំពើខុសច្បាប់

### ៣.៣.២ សុខាភិបាល

វិស័យសុខាភិបាល ជាវិស័យដែលត្រូវការជាចាំបាច់ ដល់ការអភិវឌ្ឍផងដែរ វាបានបន្ថែមទៅលើគុណភាពសុខភាព ធានាគ្រប់បញ្ហាជម្ងឺដែលកើតមានក្នុងភូមិឃុំ ក៏ជាកន្លែងដែប្រជាជនត្រូវការនៅពេលជួបស្ថានជម្ងឺផ្សេងៗ៖

- ✓ មានពេទ្យចាំទទួលពត៌មានទាក់ទង និងស្ថានជម្ងឺនៃប្រជាជនជាប្រចាំ
- ✓ បង្កើតអោយមានមណ្ឌលសុខភាពកាន់តែជិត ងាយស្រួលក្នុងការធ្វើដំណើរទៅកាន់
- ✓ ស្នាលសុំសម្ភារះពេទ្យអោយបានគ្រប់គ្រាន់
- ✓ ផ្តល់សេវាកម្មនានា អោយទាន់ពេលវេលា
- ✓ គ្រូពេទ្យមានទំនួលខុសត្រូវ និងសុជីវធម៌ល្អ
- ✓ មានការហ្វឹកហាត់ការងារស្ថានពេទ្យពីមន្ទីរសុខាភិបាលត្រឹមត្រូវ
- ✓ មានការបែងចែកវេនការងារប្រចាំថ្ងៃត្រឹមត្រូវ
- ✓ ផ្តល់ទំនុកចិត្តដល់ប្រជាជនក្នុងភូមិឃុំអោយមានការជឿទុកចិត្តខ្ពស់ទៅកាន់មណ្ឌល
- ✓ ពុំមានការប្រព្រឹត្តអំពើមិនស្របច្បាប់ដោយការយកប្រាក់ព្យាបាល លើសពីគោលការណ៍ដែលត្រូវបានកំណត់

### ៣.៣.៣ ភាពងាយរងគ្រោះ

ដំណោះស្រាយ និងការស្រោចស្រង់ត្រូវមានជាបន្ទាន់ វាអាចនិងធ្វើអោយទៅជាបញ្ហាធ្ងន់ធ្ងរ កាន់តែច្រើនបន្តទៀត ហើយបង្ករអោយទៅជាភាពវិកវរពិបាកក្នុងការគ្រប់គ្រង៖

- ✓ ស្នាលសុំជំនួយបន្ទាន់ ដើម្បីដោះស្រាយជូនដល់អ្នកកំពុងតែជួបប្រទះ និងប្រឈមនឹងបញ្ហា ដូជា ពិកការភាព និងចាស់ជរា
- ✓ បង្កើតជាក្រុមសហគមន៍ ថែរក្សាដល់មនុស្សទាំងនោះ
- ✓ បង្កើតជាប្រាក់ឧបត្ថមជាប្រចាំឆ្នាំ ឬប្រចាំខែ តាមលទ្ធភាពដែលធ្វើទៅបាន
- ✓ អនុញ្ញាតអោយជនពិការចូមរួមការងាររដ្ឋ និងឯកជន
- ✓ ផ្តល់ការលើកទឹកចិត្តជាប្រចាំតាមដែលអាចធ្វើទៅបាន
- ✓ បង្កើតអោយមានមន្ទីរចាស់ជរា និងជនពិការ
- ✓ មានទទួលខុសត្រូវខ្ពស់ និងមានអទិភាពខ្ពស់ក្នុងកិច្ចការងារនានា ដល់ចាស់ជរា និងជនពិការ

- ✓ ពុំមានការយកប្រាក់កម្រៃដល់ការព្យាបាលនានា ចំពោះជនពិការ និងចាស់ជរាគ្មានទីពឹង
- ✓ បង្កើតជាមូលនិធិមនុស្សធម៌ក្នុងភូមិឃុំ ដើម្បីជួយដល់មនុស្សចាស់ជរា ជនពិការនានា

**៣.៣.៤ ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ**

មានកិច្ចការជាច្រើនត្រូវដោះស្រាយក្នុងកិច្ចការស្តារ ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុវាមានដូចតទៅៈ

- ✓ មានការជីកស្តារឡើងវិញនៅព្រែក បឹងណាដែលលប់បាត់ពីសំណាក់ឃុំភូមិន និងប្រជាជន
- ✓ ផ្សព្វផ្សាយពីវិធីសាស្ត្រនៃការផ្ទុកទឹកសម្រាប់ប្រើប្រាស់នៅរដូវប្រាំងជារដូវហួតហែង
- ✓ ផ្សព្វផ្សាយពីវិធីសាស្ត្រទប់ស្កាត់នៅពេលមានគ្រោះមហាហន្តរាយធម្មជាតិនានាដែលអាចកើត មានតាមរដូវការណាមួយឬក៏ចៃដន្យ
- ✓ ចែកចាយពត៌មានដែលទាក់ទងនិងការបំផ្លាញព្រៃឈើ ការនេសាទខុសរដូវ ការធ្វើអោយខូចខាតដល់ធម្មជាតិ ដែលវាអាចនឹងជះឥទ្ធិពលអាក្រក់ត្រឡប់មកវិញ
- ✓ អនុវត្តពីនគរបាលក្នុងឃុំចុះត្រួតពិនិត្យ និងរក្សាការពារសម្បត្តិធម្មជាតិ
- ✓ មានការបើកវគ្គខ្លីៗ ក្នុងភូមិឃុំជាការសិក្សាបង្ហាញនានា ដែលអាចអនុញ្ញាតអោយមានប្រជាជនចូលរួមទទួលយកចំនេះដឹងថ្មីៗ ទាក់ទងនិងការទប់ស្កាត់បញ្ហានានា
- ✓ បង្កើតមូលនិធិមនុស្សធម៌ជួយដល់គ្រួសារណាដែលជួបប្រទះ និងមហន្តរាយនានា
- ✓ ស្នាលសុំការឧបត្ថម្ភពីរាជរដ្ឋាភិបាលដើម្បីសង្គ្រោះជាបន្ទាន់

**៣.៣.៥ រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**:

ក្នុងភូមិឃុំ សុទ្ធតែមានសមត្ថកិច្ច នគរបាលនានា ដែលត្រូវមានភារកិច្ចជាច្រើនជួយដល់ការ ជួបបញ្ហានានា ដែលបានកើតឡើងមកក្នុងភូមិ ដូចជាអំពើហិង្សា ការប្រព្រឹត្តអំពើអសន្តិសុខនានា និង ការប្រព្រឹត្តគ្រឿងញៀន វាមានប្រាកដណាស់និងមានដំណោះស្រាយៈ

- ✓ តាមដានរាល់សកម្មភាពមិនប្រក្រតីក្នុងភូមិឃុំ ជាកាតព្វកិច្ចរបស់សមត្ថកិច្ចក្នុងភូមិឃុំ
- ✓ ផ្សព្វផ្សាយពីផលវិបាកនៃការប្រើអំពើហិង្សាក្នុងគ្រួសារ
- ✓ ផ្សព្វផ្សាយពីផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន
- ✓ បង្កើតអោយមានមូលនិធិ និងការឧបត្ថម្ភលើកទឹកចិត្តនានាដល់សមត្ថកិច្ចយាមកាម
- ✓ បង្កើនប្រសិទ្ធភាពផ្នែករដ្ឋបាលភូមិឃុំ

- ✓ មានការកត់ត្រា រាល់សកម្មភាពមិនប្រក្រតីណាមួយដើម្បី ត្រៀមនិងដោះស្រាយបញ្ហានាពេលខាងមុខ
- ✓ ប្រើប្រាស់ និងអនុវត្តច្បាប់ដែលបានចែងទុកក្នុងភូមិឃុំនោះ
- ✓ មិនប្រព្រឹត្តអំពើពុករលួយក្នុងកិច្ចការងាររដ្ឋបាល និងសណ្តាប់ធ្នាប់

❖ ដូចនេះរាល់ដំណោះស្រាយទាំងអស់ខាងលើនេះ ចំនុចខ្លះបានអនុវត្ត និងប្រតិបត្តិបានល្អក្បោះក្បាយហើយ តែនៅតែមានចន្លោះមួយចំនួនគឺ ការគាំទ្រជាថវិកា និងសំណង់អាគារដែលឃុំព្រែករៃបានស្នាលសុំ ដើម្បីតែបង្កើននៅសមត្ថភាព និងកន្លែងការងារជាក់លាក់អោយមានប្រសិទ្ធភាពក្នុងកិច្ចការងារ ដែលបានចាត់ចេញជាសមិទ្ធផលភ្លាមៗ ក៏ដូចជាយូរអង្វែង។ គ្រប់ វិស័យទាំងអស់ត្រូវតែមានដំណោះស្រាយជាបន្ទាន់ មិនអាចទុកអោយវានៅបន្តរូបភាពបែបនេះតទៅមុខទៀតបានទេ។ ការអភិវឌ្ឍត្រូវតែបន្តដើរទៅមុខ ពេលជួបបញ្ហាត្រូវដោះស្រាយ មិនអាចអោយមានការបញ្ឈប់ឬ ដើរថយក្រោយនោះទេ។

## សន្និដ្ឋានជំពូក

សរុបសេចក្តីមកវិញ ការពិភាក្សាក្នុងជំពូកទីបីនេះ ជាជំពូកដែលមានសារៈសំខាន់ជាងគេ ដែល ត្រូវបានបែងចែកចេញជា ការវិភាគ ការពិភាក្សាលើសមិទ្ធផល, ការពិភាក្សាលើបញ្ហាប្រឈម និងដំណោះស្រាយនានាដែលបានបង្កើតចេញជាចំនុចៗជាច្រើនទៅតាមបញ្ហាដែលបានចែកចេញជាផ្នែក និងមានការចុះអង្កេតផ្ទាល់ពី សំណាក់ភូមិឃុំបានយ៉ាងល្អឥតខ្ចោះ មានជាស្ថិតិជាដើម។ នៅពេលដែលមានផលអវិជ្ជមាន ការជួបប្រទះ ដែលធ្វើអោយប៉ះពាល់ដល់ ការអភិវឌ្ឍក្នុងភូមិឃុំ រាល់ដំណោះស្រាយបានដោះស្រាយទៅតាមទ្រឹស្តីនានា យុទ្ធសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ពួកយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា បន្ទាប់ពីប្រើប្រាស់នូវ ដំណោះស្រាយដែលបានបកស្រាយខាងលើនេះ និងអាចជួយលើកស្ទួយនូវការអភិវឌ្ឍក្នុងភូមិឃុំ ដែលជាកិច្ចការដែលអាចជួយរុញច្រានអោយកម្រិតអភិវឌ្ឍន៍នៅក្នុងភូមិឃុំ មានការរីកចំរើនជាលំដាប់។

# សេចក្តីសន្និដ្ឋាន និង
# ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១ សេចក្តីសន្និដ្ឋាន

សរុបទាំងអស់មកវិញ ការអភិវឌ្ឍមិនមែនជាភាពងាយស្រួលនោះទេ។ វាត្រូវបានធ្វើឡើងដោយមានការខិតខំប្រឹងប្រែង ពីសំណាក់រាជរដ្ឋាភិបាល ដោយមានការចូលរួមខ្ពង់ខ្ពស់ពីអ្នកសិក្សាស្រាវជ្រាវពី បណ្ឌិត នៃសេដ្ឋកិច្ចនីមួយៗ នៃប្រទេសនីមួយៗដែលបានស្វែងយល់ នៃការរីកដុះដាល ភាពរីកចំរើនទៅមុខនៃសុខមាលភាពក្នុងប្រទេស អោយមានសភាពល្អ, អភិវឌ្ឍន៍ ជឿនលឿនបន្តដោយបង្កើតបានជាទ្រឹស្តី មកប្រើប្រាស់ និងយកធ្វើតាមលក្ខណ្ឌជាក់ស្តែងក្នុងបញ្ហាណាមួយដែលបានប៉ះពាល់ដោយប្រការណាមួយ។ ដំណោះស្រាយមានជាច្រើនកត្តាដែលជាជំនួយនៃការអភិវឌ្ឍដល់ សង្គមជាតិទាំងមូល មិនថាភូមិ ឃុំ ស្រុក ខេត្តនោះទេ តែវាអាស្រ័យទៅលើស្ថានភាព និងស្ថានការដែលបានកើតឡើងផ្ទាល់ក្នុងតំបន់ដែលមានបញ្ហាជាក់ប្រាកដនោះ។ បញ្ហាប្រឈមទាំងប៉ុន្មានដូចជា បញ្ហាប្រឈមស្ថានភាពសេដ្ឋកិច្ច, បញ្ហាប្រឈមស្ថានភាពសង្គមកិច្ច, បញ្ហាប្រឈមស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ បិស្ថាន និងការប្រែប្រួលអាកាសធាតុ និងបញ្ហាប្រឈមស្ថានភាពនៃ ការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ វានិងត្រូវបានដោះស្រាយនាពេលខាងមុខជាមិនខាន តែវាត្រូវទាមទារអោយមានដំណោះស្រាយណាមួយអោយមានប្រសិទ្ធភាព និងរហ័សទាន់ពេលវេលា ដែលជាតម្រូវការដ៏ប្រសើររបស់ប្រជាជនក្នុងតំបន់ជួបបញ្ហានោះ។

វាជាមូលហេតុដែលនាំអោយពួកយើងទាំងពីរ បានធ្វើការបង្ហាញពីវិធីសាស្ត្រ និងរបៀបនៃការដោះស្រាយលើបញ្ហាទាំងអស់នេះដែលពួកយើងបានបង្ហាញនៅក្នុងជំពូកទីបីខាងលើ ហើយយើងជឿជាក់ថា វានិងមានប្រសិទ្ធភាពក្នុងការដោះស្រាយកាត់បន្ថយនៅចំណោទចំណងបញ្ហានានា វានឹងនាំអោយមានការអភិវឌ្ឍជនបទដោយចីរភាព និងភាពគង់វង្សជានិរន្តខាងមុខ។

## ២ ការផ្តល់អនុសាសន៍

បញ្ហាដែលប្រឈមទាំងនោះដែល ធ្វើអោយមានភាពមហន្តរាយ និងរអាក់រអួលដល់កិច្ចការអភិវឌ្ឍ ត្រឡប់មកវិញសូមបញ្ចេញជាការផ្តល់អនុសាសន៍មួយចំនួនដូចជាៈ

* ចំពោះវិស័យអប់រំវិញ ត្រូវស្នាលសុំការសាងសង់ ជួសជុលនៅសំណង់ចាស់ៗ ណាដែលត្រូវបានបាក់បែកនានា
* មានការផ្លាស់ប្តូរនៅ សភាពការងារនៃភូមិឃុំ ដោយមានប្រាស្រ័យទាក់ទងល្អជាមួយ នឹងក្រសួងក្នុងក្រុងដែលជាប់ទាក់ទងទៅនឹងកិច្ចការងារ ចាត់ចែងនោះ

* ស្នាលសុំមានការតម្លើងប្រាក់ខែ និងប្រាក់លើកទឹកចិត្តជាប្រចាំខែឬ ប្រចាំឆ្នាំ វាជាផ្នែកនៃការលើកទឹកចិត្តដល់ការងារក្នុងសង្គម
* រិះរកគ្រប់មធ្យោបាយដើម្បីអោយ ប្រជាជនទទួលបានកិច្ចការងារប្រកបអាជីពរកប្រាក់កម្រៃចិញ្ចឹមជីវិតគ្រប់ៗគ្រួសារ
* ការជីកស្តារនូវ ស្ទឹង បឹងនានា ត្រូវធ្វើជាបន្ទាន់
* បង្ហាញបង្រៀន កិច្ចការងារកសិកម្មដល់ប្រជាជ
* ស្ត្រី និងបុរសមានភាពស្មើរគ្នា មិនមានភាពរើសអើងភេទ
* ជនពិការ និងចាស់ជរាមិនត្រូវបានបំភ្លេចចោល
* អ្នកផ្ទុកមេរោគអេដស៍ មិនត្រូវបានចាត់ចូលជាមនុស្សមិនប្រក្រតីដូចគេធម្មតា
* ជួយជ្រោមជ្រែងគ្រួសារដែលជួបហានិភ័យនៃគ្រោះធម្មជាតិ
* ជួយថែរក្សាការពារហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់
* ផ្សព្វផ្សាយពត៌មានសង្គមដល់ប្រជាជនក្នុង ភូមិឃុំអោយបានជ្រាបគ្រប់ៗគ្នា
* ស្នាលសុំរាជរដ្ឋាភិបាលអំពីមូលនិធិដោះស្រាយនានា ក្នុងសហគមន៍ខ្លួន

យ៉ាងណាមិញរាល់អនុសាសន៍ទាំងប៉ុន្មាននេះ គឺត្រូវបានអនុវត្តន៍តាមរយៈ ភូមិ ឃុំ ស្រុក ខេត្ត និងរាជរដ្ឋាភិបាលក្នុងប្រទេសកម្ពុជាដោយយកចិត្តទុកដាក់មកលើ តំបន់ក្រីក្រកង្វះខាត ទីជនបទគ្រប់ទីតាំងមានតម្រូវការ ជាពិសេសឃុំព្រែករៃដែលជាឃុំដែលបានលើកយកមកសរសេរសិក្សានេះ។ វាពុំអាចយកមកដោះស្រាយបានទាំងស្រុងនោះទេ តែរាល់អនុសាសន៍ខាងលើនេះវាបានសរសេរឡើងដោយមានការសិក្សាស្រាវជ្រាវក្នុង ឯកសារមានស្រាប់ និងរុករកបន្ថែម បានតាមភាពជាក់ស្តែង។

# ឯកសារយោង

# ឯកសារយោង


១. ជួនណាត វចនានុក្រមខ្មែរ ភាគទី១ ទី២ ភ្នំពេញ ពុទ្ធសាសនបណ្ឌិត១៩៦៧

២. សារណាបញ្ចប់ការសិក្សា,កម្មវិធីអភិវឌ្ឍន៍របស់ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ, ២០០២-២០០៦

៣. Moseley,Malcomlm J.(2003).Rural development : principles and practie

៤. ការអភិវឌ្ឍជនបទ ព្រុំទេវី , សាកលវិទ្យាល័យភូមិន្ទនិតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ,២០០៥

៥. ក្រសួងអភិវឌ្ឍន៍ជនបទ, ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទ,២០១៤ -២០១៨

៦. ផែការអភិវឌ្ឍន៍រយះពេលប្រាំឆ្នាំ (២០១៨-២០២២) ឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល https://km.wikipedia.org/wiki/%E1%9E%83%E1%9E%BB%E1%9F%86%E1%9E%96%E1%9F%92%E1%9E%9A%E1%9F%82%E1%9E%80%E1%9E%9A%E1%9F%83

៧. ធ្វើបទសម្ភាសន៍ជាមួយស្មៀនឃុំនៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ៧.៣០ នាទីព្រឹក

៨. កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៨-២០២០) ឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល

៩. ឯកសារកិច្ចសន្យានៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ ២០១៨

១០. https://www.google.com/search?q=kandal+province+map&source=lnms&tbm=isch&sa=X&ved=0ahUKEwiAsrPN0LPjAhVTFHIKHdBUAVcQ_AUIECgB&biw=1366&bih=625#imgrc=qL4T5yIyy5ZT_M: (ផែនទីខេត្តកណ្តាល)

# ឧបសម្ព័ន្ធទី១

## ឧបសម្ព័ន្ធទី១៖ ផែនទីខេត្តកណ្ដាល នៃព្រះរាជាណាចក្រកម្ពុជា



# ឧបសម្ព័ន្ធទី២

## ឧបសម្ព័ន្ធទី២៖ ផែនទីឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្ដាល



# ឧបសម្ព័ន្ធទី៣

## ឧបសម្ព័ន្ធទី៣៖ សង្ខេបទិន្នន័យចម្បងនៃឃុំព្រៃកៅ

| | |
|---|---|
| ផ្ទៃដីឃុំ | ១.៦៤៦ ហិចតា |
| ចំនួនភូមិ | ៣ ភូមិ |
| ភាគរយស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំនិងអ្នកដឹកនាំភូមិ | ២៨.៥៧ % |
| ចំនួនប្រជាជនសរុប | ៣.៩៤៧ នាក់ |
| ចំនួនស្ត្រីសរុប | ២០៧៧ នាក់ |
| ភាគរយកំនើនប្រជាជនប្រចាំឆ្នាំ | ១.៣៩ % |
| ចំនួនគ្រួសារសរុប | ៩៨៨ គ្រួសារ |
| ភាគរយមេគ្រួសារជាស្ត្រី | ១២.០៤ % |
| ភាគរយគ្រួសារមានមុខរបរកសិកម្ម និងដំណាំរួមផ្សំជាចម្បង | ៧៦.២៥ % |
| ភាគរយគ្រួសារមានមុខរបរនេសាទជាចម្បង | ៤.២៥% |
| ភាគរយគ្រួសារមានមុខរបរលក់ដូរជាចម្បង | ១៩.៥០ % |
| ប្រវែងផ្លូវដឹកជញ្ជូនសរុប ( បើផ្លូវទឹកគឺសូន្យ ) | ៨២៨០ ម |
| ប្រព័ន្ធស្រោចស្រព ( ប្រវែងប្រឡាយសរុប) | ៥៥០០ ម |
| ភាគរយកុមារអាយុ ៦-១៤ឆ្នាំ មិនបានចូលរៀន | ១.៧៦ % |
| ភាគរយអ្នកមិនចេះអក្សរអាយុពី ១៥-៦០ ឆ្នាំ | ៣.១៥ % |
| ភាគរយស្ត្រីមិនចេះអក្សរអាយុ ១៥-៦០ ឆ្នាំ | ២.១០ % |
| ចំនួនស្ត្រីសំរាលកូនសរុប | ៥៦ នាក់ |
| ភាគរយស្ត្រីសម្រាលកូនដោយពេទ្យឆ្មប | ៥៦ នាក់ |
| ភាគរយគ្រួសារប្រើប្រាស់ទឹកស្អាត ( ទឹកម៉ាស៊ីន ទឹកអណ្តូងស្នប់ ) | 0 % |
| ភាគរយគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | ៣២.២៩ % |
| ចំនួនគ្រួសារជនងាយរងគ្រោះក្នុងឃុំ | ៧.១៩ % |
| ចំនួនករណីបទល្មើសក្នុងឃុំ | ១.២១ % |
| ចំនួនករណីអំពើហឹង្សាក្នុងគ្រួសារ | ១.៤២ % |

(២០១៣ ដល់ ២០១៧)

| ល.រ | បរិយាយ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ |
|---|---|---|---|---|---|---|
| **ព័ត៌មានទូទៅ** | | | | | | |
| ១ | ផ្ទៃដីឃុំ សង្កាត់ (គ.ម$^{២}$ )១,៦៤៦ហិកតា | ១៦.៤៦គ.ម$^{២}$ | | | | |
| ២ | ចំនួនភូមិ | ៣ ភូមិ | | | | |
| ៣ | ចំនួនគ្រួសារ | ១,១៨៥ | | | | |
| ៤ | % មេគ្រួសារជាស្ត្រី | ១៤.៥% | | | | |
| ៥ | ចំនួនប្រជាជនសរុប | ៤,៤៥២ | | | | |
| ៦ | ចំនួនស្រី | ២,២៦២ | | | | |
| ៧ | ចំនួនប្រុស | ២,១៩០ | | | | |
| ៨ | % អ្នកមានអាយុពី០-១៧ឆ្នាំ | ៣០% | | | | |
| ៩ | % អ្នកមានអាយុពី១៨-៦០ឆ្នាំ | ៤៥% | | | | |
| ១០ | % អ្នកមានអាយុពី៦១ឆ្នាំឡើង | ២០% | | | | |
| ១១ | កំណើនប្រជាជនប្រចាំឆ្នាំ (%) | ២.៨% | | | | |
| ១២ | អត្រាភាពក្រីក្រ (%) | ១.៨% | | | | |
| ១៣ | % អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម | ៨០% | | | | |
| ១៤ | % អ្នកមានមុខរបរចម្បងផ្នែកសិប្បកម្ម | ០០% | | | | |
| ១៥ | % អ្នកមានមុខរបរចម្បងផ្នែកសេវាកម្ម | ០០% | | | | |
| ១៦ | % មនុស្សទៅរកការងារធ្វើនៅក្នុងប្រទេស | ២% | | | | |
| ១៧ | % មនុស្សទៅរកការងារធ្វើនៅក្រៅប្រទេស | ០.៥% | | | | |

| លរ | បរិយាយ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ |
|---|---|---|---|---|---|---|
| ១៨ | % ខ្នងផ្ទះមានអគ្គិសនីប្រើប្រាស់ | ៩៨% | | | | |
| **អប់រំ** | | | | | | |
| ១៩ | % កុមារអាយុ៣-៥ឆ្នាំបានចូលរៀន | ៥០% | | | | |
| ២០ | % កុមារអាយុ៦ឆ្នាំបានចូលរៀន | ៩៥% | | | | |
| ២១ | % កុមារអាយុ៦-១១ឆ្នាំបានចូលរៀន | ៩៥% | | | | |
| ២២ | % កុមារអាយុ១២-១៤ឆ្នាំនៅរៀន | ៩០% | | | | |
| ២៣ | % អ្នកចេះអក្សរអាយុ១៥-១៧ឆ្នាំ | ៩៨% | | | | |
| ២៤ | % អ្នកចេះអក្សរអាយុ១៨-៤៥ឆ្នាំ | ៩៨% | | | | |
| **សុខាភិបាល** | | | | | | |
| ២៥ | ចំនួនមណ្ឌលសុខភាព | ១ មណ្ឌល | | | | |
| ២៦ | % ស្ត្រីសម្រាលកូនដោយឆ្មបពេទ្យ | ០០% | | | | |
| ២៧ | អត្រាស្លាប់របស់មាតាក្រោយពេលសម្រាល(០-១ខែ) ក្នុង១ពាន់កំណើត | ០០% | | | | |
| ២៨ | អត្រាស្លាប់របស់កុមារក្រោយពេលកើត(០-១ខែ)ក្នុង១ពាន់កំណើត | ០០% | | | | |
| ២៩ | % កុមារអាយុពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | ៩៥% | | | | |
| ៣០ | ចំនួនគ្រួសារមានសមាជិកកើតជំងឺអេដស៍ | ០.៣% | | | | |
| **ភាពងាយរងគ្រោះ** | | | | | | |
| ៣១ | ចំនួនជនពិការ | ៥នាក់ | | | | |
| ៣២ | % ជនពិការអាយុ១៨ឆ្នាំឡើងមិនអាចរកចំណូលបាន | ២% | | | | |
| ៣៣ | ចំនួនកុមារកំព្រាឪពុកម្ដាយស្លាប់ដោយជំងឺអេដស៍ | ០០% | | | | |
| ៣៤ | ចំនួនចាស់ជរាគ្មានទីពឹង(អាយុ៦១ឆ្នាំឡើង) | ៨នាក់ | | | | |
| **ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ** | | | | | | |
| ៣៥ | ចំនួនគ្រួសាររងគ្រោះដោយខ្យល់ព្យុះ/កន្ត្រាក់ | ៥នាក់ | | | | |
| ៣៦ | ចំនួនគ្រួសាររងគ្រោះដោយទឹកជំនន់ | ២% | | | | |

| ល.រ | បរិយាយ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ |
|---|---|---|---|---|---|---|
| ៣៧ | ចំនួនគ្រួសាររងគ្រោះដោយរាំងស្ងួត | ០០% | | | | |
| ៣៨ | % គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | ៨នាក់ | | | | |
| ៣៩ | % គ្រួសារមានទឹកស្អាតប្រើប្រាស់ | ៥នាក់ | | | | |
| ក្នុងនោះ | % គ្រួសារមានទឹកម៉ាស៊ីនប្រើប្រាស់ | ២% | | | | |
| | % គ្រួសារមានទឹកអណ្ដូងស្នប់ឬអណ្ដូងចម្រុះ | ០០% | | | | |
| | % គ្រួសារប្រើទឹកអណ្ដូងជីកមានការការពារ | ៨នាក់ | | | | |
| | % គ្រួសារប្រើទឹកភ្លៀងមានការការពារ | ៥នាក់ | | | | |
| ៤០ | % គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | ២% | | | | |
| **រដ្ឋបាល និងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ** | | | | | | |
| ៤១ | % កុមារបានចុះសំបុត្រកំណើត (០-៣០ថ្ងៃ) | ៩៥% | | | | |
| ៤២ | ចំនួនគ្រួសារមានអំពើហិង្សាក្នុងគ្រួសារ | ៦គ្រួសារ | | | | |
| ៤៣ | ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ | ២នាក់ | | | | |
| ៤៤ | ចំនួនអ្នកស្លាប់ដោយអំពើហិង្សានានា | ០០នាក់ | | | | |
| ៤៥ | ចំនួនគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន | ៤គ្រួសារ | | | | |

(២០១៨ ដល់ ២០១៩)

# ឧបសម្ព័ន្ធទី៤

# ឧបសម្ព័ន្ធទី៤៖ គម្រោង សកម្មភាពមានថវិកាគាំទ្រ

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំងគម្រោង | លទ្ធផលគម្រោង | | រយៈពេលអនុវត្ត | តម្លៃគម្រោង | ប្រភពមូលនិធិ | ការគ្រោងទុកវិនិយោគ (លានរៀល) | | | | អ្នកពាក់ព័ន្ធ | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | ២០១៨ | ២០១៩ | ២០២០ | សរុប | | |
| **គម្រោង សកម្មភាពប្រើប្រាស់មូលនិធិឃុំ** | | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | | |
| ១ | ជួសជុលផ្លូវបាក់ជីសា | ១.៣.១ | ភូមិព្រែកឈ្មោះ | ១,៥០០ | ម៉ែត្រ | ១ ឆ្នាំ | ១០០ | មូលនិធិឃុំ | ១០០ | ០ | ០ | ១០០ | ឃុំ | ២០១៨ |
| | | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច (គ្មាន) | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (គ្មាន) | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ (គ្មាន) | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| **គម្រោង សកម្មភាពដែលទទួលបានការសន្យាគាំទ្រមូលនិធិពីអ្នកពាក់ព័ន្ធ** | | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច (គ្មាន) | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | | |
| ១ | អាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាបឋមភូមិ | ២.២.១ | អនុ. ព្រែកតតែង | ៥០ | នាក់ | ១ ឆ្នាំ | ២១,៦ | រដ្ឋាភិបាល | ២១.៦ | ០ | ០ | ២១.៦ | មន្ទីរអប់រំ | |
| ២ | អប់រំក្រៅប្រព័ន្ធ (ពង្រឹងមជ្ឈមណ្ឌលសិក្សាសហគមន៍) | ២.២.១ | ភូមិព្រែកតតែង | ៣៥ | នាក់ | ១ ឆ្នាំ | ២០ | រដ្ឋាភិបាល | ២០ | ០ | ០ | ២០ | មន្ទីរអប់រំ | |
| ៣ | ផ្តល់ថ្នាំគ្រាប់ការពារជំងឺ ១១មុខ ដល់កុមារអាយុក្រោម១ឆ្នាំ និងថ្នាំបង្ការជំងឺតេតាណូស ដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រី | ២.១.១ | ម.ស ឃុំ | ៥០ | % | ១ ឆ្នាំ | ៣,៣ | រដ្ឋាភិបាល | ៣,៣ | ០ | ០ | ៣,៣ | មន្ទីរសុខាភិបាល | |
| ៤ | ការផ្តល់សេវាសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលបានបណ្តុះបណ្តាលនៅមូលដ្ឋាន (RH,HC) | ២.១.២ | ម.ស ឃុំ | ៥០ | % | ១ ឆ្នាំ | ៤,១១ | រដ្ឋាភិបាល | ៤,១១ | ០ | ០ | ៤,១១ | មន្ទីរសុខាភិបាល | |
| ៥ | កម្មវិធីពន្យារកំណើត | ២.១.១ | ម.ស ឃុំ | ៥០ | % | ១ ឆ្នាំ | ១,១ | រដ្ឋាភិបាល | ១,១ | ០ | ០ | ១,១ | មន្ទីរសុខាភិបាល | |
| ៦ | សេវាសុខភាពស្ត្រីមានផ្ទៃពោះ | ២.១.១ | ម.ស ឃុំ | ៥០ | % | ១ ឆ្នាំ | ១,១ | រដ្ឋាភិបាល | ១,១ | ០ | ០ | ១,១ | មន្ទីរសុខាភិបាល | |

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំងគម្រោង | លទ្ធផលគម្រោង | | រយៈពេលអនុវត្ត | តម្លៃគម្រោង | ប្រភពមូលនិធិ | ការប្រើប្រាស់ថវិកា (លានរៀល) | | | | អង្គភាពអនុវត្ត | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | ២០១៨ | ២០១៩ | ២០២០ | សរុប | | |
| ៧ | សកម្មភាពបង្ការថែទាំ និងព្យាបាលជំងឺអេដស៍ | ២.១.១ | ឃុំ | ៩០ | % | ១ ឆ្នាំ | ១ | រដ្ឋាភិបាល | ១ | ០ | ០ | ១ | មន្ទីរសុខាភិបាល | |
| ៨ | សកម្មភាពស្រាវជ្រាវ និងទប់ស្កាត់ការឆ្លងរោគជាលជំងឺរបេង | ២.១.១ | ឃុំ | ៩៨ | % | ១ ឆ្នាំ | ៥ | រដ្ឋាភិបាល | ៥ | ០ | ០ | ៥ | មន្ទីរសុខាភិបាល | |
| ៩ | យុទ្ធនាការដាក់ថ្នាំបាណកឃាដអាបេត/បឺជីអាយ | ២.១.១ | ឃុំ | ៩០ | % | ១ ឆ្នាំ | ១,៥ | រដ្ឋាភិបាល | ១,៥ | ០ | ០ | ១,៥ | មន្ទីរសុខាភិបាល | |
| ១០ | អប់រំផ្សព្វផ្សាយបន្ទុកជំងឺ ឆ្លង (លើសឈាម ទឹកនោមផ្អែម សុខភាពភ្នែក សុខភាពមាត់ធ្មេញ...) | ២.១.២ | ឃុំ | ៩០ | % | ១ ឆ្នាំ | ០,៩៦ | រដ្ឋាភិបាល | ០,៩៦ | ០ | ០ | ០,៩៦ | មន្ទីរសុខាភិបាល | |
| ១១ | ផ្តល់សេវាព្យាបាលដោយ មិនយកកម្រៃដល់ប្រជា ពលរដ្ឋក្រីក្រតាមរយៈ មូលនិធិសមធម៌ | ២.១.២ | ឃុំ | ១០០ | % | ១ ឆ្នាំ | ៨ | រដ្ឋាភិបាល | ៨ | ០ | ០ | ៨ | មន្ទីរសុខាភិបាល | |
| ១២ | ប្រតិបត្តិការពង្រឹងគុណ ភាពនិងលើកកម្ពស់ សមធម៌សេវាសុខាភិបាល | ២.១.២ | ឃុំ | ១០០ | % | ១ ឆ្នាំ | ៣០,៦ | រដ្ឋាភិបាល | ៣០,៦ | ០ | ០ | ៣០,៦ | មន្ទីរសុខាភិបាល | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (គ្មាន) | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ (គ្មាន) | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |

# ឧបសម្ព័ន្ធទី៥

# ឧបសម្ព័ន្ធទី៥៖ គម្រោង សម្ភាពអាទិភាពមិនទាន់មានថវិកាគាំទ្រ

| ល.រ | ឈ្មោះគម្រោង | [illegible] | ទីតាំងគម្រោង | លទ្ធផលគម្រោង | | រយៈពេលអនុវត្ត | អ្នកទទួលផលផ្ទាល់ | | ចំណាយប៉ាន់ស្មាន (លានរៀល) |
|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | |
| ១/ផ្នែកសេដ្ឋកិច្ច | | | | | | | | | |
| ១ | ធ្វើលូរំដោះទឹក | | គ្រប់ភូមិ | ៧ | កន្លែង | ២ ឆ្នាំ | ៤,៤៥២ | ២,២៦២ | ១៣៧.៥ |
| ២ | ជួសជុលផ្លូវបេតុងអាមេ | | គ្រប់ភូមិ | ៨,៧៣៣ | ម៉ែត្រ | ៣ ឆ្នាំ | ៤,៤៥២ | ២,២៦២ | ៤,៣៦៦.៥ |
| ៣ | ជួសជុលទំនប់ទឹក | | ភូមិក្រាំងគគ់ កន និងក្រាំងឈ្មោះ | ១,២០០ | ម៉ែត្រ | ២ ឆ្នាំ | ៣,២៥០ | ១,៦៦៨ | ៣៣ |
| ២/ផ្នែកសង្គម | | | | | | | | | |
| ១ | ផ្សព្វផ្សាយការយល់ដឹងពីពិការភាព | | គ្រប់ភូមិ | ៥៧ | នាក់ | ១ ឆ្នាំ | ៥៧ | ២១ | ០,៥៧០ |
| ២ | ផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធជនពិការ | | គ្រប់ភូមិ | ៧៥ | នាក់ | ៣ ឆ្នាំ | ៧៥ | ២៨ | ០,៧៥ |
| ៣ | សាងសង់អាគារបឋមសិក្សា | | ភូមិក្រាំង | ១ | ខ្នង | ៣ ឆ្នាំ | ១៥០ | ៥០ | ២០០ |
| ៤ | ផ្តល់ថវិកាដល់ម៉េបង្គោលអប់រំកុមារតូចឲ្យបានសមរម្យ | | ក្រាំង, ក្រាំងឈ្មោះ | ២ | នាក់ | ១ ឆ្នាំ | ២ | ២ | ១,២ |
| ៥ | បណ្តុះបណ្តាលវិជ្ជាជីវៈ កាត់ដេរ អ៊ុតសក់ ជួសជុលទូរស័ព្ទ ទូរទស្សន៍ ម៉ាស៊ីន...ដល់យុវជន | | គ្រប់ភូមិ | ១ | វគ្គ | ១ ឆ្នាំ | ៥០ | ៣៨ | ៣.៥៦៤ |
| ៣/ផ្នែកធនធានធម្មជាតិ បរិស្ថាន កាកសំណល់ និងការប្រែប្រួលអាកាសធាតុ | | | | | | | | | |
| ១ | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យយល់ដឹងពីការរស់នៅមានបរិស្ថានល្អ | | គ្រប់ភូមិ | ២ | លើក | ១ ឆ្នាំ | ៦០ | ៤០ | ៥ |
| ២ | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យប្រើប្រាស់ឧបករណ៍នេសាទស្របច្បាប់ | | គ្រប់ភូមិ | ២ | លើក | ១ ឆ្នាំ | ១៥០ | ៣០ | ២ |
| ៤/ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | |
| ១ | ផ្សព្វផ្សាយពីផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន | | គ្រប់ភូមិ | ១ | លើក | ១ ឆ្នាំ | ២៨ | ៣ | ០,២៥០ |

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំងគម្រោង | លទ្ធផលគម្រោង | | រយៈពេល | អ្នកទទួលផលផ្ទាល់ | | ចំណាយប៉ាន់ស្មាន (លានរៀល) |
|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | អនុវត្ត | សរុប | ស្រី | |
| ២ | ផ្សព្វផ្សាយច្បាប់ភូមិបាល | | គ្រប់ភូមិ | ៣ | លើក | ១ ឆ្នាំ | ១,១៤៥ | ៧០០ | ៥.៧២៥ |
| ៣ | ផ្សព្វផ្សាយច្បាប់ចរាចរណ៍ជូនដល់ប្រជាពលរដ្ឋ | | គ្រប់ភូមិ | ៣ | លើក | ១ ឆ្នាំ | ៦០០ | ១០០ | ៣ |